ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

កំណត់ហេតុជាលាយលក្ខណ៍អក្សរ
នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ខុច"
សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩

សវនាការលើកទី៥០

ចៅក្រមសាលាដំបូង៖

លោក និល ណុន ជាប្រធាន
លោកស្រី ស៊ីលយ៉ា ខាតរ៉ាយច៍
(Judge Silvia Carwright)
លោក យ៉ា សុខន
លោក ហ្សង់ម៉ាក ឡាវែន៍
(Judge Jean-Marc Lavegne)
លោក ធូ មណី
លោក យូរ ឧត្តរា
លោកស្រី ក្លូឌា ហ្វេនស៍
(Judge Claudia Fenz)

ក្រឡាបញ្ជីសាលាដំបូង៖

លោក លឹម ស៊ុយហុង
លោកស្រី សែ កុលវុឌ្ឍី
លោក ម៉ាតូ គ្រីស្តារ *(Mr. Matteo Crippa)*
កញ្ញា ណាតាចា វិចស៍លែ រីសឺ
(Ms. Natacha Wexels-Riser)
លោក អាឡាញ ប្រៃអត *(Ms. Aline BRIOT)*

ការិយាល័យសហព្រះរាជអាជ្ញា៖

លោក តាន់ សេណារ៉ុង

លោក អានីស អះមេដ *(Mr. Anees AHMED)*

លោក ពេជ្រ សម្បត្តិ

លោក ហ្សាធិរី ឡាំពែល *(Mr.Zachery LAMPEL)*

ជនជាប់ចោទ៖

លោក កាំង ហ្គេកអ៊ាវ

មេធាវីការពារជនជាប់ចោទ៖

លោក ការ សារុត្ត

លោកស្រី ហេឡឺន អ៊ុយណាក់

(Ms. Heleyn UÑAC)

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖

កញ្ញា ទី ស្រីនណា

កញ្ញា ម៉ុច សុវណ្ណារី

លោក គីមម៉េងឃី

លោក គង់ ពិសី

លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី

(Ms. Silke Studzinsky)

លោក អាឡាំង វ៉ែនណឺ *(Mr. Alain Werner)*

មេធាវីជំនួយការរបស់សាក្សី៖

លោក គង់ សំអុន

ផ្នែកគ្រប់គ្រងតុលាការ៖

លោក អ៊ុច អរុណ

ខ្ងបសម្ព័ន្ធ

សាក្សី

លោក គក ស្រស់

សួរដោយ ចៅក្រម ធូ មណី ផ្តើមពី ..... ទំព័រ ២
សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតរ៉ាយច៍ ផ្តើមពី ..... ទំព័រ ៩
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន ផ្តើមពី ..... ទំព័រ ១៦
សួរដោយ លោក តាន់ សេណារ៉ុង ផ្តើមពី ..... ទំព័រ ២៦
សួរដោយ លោក អានីស អះមេដ ផ្តើមពី ..... ទំព័រ ២៨
សួរដោយ លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គីផ្តើមពី ..... ទំព័រ ៣១
សួរដោយ លោក ការ សារុត្ត ផ្តើមពី ..... ទំព័រ ៣៦
សួរដោយ ចៅក្រម ហ្សង់ ម៉ាកឡាវ៉ែន៍ ផ្តើមពី ..... ទំព័រ ៤០

លោក សួស ធី

សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ..... ទំព័រ ៤៤

បញ្ជីឈ្មោះ អ្នកនិយាយ៖

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

អ្នកនិយាយ	**ភាសា**
លោក អានីស អះមេដ	អង់គ្លេស
ចៅក្រម ស៊ីលយ៉ា ខាតរ៉ាយម៍	អង់គ្លេស
លោក គក ស្រស់	ខ្មែរ
លោក ការ សារុត្ត	ខ្មែរ
ចៅក្រម ហ្សង់ម៉ាក ឡាវែន៍	បារាំង
លោក តាន់ សេណារ៉ុង	ខ្មែរ
លោក សួស ធី	ខ្មែរ
ជនជាប់ចោទ	ខ្មែរ
ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ)	ខ្មែរ
ចៅក្រម ធូ មណី	ខ្មែរ
លោកស្រី សែ កុលវុឌ្ឍី	ខ្មែរ
លោក អាឡាំង វែនណឺ	អង់គ្លេស

កិច្ចដំណើរការនីតិវិធី

[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]

[០៩:០៥:១៩]

ប្រធានអង្គជំនុំ៖

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះសាលាដំបូង ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោល ថ្ងៃនេះគឺបន្តកិច្ចនីតិវិធីស្តាប់សក្ខីកម្មសាក្សីឈ្មោះ គក ស្រស់ ដោយអង្គជំនុំជម្រះ ។ មុននឹងចាប់ផ្តើមនីតិវិធី ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលត្រូវធ្វើការកោះហៅឲ្យចូលរួមដំណើរការនីតិវិធីសវនាការសម្រាប់ថ្ងៃនេះ ។

លោកស្រី សែ កុលវុឌ្ឍី៖

សូមគោរពលោកប្រធាន! ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន ។ ចំណែកឯសាក្សី គក ស្រស់ ក៏មានវត្តមាននៅក្នុងបន្ទប់សវនាការផងដែរ ។ សាក្សី KW-07 ដែលត្រូវមកផ្តល់សក្ខីកម្មបន្ទាប់ពីសាក្សី គក ស្រស់ មានវត្តមានរង់ចាំការកោះហៅពីអង្គជំនុំជម្រះ ។ សាក្សី KW-07 មិនមានជាប់ចំណងញាតិសោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទ ឬភាគីរដ្ឋប្បវេណីនោះទេ ។ សាក្សី KW-07 បានស្បថរួចហើយ ។

ប្រធានអង្គជំនុំ៖

លោក គក ស្រស់ អរុណាសួស្តី! ថ្ងៃនេះគឺអង្គជំនុំជម្រះបន្តស្តាប់សក្ខីកម្មរបស់លោក ក្នុងនាមលោកជាសាក្សីជាបន្តទៀត ហើយមុននឹងផ្តល់ជូនវេទិកានេះទៅឲ្យចៅក្រមដែលទទួលបន្ទុកនៅក្នុងការសាកសួរនេះ អង្គជំនុំជម្រះ-- យើងខ្ញុំសូមជម្រាបរំឭកអំពីសិទ្ធិនិងករណីកិច្ចដល់លោក ក្នុងនាមលោកជាសាក្សីដូចខាងក្រោម៖

សិទ្ធិក្នុងនាមលោកជាសាក្សី អាចបដិសេធក្នុងការឆ្លើយទៅសំណួរ ឬក៏អំណះអំណាងណាមួយឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងនោះ នាំឲ្យលោកត្រូវទទួលការរងការចោទប្រកាន់ប្រឆាំងនឹងលោក ។

ក្នុងនាមលោកជាសាក្សី លោកមានករណីកិច្ចនិយាយតែការណាដែលពិត ដែលលោកបានឃើញ បានដឹង បានឮដោយផ្ទាល់ ។

1 នេះជាការរំឭកទេ យើងបានប្រាប់លោករួចហើយ កាលពីលើកដំបូង គឺកាលពីថ្ងៃពុធ សប្តាហ៍
2 មុន ។ ជាបន្តនេះ សូមប្រគល់វេទិកាទៅចៅក្រម ធូ មណី ដែលលោកបានមានបំណងក្នុងការសួរដល់
3 សាក្សីរូបនេះ ។ សូមអញ្ជើញលោកចៅក្រម ធូ មណី ។
4 [០៩:០៨:៤៨]
5 **សួរដោយ ចៅក្រម ធូ មណី៖**
6 សូមអរគុណលោកប្រធាន ។ លោក គក ស្រស់ កាលពីល្ងាចថ្ងៃពុធនោះ យើងបានសួរសំណួរ
7 មួយចំនួនទៅដល់លោករួចហើយ ហើយអ៊ីចឹងថ្ងៃនេះយើងបន្តសំណួរមួយចំនួនទៀតដល់លោក ។
8 **ស:** លោក គក ស្រស់ តើក្នុងនាមលោកជាកងការពារ តើលោកធ្លាប់ដែលបានចុះទៅចាប់ខ្លួន
9 អ្នកដែលត្រូវចាប់ខ្លួនមកមន្ទីរស-២១ ដែរឬទេ?
10 **លោក គក ស្រស់៖**
11 **ឆ:** ខ្ញុំមិនដែលចុះទៅចាប់ខ្លួនទេ ។
12 **ស:** លោកបានប្រាប់អង្គសវនាការយើងកាលពីថ្ងៃមុនហើយ ថាលោកជាអ្នកយាមនៅចំណុច
13 អគារទទឹងថ្ងៃ នៅខាងជើង បាននិយាយថាប្រហែលជាអគារ “D” អ៊ីចឹងក្នុងអំឡុងពេលដែលលោកយាម
14 នៅក្នុងមន្ទីរស-២១ នោះ តើលោកយាមទីនោះរហូត ឬក៏មានការផ្លាស់ប្តូរកន្លែងយាមដែរ?
15 **ឆ:** ពេលខ្ញុំយាមនៅក្នុងមន្ទីរស-២១ យាមផ្នែកខាងក្នុងអ៊ីចឹងទៅចំនួនមួយខែ ។ រួចផុតមកខ្ញុំ
16 ផ្លាស់មកយាមតាមក្បែររបងខាងក្រៅហ្នឹងចំនួនមួយខែ ផ្លាស់វៀងរាល់ខែ ។
17 **ស:** អ៊ីចឹងបាននិយាយថា លោកយាមនៅក្នុងមន្ទីរស-២១ ហ្នឹងច្រើនកន្លែង អ៊ីចឹងមែនទេ?
18 **ឆ:** ខ្ញុំយាមនៅពីរមុខសញ្ញា ។ មួយខែយាមក្នុង មួយខែយាមក្រៅ ការពារក្នុង ការពារក្រៅតែ
19 ម្តង ហ្នឹងពីរមុខសញ្ញាហ្នឹងខ្ញុំ ។
20 **ស:** ក្នុងការយាមនៅខាងក្នុង តើលោកបានឃើញទិដ្ឋភាពអ្វីខ្លះនៅក្នុងមន្ទីរស-២១ នោះ?
21 **ឆ:** ខ្ញុំយាមនៅខាងក្នុង ដើរត្រួតពិនិត្យមើលអ្នកទោសដែលមាន អ្នកទោសខ្លះអ៊ីចឹងទៅមាន
22 ស្គាកស្នាមរបួសដែរ មកពីសួរចម្លើយសួរអីវិញហ្នឹង មានឃើញកន្ទួលកណ្តាលខ្នង កន្ទួលគៃរ៉ែមកហ្នឹង
23 ហ្នឹងមកដល់កន្លែងមុខសញ្ញារបស់ខ្ញុំ ។
24 **ស:** បាននិយាយថា ក្នុងការយាមហ្នឹងលោកជាអ្នកដើរត្រួតពិនិត្យមើលការឃុំឃាំង ។ អ៊ីចឹងតើ
25 លោកឃើញស្ថានភាពនៃការឃុំខ្លួនអ្នកទោសហ្នឹងយ៉ាងដូចម្តេចដែរ គេដាក់ខ្មោះ ឬក៏ចងអីយ៉ាងម៉េច?

ឆៃ៖ ពេលខ្ញុំយាមនៅមុខសញ្ញាខ្ញុំ អ្នកទោសគេដាក់ក្នុងបន្ទប់មួយ ។ ម្នាក់មួយៗហ្នឹងគេដាក់កងមួយរនងមួយប្រាំមួយតឹក ហើយចាក់សោភ្ជាប់នៅនឹងថ្មដែលមានសាយូរភ្ជាប់នឹងថ្មហ្នឹង ហ្នឹងក្នុងមួយបន្ទប់ម្នាក់ៗដាក់អ៊ីចឹងទាំងអស់ ។

សៈ ចុះតើអ្នកទោសហ្នឹងគេដាក់ខ្នោះហ្នឹងជាប្រចាំរហូត ឬក៏យ៉ាងម៉េច?

ឆៃ៖ ដាក់ប្រចាំថ្ងៃរហូត ។

សៈ ចុះបើអ្នកទោសត្រូវដាក់ប្រចាំថ្ងៃរហូតអ៊ីចឹង តើគេបត់ដៃ បត់ជើង ឬក៏ងូតទឹកអីយ៉ាងម៉េចដែរ?

ឆៃ៖ ពេលបត់ជើងមានឡាំងមួយនៅក្នុងហ្នឹងសម្រាប់ទុកឲ្យបត់ ។ ដល់ពេលងូតទឹកទាញទុយោមកបាញ់ពីខាងក្រៅចូលទៅក្នុងបន្ទប់ហ្នឹងទៅឲ្យអ្នកទោសគាត់ងូតទឹកទៅ ។

សៈ ចុះពេលងូតទឹកហើយ តើគាត់ផ្លាស់សម្លៀកបំពាក់យ៉ាងម៉េចដែរ? ហើយសម្លៀកបំពាក់ហ្នឹងមានផ្លាស់ប្តូរ ឬក៏គាត់ស្លៀកអាទទឹកអ៊ីចឹងរហូតទៅ?

ឆៃ៖ ពេលងូតទឹកសម្លៀកបំពាក់របស់គាត់ដូរ ដាក់អាថ្មីចូលទៅ យកអាចាស់ហ្នឹងចេញមកយកឲ្យគេយកទៅគក់ទៅ ។

សៈ ប្តូរ តើលោកដឹងទេ តើប្តូរសម្លៀកបំពាក់យ៉ាងម៉េចទៅបើជើងគាត់ជាប់ខ្នោះជាប់ជាប្រចាំអ៊ីចឹង?

ឆៃ៖ ដល់ពេលប្តូរអ៊ីចឹងទៅ ជើងជាប់ខ្នោះចេះតែសកទាញបន្តិចៗៗៗ គាត់អង្គុយទាញអ៊ីចឹងជើងម្ខាងចេះទាញៗជើងខោទៅ តាមកន្លែងប្រឡោះកងហ្នឹងទៅ យូរៗបានស្លៀកបានហើយ ។

សៈ តើកន្លែងឃុំខ្លួនដែលលោកទទួលយាមកាមហ្នឹងមានអ្នកទោសជាស្ត្រីដែរឬទេ?

ឆៃ៖ មុខសញ្ញាខ្ញុំអត់មានទេ ។

សៈ អ៊ីចឹងតើលោកអាចដឹងទេ តើអ្នកទោសស្ត្រីនៅពេលដែលគេងូតទឹកអីហ្នឹង ស្ថានភាពដូចអ្នកទោសបុរសដែលលោករៀបរាប់អម្បាញ់មិញដែរឬទេ?

ឆៃ៖ ខ្ញុំអត់ដែលឃើញអ្នកទោសស្រីងូតទឹកផង អ្នកនៅក្នុងបន្ទប់តូចៗហ្នឹងគឺអត់មានបានឃើញទេ ។

សៈ ចុះការហូបចុករបស់អ្នកទោស តើអ្នកទោសគេឲ្យហូបគ្រប់គ្រាន់ដែរឬទេ? ហើយហូបអីទៅ?

ឆៃ៖ អ្នកទោសហូបមិនគ្រប់គ្រាន់ទេ ហូបបបរអីចឹងទៅ មួយកាហ្នឹងអត់ពេញកាទេ ហើយសម្ពមួយកួនចាន ។

សៈ លោកអះអាងថា មួយកា បបរគេដួសយកកាហ្នឹងទៅឲ្យអ្នកទោសតែម្តង ឬក៏គេយកកាហ្នឹងវ៉ាល់ដួសចាក់ទៅក្នុងចានឲ្យអ្នកទោស?

ឆៃ៖ យកកាហ្នឹងដួស ហើយចាក់ដាក់ក្នុងចាន ហើយបានឲ្យអ្នកទោសហូប ។

សៈ គឺលោកអះអាងអំមិញ្ញថា លោកបានដើរមើលអ្នកទោស ត្រួតពិនិត្យមើលអ្នកទោស ហើយលោកធ្លាប់ឃើញថា មានការស្តាកស្មាមក្រោយពីយកទៅសួរចម្លើយ ហើយតើថាពេលដែលសួរចម្លើយហ្នឹងលោកសង្កេតឃើញថាអ្នកទោសយ៉ាងម៉េចដែរ រងរបួសធ្ងន់ធ្ងរ ឬក៏របួសនោះយ៉ាងម៉េច? ហើយអាចតើរបួសនោះ រងរបួសដោយសារអ្វី?

ឆៃ៖ អ្នកទោសរងរបួសនោះដោយសារអ្វីខ្ញុំមិនដឹងដែរ ។ ប៉ុន្តែមកវិញឃើញកន្ទួលកណ្តាលខ្នងតែមិនដឹងយកអ្វីទៅវ៉ៃ ហើយខ្លះទៀតក៏របួសចាស់មកពីមុនមក អីចឹងមានស្នាមធំៗកណ្តាលខ្នងហ្នឹងទៅ ។ តែដឹងគេធ្វើទារុណកម្មរបៀបម៉េចៗខ្ញុំអត់បានដឹងដែរទេ ។

សៈ លោកមានដែលបានដឹងទេអំពីការដែលអ្នកទោសត្រូវគេដកក្រចក ឬក៏ចងជ្រមុជទឹកនោះ?

ឆៃ៖ ហ្នឹងក៏ខ្ញុំអត់ដឹង ។

សៈ នៅកន្លែងដែលលោកយាមកាមនៅក្នុងបរិវេណខាងក្នុងមន្ទីរស-២១ ហ្នឹងតើមានកន្លែងសួរចម្លើយក្នុងហ្នឹងដែរឬទេ?

ឆៃ៖ តាមខ្ញុំសម្គាល់មើលអត់មាន ។

សៈ អីចឹងតើអ្នកទោសហ្នឹងដែលគេយកទៅសួរចម្លើយនៅឯណាទៅ?

ឆៃ៖ អ្នកទោសហ្នឹងគេយកទៅសួរចម្លើយនៅខាងកើតមន្ទីរឃុំឃាំងហ្នឹង ។

សៈ ខាងកើត ខាងក្នុងហ្នឹង ឬក៏ខាងក្រៅ?

ឆៃ៖ ខាងក្រៅ ។

[០៩:១៨:៤៥]

សៈ នៅក្នុងការដែលនាំអ្នកទោសយកទៅសួរចម្លើយ តើអ្នកណាជាអ្នកនាំយកទៅ ខាងកងការពារ ឬក៏ខាងក្រុមអ្នកសួរចម្លើយ?

ឆៃ៖ ខាងកងសួរចម្លើយគេនាំយកទៅ ។ កងការពារខាងក្នុងហ្នឹង មានអ្នកចល័តហ្នឹងគេចាក់យកទៅឲ្យកងសួរចម្លើយយកទៅ ។

សៈ អ៊ីចឹងបានន័យថា កងការពារហ្នឹងមានអ្នកចល័ត មានអ្នកយាមជាប់ប្រចាំ អ៊ីចឹងមែនទេ?

ឆៃ៖ បាទ ។

សៈ លោកមានធ្លាប់ដែលបានឃើញគេសួរចម្លើយអ្នកទោសដែរឬទេ?

ឆៃ៖ ខ្ញុំមិនដែលបានឃើញទេ ។

[០៩:២០:០៦]

សៈ ក្នុងការដែលលោកយាមហ្នឹង តើគេមានដាក់បទវិន័យអីខ្លះទៅដល់លោក? និយាយឲ្យចំក្រុមកងការពារទាំងអស់ហ្នឹង តើមានវិធានការយ៉ាងម៉េចៗ ប្រសិនបើត្រូវយាមឲ្យបានជិតដល់យ៉ាងម៉េច? ហើយប្រសិនបើមានការធ្លោះធ្លាយអ្នកទោសរត់រួច ឬក៏ធ្វើអ្វីៗ តើគេមានវិធានការយ៉ាងម៉េចចំពោះអ្នកយាមទាំងនោះ?

ឆៃ៖ ពេលយាមការពារហ្នឹង ពេលបើកអង្គប្រជុំឃើញថា ថ្នាក់លើបានដាក់វិន័យឲ្យថា ឲ្យកងការពារហ្នឹងខំការពារឲ្យបាន កុំឲ្យអ្នកទោសធ្វើសកម្មភាពហ្នឹងរត់រួចឲ្យសោះ ។ កាលណាអ្នកទោសធ្វើសកម្មភាពរត់រួចបាន អាហ្នឹងទទួលទោសរបស់ខ្លួនឯង ។

សៈ តើអ្នកណា ជាអ្នកដឹកនាំការប្រជុំនោះ?

ឆៃ៖ ហ្នឹងកងរយ ឈ្មោះ ប៉ែង ។

សៈ លោកមានដែល-- លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច នេះ មានដែលចូលរួមធ្លាប់ទៅប្រជុំប្រាប់ពីវិន័យអី ដល់ក្រុមកងការពាររបស់លោកដែរឬទេ?

ឆៃ៖ គាត់មិនដែលមកផង មានតែកងរយ ឈ្មោះ ប៉ែង ហ្នឹង ដែលណែនាំ ។

សៈ អ៊ីចឹងនៅក្នុងអំឡុងពេលដែលលោកយាម លោកដែលឃើញជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច នេះ ដើរត្រួតពិនិត្យមើលមន្ទីរឃុំឃាំងហ្នឹងដែរឬទេ? កន្លែងឃុំខ្លួន ។

ឆៃ៖ ឃ្យរៗ គាត់មកម្តង ក៏ប៉ុន្តែគាត់អត់ចូលដែរ គាត់មើលតែពីខាងក្រៅទៅទេ ។

សៈ ចុះលោកធ្លាប់ដែលឃើញគាត់ សួរចម្លើយអ្នកទោសដែរឬទេ?

ឆៃ៖ ខ្ញុំមិនដែលឃើញគាត់សួរចម្លើយអ្នកទោសទេ ។

សៈ ចុះអំពីការធ្វើទារុណកម្ម លោកដឹងទេ? តើជនជាប់ចោទធ្លាប់បានចូលរួមសួរ ឬក៏ធ្វើទារុណកម្មទៅអ្នកទោសដែរ? វាយ ឬក៏ទាត់ធាក់អីទៅលើអ្នកទោសដែរឬទេ?

ឆៈ ហ្នឹងចំណុចនេះ ក៏ខ្ញុំមិនដែលឃើញដែរ ។

សៈ តើលោកដឹងទេ ថាតើក្នុងការចាត់ចែងឃុំខ្លួនអ្នកទោស ឬក៏បញ្ជេញអ្នកទោសទៅឲ្យកងសួរចម្លើយ យកទៅសួរចម្លើយ ហើយយកត្រឡប់មកវិញហ្នឹង តើអ្នកណាជាអ្នកបញ្ជា?

[០៩:២៣:២៥]

ឆៈ ការឃុំឃាំង យកចេញ យកចូល ហ្នឹងនៅលើកងរយ គាត់ចាត់ចែង ។

សៈ ចង់ដឹងថាតើមានពីណាទៀត បញ្ជាទៅលើកងរយហ្នឹង ឲ្យអនុវត្តការយកចេញ យកចូល យកទៅដាក់ឃុំហ្នឹង?

ឆៈ ហ្នឹងក៏ខ្ញុំអត់ដឹងដែរ ។

សៈ តើលោកដឹងឬទេ? ក្រោយពីសួរចម្លើយរួចរាល់ហើយ តើលោកដែល គេធ្លាប់ដោះលែងអ្នកទោសចេញទៅដែរ ពេលដែលគេសួរចម្លើយរួច?

ឆៈ ពេលសួរចម្លើយអ្នកទោសរួចហើយ ដោះលែង ឬក៏មិនដោះ ក៏ខ្ញុំអត់បានដឹងដែរទេ ។

សៈ តើលោកដឹងទេថា អ្នកដែលត្រូវសួរចម្លើយហើយហ្នឹង គេដឹកយកទៅណា? នាំយកទៅណាដែរឬទេ?

ឆៈ អ្នកសួរចម្លើយហើយហ្នឹង ខ្ញុំក៏មិនដឹងដឹកទៅណាទេ ប៉ុន្តែគ្រាន់តែឃើញចេញពីបន្ទប់ទៅ មិនដឹងយកទៅណា វាបាត់ចេញពីបន្ទប់ទៅអត់ឃើញមកវិញ ។

សៈ នៅពេលដែលគេដឹកចេញពីបន្ទប់ន៉ុង របៀបគេដឹកហ្នឹងយ៉ាងម៉េច? គេដាក់ខ្នោះចងដៃ ឬក៏ចងមុខអីយ៉ាងម៉េចដែរ?

ឆៈ គេដាក់ខ្នោះដៃព័ទ្ធទៅក្រោយ ហើយចងមុខ ហើយបណ្តើរចេញយកទៅ ។

សៈ ហើយលោកធ្លាប់បានឃើញគេសម្លាប់អ្នកទោសទៅក្នុងមន្ទីរស-២១ ហ្នឹង ដែរឬទេ?

ឆៈ ខ្ញុំមិនដែលឃើញទេ ។

សៈ នៅពេលដែលអ្នកទោសរងរបួសអំពីការធ្វើទារុណកម្មហ្នឹង តើមានការព្យាបាលអីដែរ?

ឆៈ អ្នកទោសដែលត្រូវទារុណកម្ម មានរបួសស្នាកស្នាមអី មានពេទ្យព្យាបាល ។

សៈ អ៊ីចឹងលោកដឹងទេថា តើនៅមន្ទីរ ស-២១ ហ្នឹង មានពេទ្យប៉ុន្មាននាក់ទៅ?

ឆេ៖ ហ្នឹងក៏ខ្ញុំអត់ដឹង មានពេទ្យប៉ុន្មាននាក់ដែរ ។

សៈ តាមការដែលលោកធ្លាប់ឃើញ គេព្យាបាលអ្នកទោស លោកៗថាអះអាងថា អម្បាញ់មិញនេះ ថាអ្នកទោសដែលមានរងរបួសហ្នឹង មានការព្យាបាល ។ អ៊ីចឹង បានន័យថា មានពេទ្យ ហើយលោកធ្លាប់ឃើញពេទ្យនុង មកព្យាបាលអ្នកទោសដល់កន្លែងឃុំឃាំង ឬក៏គេដឹកយកទៅព្យាបាលឯណា?

[០៩:២៧:០១]

ឆេ៖ ពេទ្យមកព្យាបាល ដល់កន្លែងអ្នកទោសនៅហ្នឹងហ្អង ។

សៈ តើពេទ្យមកម្តង ប៉ុន្មាននាក់ទៅ? ហើយក្នុងនោះ មានពេទ្យស្រីដែរឬទេ?

ឆេ៖ ខ្ញុំឃើញតែម្នាក់ ពេទ្យប្រុស ។

សៈ ក្នុងចំណោមថ្នាក់ដឹកនាំនៅមន្ទីរស-២១ ក្រៅពីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ហើយមេកងរយឈ្មោះ ប៉ែង អីហ្នឹង ដែលលោកវៀបរាប់ខ្លះហើយហ្នឹង តើលោកមានស្គាល់អ្នកណាផ្សេងពីហ្នឹងទៀតដែរឬទេ?

ឆេ៖ បន្ទាប់ពីហ្នឹងមកឃើញថាស្គាល់កងការពារប្រហែលបួននាក់នៅរស់បច្ចុប្បន្នហ្នឹង ។ មួយឈ្មោះ គ័ន, មួយឈ្មោះ ហេង, មួយទៀតឈ្មោះ ថន, មួយទៀតឈ្មោះ ជឿន សព្វថ្ងៃគាត់រស់នៅដែរ ។

សៈ សំណួរខ្ញុំ ចង់ដឹងថាថ្នាក់ដឹកនាំនៅមន្ទីរស-២១ ដូចជា អនុប្រធានស-២១ ឬក៏ប្រធានក្រុមសួរចម្លើយផ្សេងៗទៀតហ្នឹង តើលោកមានស្គាល់អ្នកណាខ្លះដែរ?

ឆេ៖ ចុះពីជនជាប់ចោទមក មានតែស្គាល់ បងហ៊ី ហើយ បងហ៊ុយ ហើយ បងប៉ែង ហើយបងហ៊ុយ តូច ។

សៈ ហ៊ុយ តូច ហ្នឹង ឈ្មោះពេញនេះ ឈ្មោះអីទៅ?

ឆេ៖ ហ៊ុយ តូច ឈ្មោះគាត់ ហ៊ឹម ហ៊ុយ ។

សៈ ចុះ ហ៊ុយ ធំ នុំង ឈ្មោះអីវិញ?

សៈ ហ្នឹងក៏ខ្ញុំអត់ស្គាល់នាមរបស់គាត់ ស្គាល់តែខ្លួនគាត់ផ្ទាល់ហ្អង ។ ឈ្មោះខ្លួនគាត់ផ្ទាល់ហ៊ុយ ហ្នឹងផ្ទាល់ហ្អង ។

សៈ ក្នុងអំឡុងពេលដែលលោកធ្វើការនៅមន្ទីរស-២១ហ្នឹង តើលោកធ្លាប់ឃើញគេចាប់ខ្លួនបុគ្គលិកមន្ទីរ ស-២១ ហ្នឹងផ្ទាល់ដែរឬទេ?

ឆៃ៖ បុគ្គលិក ស-២១ ហ្នឹងបាត់ខ្លួន ក៏ខ្ញុំមិនដែលឃើញផ្ទាល់នឹងភ្នែកដែរ គេចាប់ ។

សៃ៖ លោកអះអាងថា មិនបានឃើញផ្ទាល់ភ្នែក ប៉ុន្តែលោកដឹងទេ ថាគេមានការចាប់ខ្លួនបុគ្គលិក ស-២១ ហ្នឹង?

ឆៃ៖ ឃើញថា នៅក្នុងស-២១ហ្នឹង បើខ្ញុំពិនិត្យមើលទៅឃើញថានៅក្នុងក្រុមរបស់ខ្ញុំ ឃើញថាចាប់អស់ពីរនាក់ដែរ ប្រធានក្រុម ហើយនិងអនុក្រុម ។

[០៩:៣០:៤៩]

សៃ៖ តើពួកគេនុង បានប្រព្រឹត្តកំហុសអីទៅ បានជាឈានដល់ការចាប់ខ្លួន?

ឆៃ៖ បាទ, ខ្ញុំពិនិត្យសង្កេតមើលទៅ ឃើញថាពីរនាក់គាត់បំពេញការងារមិនបាន ការយាមល្បាតអី វាមានការងក់ងុយ ។ ម្ល៉ោះហើយធ្វើការបំពេញការងារហ្នឹងមិនបានសម្រេច ទើបគេចាប់ខ្លួនទៅ ។

ឆៃ៖ ចុះលោកដឹងដែរ ថាគេចាប់ខ្លួនគាត់ហ្នឹងយកទៅណា?

ឆៃ៖ ចាប់ខ្លួនគាត់ហ្នឹង ក៏ខ្ញុំអត់បានដឹងដែរ ។

សៃ៖ ចុះលោកមានបានដឹងទេអំពីការចាប់ខ្លួនហើយនិងការសម្លាប់ជនជាតិបរទេស បស្ចិមប្រទេស លោកមានធ្លាប់បានឃើញដែរឬទេ?

ឆៃ៖ ខ្ញុំអត់មានបានឃើញទេ កន្លែងហ្នឹង ។

សៃ៖ នៅក្នុងអំឡុងពេលដែលលោកធ្វើការនៅមន្ទីរស-២១ ហ្នឹង តើគេមានដែលអនុញ្ញាតលោកទៅលែងបងប្អូន និយាយចំលេងផ្ទះ ទៅលេងក្រុមគ្រួសារដែរឬទេ?

ឆៃ៖ ហ្នឹងក៏អត់ ។

សៃ៖ អ៊ីចឹង លោកធ្វើការនៅមន្ទីរ ស-២១ រហូតដល់ពេលណា?

ឆៃ៖ ខ្ញុំធ្វើការនៅស-២១ នៅរហូតដល់ជិតកន្លែងរំដោះ៧មករា ហ្នឹងបានខ្ញុំចេញទៅស្រែហ្នឹង។

សៃ៖ លោកចេញទៅស្រែហ្នឹង ចេញទៅយ៉ាងម៉េច? ទៅធ្វើស្រែ ឬមួយគេ-- លោកប្រព្រឹត្តកំហុសអី គេឲ្យទៅលត់ដំ?

ឆៃ៖ ខ្ញុំទៅហ្នឹង អត់មានខុសឆ្គងអីទេ ។ គ្រាន់តែដូចថា គាត់ចាត់តាំងទាំងអស់ហ្នឹង ព្រោះការងារនៅក្នុងមន្ទីរហ្នឹងរៀងស្បើយបន្តិចទៅ គាត់ចាត់តាំងឲ្យទៅជួយធ្វើស្រែ ធ្វើចម្ការនៅស្រុកស្រែហ្នឹង ជួយស្នងស្រូវ ស្នងអីនៅ ស-២១ ស្រែហ្នឹង ។

សៈ ក្នុងការធ្វើស្រែហ្នឹង ទៅរៀងរាល់ឆ្នាំឬទេ?

ឆៈ តាំងពីខ្ញុំមកនៅស-២១ ទៅជួយធ្វើស្រែគេហ្នឹង បានពីរដង ។

សៈ ហើយចុះលោកមានដឹងទេ ដែលថាការជិតបែក៧មករាហ្នឹង តើលោកដឹងទេ ថាកាលគេមានដឹកអ្នកទោសយកទៅណាជាទ្រុងទ្រាយធំដែរឬទេ?

ឆៈ ហ្នឹងក៏ខ្ញុំអត់បានដឹងដែរ ។

សៈ ចុះលោកស្គាល់ជើងឯកដែរ?

ឆៈ ខ្ញុំឮស្រែគេថាជើងឯកៗ តែមិនដែលបានទៅស្គាល់ផង ។

[០៩:៣៥:០០]

សៈ លោកឮស្រែថា គេថាជើងឯកៗ លោកឮស្រែយ៉ាងម៉េច? ឮស្រែថាគេដឹងដែរ ថាគេមានយកមន្ទីរស-២១ មានយកមនុស្សទៅ អ្នកទោសយកទៅសម្លាប់នៅជើងឯកនោះ តើលោកមានដឹងដែរពីករណីនេះ?

ឆៈ ករណីយកអ្នកទោសទៅសម្លាប់នៅជើងឯកហ្នឹង អាហ្នឹងក៏ខ្ញុំអត់ដឹង ។ ខ្ញុំគ្រាន់តែស្គាល់ថាជើងឯកៗ បឹងជើងឯកហ្នឹង ស្គាល់តែអ៊ីចឹង ត្រង់គេដឹកអ្នកទោសទៅសម្លាប់ហ្នឹង ក៏ខ្ញុំអត់ដឹងដែរ ។

ចៅក្រម ធូ មណី៖

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ ។

ប្រធានអង្គជំនុំ៖

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីសួរដល់សាក្សីរូបនេះដែរឬទេ?

សូមអញ្ជើញលោកស្រីចៅក្រម។

សួរដោយចៅក្រម ស៊ីលយ៉ា ខាតរ៉ាយថ៍៖

សូមអរគុណលោកប្រធាន។

សៈ លោក គក ស្រស់ លោកបាននិយាយជាមួយនឹងអ្នកនិពន្ធសៀវភៅម្នាក់ដែលសរសេរសៀវភៅ សំឡេងពីស-២១ អ្នកនិពន្ធនោះឈ្មោះ លោក ដេវីដ ឆេនដ៍លែ តើលោកបានចាំនូវពេលដែលលោកបាននិយាយជាមួយនឹងអ្នកនិពន្ធនោះដែរឬទេ?

ឆៈ យូរឆ្នាំមកហើយ កន្លែងហ្នឹងខ្ញុំភ្លេចភ្លាំងហើយ ។

សៈ ខ្ញុំមានសំណួរមួយចំនួនសុំសួរលោក អំពីការសម្ភាសន៍ និងឆ្លើយរបស់លោកជូនលោក ដេវីដ ឆេនដ៍លរ។ ហើយលោកអាចជម្រាបខ្ញុំនៅពេលណាមួយប្រសិនបើលោកមិនយល់ស្របទៅនឹងចម្លើយទាំងឡាយដែលលោកបានផ្តល់ជូនលោកនោះ ។ ប៉ុន្តែជាដំបូង តើលោកនៅចាំថាបានធ្លាប់ជួបបុរសម្នាក់ ឈ្មោះ ដេវីដ ឆេនដ៍លរ ដែរឬទេ?

ឆៈ ពីមុនមកខ្ញុំធ្លាប់ជួបដែរ ប៉ុន្តែខ្ញុំអត់ស្គាល់មិនដឹងជាអ្នកណាអ្នកណី ។

សៈ គឺបុរសម្នាក់ដែលនិយាយភាសាអង់គ្លេស ហើយលោកជួបនឹងប្រហែលជាដប់ឆ្នាំទៅមុន តើលោកនៅចាំទេ?

[០៩:៣៧:៥០]

ឆៈ ពិតប្រាកដមែន ។

សៈ សូមអរគុណ ។ ជាដំបូង សៀវភៅដែលខ្ញុំនិយាយអំពីនេះ គឺ“សំឡេងចេញពីមន្ទីរស-២១” ភាពភ័យខ្លាច និងប្រវត្តិសាស្ត្រនៅក្នុងគុកសម្ងាត់របស់ ប៉ុល ពត គឺមានលេខ ERN ជាភាសាអង់គ្លេស 00192667 រហូតដល់លេខ 00192932 គឺឯកសារ D91/I ជាដំបូងនៅក្នុង ERN00192712 នៅក្នុងនោះ គឺលោកបាននិយាយអំពីអាយុរបស់អ្នកយាមនៅស-២១ តើវាជាការត្រឹមត្រូវដែរឬទេដែលលោកបាននិយាយជាមួយបុរសនោះថា នៅពេលនោះលោកមានអាយុ២៥ នៅពេលដែលលោកចូលមកក្នុងគុកស-២១ ។ ប៉ុន្តែ អ្នកយាមភាគច្រើនដែលបានចាប់ផ្តើមធ្វើការងារនៅក្នុងពាក់កណ្តាលឆ្នាំ១៩៧៧ អ្នកទាំងអស់នោះ គឺមានវ័យក្មេងជាងអាយុដែលលោកបានលើកឡើងនោះ? ថាតើលោកបានចាំទៅលើចំណុចនេះដែរឬទេ?

ឆៈ កន្លែងហ្នឹងខ្ញុំអត់បានចាំទេ ភ្លេចអស់ហើយ ។

សៈ តើលោកចាំអំពីអាយុរបស់អ្នកយាមដែលធ្វើការនៅស-២១ ដែរឬទេ? ថាតើអ្នកទាំងអស់នោះគាត់មានវ័យស្មើនឹងលោក ឬក៏មានវ័យក្មេងជាងលោក នៅពេលដែលពួកគេមកធ្វើការនៅស-២១?

ឆៈ ហ្នឹង តាមខ្ញុំសម្គាល់មើលមានចាស់ជាងខ្ញុំ មានក្មេងជាងខ្ញុំ ហ្នឹងពិនិត្យមើលទៅឃើញអ៊ីចឹង។

សៈ តើលោកអាចជម្រាបខ្ញុំបានដែរឬទេ? ថាតើអ្នកយាមក្មេងជាងគេបំផុតនោះមានអាយុប៉ុន្មាន? គេមានអាយុ២០ឆ្នាំ ឬក៏ក្មេងជាងហ្នឹង?

ឆៈ តាមក្មេងដែលរស់នៅជាមួយនឹងក្រុមរបស់ខ្ញុំហ្នឹង ឃើញក្មេងជាងគេហ្នឹងអាយុប្រហែលជា១៥ឆ្នាំទេ ហ្នឹងក្មេងជាងគេហើយ ។

សៈ ចាតើមានកូនក្មេងដែលមានវ័យ១៥ឆ្នាំហ្នឹងដែរឬទេ ធ្វើការនៅស-២១ហ្នឹង មានច្រើនដែរឬទេ?

ឆៈ មានតិចតួចណាស់នៅក្នុងកន្លែងស-២១ហ្នឹង ឃើញកុមារមាននៅកន្លែងខ្ញុំប្រហែលជាបីនាក់ទេ ក្រៅពីហ្នឹងសុទ្ធតែធំៗ។

សៈ បានន័យថា វាក៏អាចមានក្មេងៗដែលមានវ័យប្រហែលហ្នឹងដែរនៅក្រុមផ្សេង ប៉ុន្តែលោកអត់បានដឹង តើត្រឹមត្រូវដែរឬទេ?

[០៩:៤១:៤៧]

ឆៈ ត្រឹមត្រូវហើយ។

សៈ នៅក្នុងសៀវភៅរបស់បុរសនោះ អ្នកនិពន្ធនោះក៏បាននិយាយអំពីករណីដែលគាត់និយាយជាមួយលោកអំពីអ្នកទោសសំខាន់ៗនៅស-២១ ។ អ្នកនិពន្ធនោះបាននិយាយថា លោកប្រាប់គាត់ថា អ្នកទាំងអស់នោះ គឺទទួលបានការប្រព្រឹត្តិលើពួកគេពិសេស តើលោកចាំលើចំណុចនេះដែរឬទេ?

ឆៈ កន្លែងហ្នឹងក៏ខ្ញុំអត់ចាំដែរ។

សៈ នៅក្នុងERN អង់គ្លេស 00192716 នៅក្នុងហ្នឹងអ្នកនិពន្ធបាននិយាយថា លោកបានប្រាប់គាត់ថា “ពួកគេគេងនៅលើត្រែ ហើយអ្នកនុ៎ងគឺមានអាហារដូចនឹងបុគ្គលិកនៅស-២១ដែរ” តើលោកចាំទៅលើចំណុចនេះដែរឬទេ? ដែលលោកបាននិយាយប្រាប់គាត់?

ឆៈ កន្លែងនេះក៏ខ្ញុំមិនបានចាំដែរភ្លេចអស់ហើយ ព្រោះរយៈពេលយូរពេកទៅ ។

សៈ តើលោកចាំថាបានប្រាប់អ្នកនិពន្ធនោះថា “បន្ទាប់ពីអ្នកទាំងអស់នោះត្រូវបានគេសួរចម្លើយ និងធ្វើទារុណកម្ម ពួកគេងូតទឹក ហើយមានពេទ្យទៅព្យាបាលអ្នកទាំងអស់នោះ” តើលោកចាំទៅលើចំណុចនេះដែរឬទេ?

ឆៈ កន្លែងហ្នឹងចាំ ។

សៈ តើវាត្រឹមត្រូវថា ចំណុចនេះលោកបានប្រាប់ទៅអ្នកនិពន្ធនោះដែរឬទេ?

ឆៈ ហ្នឹងខ្ញុំបាននិយាយប្រាប់គាត់អ៊ីចឹងមែន ។

សៈ លោកបានចំណាយពេលធ្វើការងារយូរនៅស-២១ ហើយលោកបានឃើញនូវអ្វីដែលបានកើតឡើងច្រើននៅក្នុងមន្ទីរនោះ តើត្រឹមត្រូវដែរឬទេ?

ឆៈ កន្លែងហ្នឹងខ្ញុំភ្លេចអស់ដែរហើយ ព្រោះយូរពេក ។

ស៖ ខ្ញុំយល់អំពីចំណុចហ្នឹង ។ ប៉ុន្តែ ខ្ញុំនៅមានចំណុចមួយចំនួនដែលខ្ញុំចង់សួរលោកដោយសារតែលោកបាននិយាយប្រាប់ទៅបុរសឈ្មោះ ដេវីដ ឆេនដ៍ល័រ ។ ចំណុចមួយទៀត គឺនៅក្នុង ERN 00192775 នៅក្នុងនុំងលោក ដេវីដ ឆេនដ៍ល័រ បាននិយាយថា លោកបានប្រាប់គាត់ "លោកបានឃើញអ្នកទោស ដែលអ្នកទោសនោះ គឺសុទ្ធតែឈាមនៅពេលដែលពួកគេបានយកទៅត្រឡប់ទៅបន្ទប់ឃុំឃាំងរបស់ពួកគេបន្ទាប់ពីការសួរចម្លើយ" ។ តើវាជាចម្លើយមួយដែលត្រឹមត្រូវដែរឬទេ លោកបានផ្តល់ឲ្យគាត់?

[០៩:៤៥:៣០]

ឆ៖ នោះត្រឹមត្រូវរបស់ខ្ញុំមុន។

ស៖ ហើយនៅក្នុង 00192821 នៅក្នុងនោះលោកបាននិយាយថា "លោកបានឲ្យសម្រែករបស់មនុស្សក្នុងពេលដែលគេសួរចម្លើយ" តើវាត្រឹមត្រូវដែរឬទេ?

ឆ៖ ហ្នឹងក៏ត្រឹមត្រូវដែរ។

ស៖ លោកបានឲ្យសម្រែកនោះនៅពេលដែលអ្នកទាំងអស់នោះទទួលការសួរចម្លើយ ហើយសម្រែកនោះក៏ឲ្យឡើង លោកបានឲ្យនៅពេលដែលពួកគេមិនគោរពអ្នកយាមផងដែរ តើត្រឹមត្រូវដែរឬទេ?

ឆ៖ ហ្នឹងក៏ខ្ញុំអត់ដឹងដែរកន្លែងហ្នឹង។

ស៖ លោកបានឲ្យសម្រែកនៅពេលដែលមនុស្សទាំងឡាយត្រូវបានគេយកទៅសួរចម្លើយ ។ តើលោកនៅកៀកហ្នឹងកន្លែងគេសួរចម្លើយទេ នៅពេលដែលលោកឲ្យសម្រែកទាំងអស់នោះ?

ឆ៖ ពេលដែលខ្ញុំឲ្យហ្នឹង ខ្ញុំនៅខាងក្នុងដែរ ប៉ុន្តែខ្ញុំនៅកៀនរបង ហើយគេសួរនៅខាងកើតរបងហ្នឹង ប៉ុន្តែខ្ញុំមើលអត់មានឃើញទេ គ្រាន់តែឲ្យសំឡេងទេ ។

ស៖ បុគ្គលមួយទៀតប្រាប់លោក ដាវីដ ឆេនដ៍ល័រ ថា មានសម្រែកច្រើន ជាពិសេសនោះគឺនៅពេលយប់ នៅពេលដែលអត់មានសំឡេងអីផ្សេងនៅក្នុងទីក្រុងភ្នំពេញ សម្រែកនោះខ្លាំងនោះ ហើយអាចឲ្យប្រហែលជាប្រាំមួយរយម៉ែត្រែ ពីកន្លែងហ្នឹង ។ តើលោកចាំទេទៅលើចំណុចដែលគេលើកឡើងដូច្នេះ ។

ឆ៖ ហ្នឹងក៏ខ្ញុំអត់ដឹងដែរ។ ចំណុចហ្នឹង ខ្ញុំអត់ដឹងទេ ។

សៈ នៅក្នុងលេខ ERN00192832 លោកបាននិយាយជាមួយលោក ដេវីដ ឆេនដ៍លរ អំពីការសម្លាប់អ្នកទោស ហើយលោកបានជម្រាបទៅគាត់ថា "ការសម្លាប់ស្ទើរតែទាំងអស់ គឺធ្វើឡើងដោយសម្ងាត់ និងនៅពេលយប់" តើចំណុចនេះលោកចាំថាបាននិយាយជាមួយគាត់ដែរឬទេ?

ឆៈ កន្លែងហ្នឹងក៏ខ្ញុំភ្លេចអស់ហើយ។

សៈ លោកបានជម្រាបគាត់ថា "នៅឆ្នាំ១៩៧៦ អ្នកទោសដែលគេចងមុខគឺត្រូវបានគេវាយហ្នឹងដំបងស្លាប់ដោយប្រើដំបងដែក នៅទីវាលមួយនៅផ្នែកខាងលិចទីតាំងនោះ ។ ហើយពួកគេត្រូវបានកប់នៅក្នុងរណ្តៅ ហើយរណ្តៅនោះមានជម្រៅប្រហែលជាមួយម៉ែត្រកន្លះ" តើលោកចាំទៅលើព្រឹត្តិការណ៍ឬក៏ហេតុការណ៍ទាំងអស់នោះដែរឬទេ?

ឆៈ ហ្នឹងកន្លែងហ្នឹងក៏ខ្ញុំអត់ចាំដែរ ។

សៈ លោកក៏បានជម្រាបទៅគាត់ផងដែរថា "ទោះបីជាការសម្លាប់នោះមិនត្រូវបានគេនិយាយក៏ដោយ ប៉ុន្តែក្លិនខ្មោច គឺវាធុំក្លិនដោយរួមជាមួយទឹកនោមផ្សេងៗ" តើលោកចាំទៅលើចំណុចទាំងអស់នេះដែរឬទេ?

ឆៈ ហ្នឹង កន្លែងហ្នឹងក៏ខ្ញុំចាំមិនច្បាស់ដែរ ។

សៈ លេខERN00192845 លោកបាននិយាយទៅលោក ដេវីដ ឆេនដ៍លរ អំពីអ្នកសួរចម្លើយដែលមិនចង់ប្រើទារុណកម្ម ហើយប្រសិនបើអ្នកទាំងអស់នោះគាត់ស្ទាក់ស្ទើរក្នុងការប្រើទារុណកម្មគឺពួកគេនឹងត្រូវបានគេចាប់ខ្លួន តើលោកចាំទៅលើចំណុចដែលលោកបាននិយាយនេះជាមួយនឹងគាត់ដែរឬទេ?

ឆៈ ចំណុចនេះក៏ខ្ញុំភ្លេចអស់ហើយ អត់បានចាំ ។

សៈ តើលោកចាំថាលោកបានចូលរួមជាមួយនឹងការប្រជុំជីវភាពដែលជនជាប់ចោទនិយាយអំពីការធ្វើទារុណកម្ម ដែលគាត់បានលើកឡើងចំណុចនេះថា "អ្នកទាំងអស់គ្នាត្រូវតែធ្វើយ៉ាងណាកុំឲ្យវាយអ្នកទោស ហើយគឺការដែលអាណិតអាសូរ គឺត្រូវតែមាន ហើយលោកអ្នកត្រូវវាយពួកគេដោយបញ្ហាជាតិ និងបញ្ហាវណ្ណៈ និងដោយសារបញ្ហាអន្តរជាតិផងដែរ" តើលោកចាំទៅលើការប្រជុំជីវភាពដែលជនជាប់ចោទបានលើកចំណុចទាំងអស់នេះដែរឬទេ?

ឆៈ បញ្ហាប្រជុំ ឃើញថា មានតែថ្នាក់លើគាត់ណែនាំថា ឲ្យកងការពារហ្នឹងខំការពារឲ្យបានទៅ កុំឲ្យមានបញ្ហាអ្នកទោសធ្វើសកម្មភាព តែប៉ុណ្ណឹងទេ ។ ត្រង់អ្វីៗទៀត ក៏ខ្ញុំអត់ដឹងដែរ ។

សៈ តើលោកចាំទេថា ជនជាប់ចោទ ឌុច បាននិយាយនៅក្នុងការប្រជុំជីវភាព ដែលថាតើអ្នកទាំងអស់គ្នាត្រូវវែអ្នកទោសយ៉ាងណា? តើលោកចាំទេ?

អៈ នេះក៏ខ្ញុំអត់ដឹងដែរ កន្លែងហ្នឹង ។

ចៅក្រម ស៊ីលយ៉ា ខាតរ៉ាយថ៍ៈ

សូមអរគុណ ។ លោកប្រធាន ខ្ញុំពុំមានសំណួរសម្រាប់សាក្សីរូបនេះទេ ប៉ុន្តែខ្ញុំសូមការអនុញ្ញាតពីលោក ដើម្បីសួរទៅកាន់ជនជាប់ចោទ ទៅលើចំណុចចុងក្រោយ ។

ប្រធានអង្គជំនុំៈ

សូមអញ្ជើញលោកស្រីចៅក្រម ។

[០៩:៥៣:១៩]

ចៅក្រម ស៊ីលយ៉ា ខាតរ៉ាយថ៍ៈ

សូមអរគុណ ។ លោក កាំង ហ្គេកអ៊ាវ តើលោកចង់ឲ្យខ្ញុំនិយាយទៅលើចម្លើយដែលបានគេកត់នៅក្នុងសៀវភៅរបស់លោក ដេវីដ ឆេនដ៍លែរ ដែលទើបតែខ្ញុំអានអម្បាញ់មិញជូនសាក្សីដែរឬទេ?

ជនជាប់ចោទៈ

ជម្រាបប្រសាសន៍លោកជំទាវ! សៀវភៅ ដេវីដ ឆេនដ៍លែរ នេះ ខ្ញុំបានអានជាភាសាបារាំង ក៏ប៉ុន្តែខ្ញុំភ្លេចអស់ទៅហើយ បើលោកជំទាវរំឭកទៀត ខ្ញុំសូមអរគុណ ។

ចៅក្រម ស៊ីលយ៉ា ខាតរ៉ាយថ៍ៈ

នេះគឺជាចម្លើយដែលវាទាក់ទងទៅនឹងលោក គឺវាទាក់ទងទៅនឹងការដែលគេដកស្រង់ពីឯកសារ ស-២១ គឺចុះថ្ងៃទី១៨ មេសា ឆ្នាំ១៩៧៦ ខ្ញុំអត់មានERNទេ ប៉ុន្តែខ្ញុំអានជាភាសារង់គ្លេសឲ្យលោកស្តាប់ នេះគឺជាចម្លើយដែលត្រូវបានគេកត់ត្រានៅក្នុងនុ៎ង “លោកអ្នកទាំងអស់គ្នាត្រូវដឹងថា ការវាយអ្នកទោសគឺធ្វើយ៉ាងណាឲ្យវាមានលក្ខណៈសាហាវ គឺមិនត្រូវមានការអាណិតអាសូរនៅក្នុងករណីទាំងអស់នេះទេ ។ អ្នកទាំងអស់គ្នាត្រូវតែវាយអ្នកទាំងអស់នោះ ដោយមូលហេតុជាតិ ដោយមូលហេតុវណ្ណៈ និងមូលហេតុអន្តរជាតិ” ។

ខ្ញុំចង់សួរលោកថា តើលោកទទួលស្គាល់ថាលោកបាននិយាយអំពីចំណុចទាំងអស់នេះ ដូចហ្នឹងដែរឬទេ?

ជនជាប់ចោទ៖

ជម្រាបប្រសាសន៍លោកជំទាវ! ឯកសារថ្ងៃ១៨ មេសា ១៩៧៦ ដែលលោកជំទាវមានប្រសាសន៍នេះ ខ្ញុំជឿថា ឃ្លាតអំពីន័យដើមដែលខ្ញុំបង្រៀន ។ ន័យដើមដែលខ្ញុំបង្រៀន ខ្ញុំជឿថានៅលើកំណត់ហេតុមួយ ថ្ងៃ១៣ កុម្ភៈ ១៩៧៦ ដែលខ្ញុំប្រជុំជីវភាព ដឹកនាំប្រជុំជីវភាពកម្លាំងក្រុង កម្លាំងអ្នកតស៊ូក្រុងចាស់ ។ ខ្ញុំនិយាយថា "ជនណាក៏ដោយឲ្យតែអង្គការចាប់មក គឺសុទ្ធតែជាខ្មាំង ។ បើអ្នកឯងមិនកំណត់ថាជាខ្មាំងទេ អ្នកឯងសួរចម្លើយមិនចេញទេ" ។ នេះជាមូលដ្ឋាននៃការណែនាំរបស់ខ្ញុំគ្រប់កម្មាភិបាលសួរចម្លើយ ។ ដល់និយាយថា "វ៉ៃឲ្យសាហាវ" មិនមែនទេ "ដោយបុព្វហេតុជាតិ បុព្វហេតុវណ្ណៈ" អាចពេលខ្លះ ខ្ញុំភ្លាត់និយាយដើម្បីញែកឲ្យខុសអំពីគំនុំផ្ទាល់ បានន័យថា បុគ្គលដែលគេចាប់បញ្ជូលមក ស-២១ មិនមែនជាបុគ្គលដែលមានគំនុំផ្ទាល់ជាមួយនឹងខ្ញុំ មិនមែនជាបុគ្គលដែលមានគំនុំផ្ទាល់ជាមួយអ្នកណាម្នាក់នៅក្នុងស-២១ ទេ ។ ក៏ប៉ុន្តែ អង្គការគេចាប់មកជាសត្រូវរបស់ជាតិ ។ ដូច្នេះ ខ្ញុំអាចភ្លាត់និយាយបញ្ហានេះ ។ ប៉ុន្តែចានិយាយ "ឲ្យវ៉ៃឲ្យសាហាវ" ខ្ញុំជឿថា ខ្ញុំមិនភ្លាត់ ។ សូមអរគុណ សូមបញ្ចប់ប៉ុណ្ណោះ បញ្ចាក់ជូនប៉ុណ្ណោះ ។

[០៩:៥៧:៣៥]

ចៅក្រម ស៊ីលយ៉ា ខាតរ៉ាយថ៍៖

យើងនឹងធ្វើការដេញដោលជាមួយនិងលោក ដេវីដ ឆេនល័រ នៅពេលក្រោយ ។ ប៉ុន្តែ លោកឆ្លើយតបទៅនឹងសៀវភៅរបស់គាត់ គឺជាការ-- គឺប្រព័ន្ធមួយ ដែលមានការពិនិត្យដោយម៉ត់ចត់នៅក្នុងស-២១តើត្រឹមត្រូវដែរឬទេ?

ជនជាប់ចោទ៖

ជម្រាបប្រសាសន៍លោកជំទាវ ។ ខ្ញុំបានឆ្លើយតបជាមួយនឹងអ្នកនិពន្ធ ដេវីដ ឆេនដ៍ល័រ ដោយសរសេរដប់បីទំព័រជាភាសាបារាំង ជូនចៅក្រមស៊ើបអង្កេតរួចហើយ ។ ដូច្នេះ បញ្ហាផ្សេងទៀត នៅពេលដែលលោក ដេវីដ ឆេនដ៍ល័រ លោកអញ្ជើញមកខ្ញុំនឹងជម្រាប ។

ចៅក្រម ស៊ីលយ៉ា ខាតរ៉ាយថ៍៖

សូមអរគុណ ខ្ញុំពុំមានសំណួរផ្សេងទៀតសួរទៅកាន់ជនជាប់ចោទទេ លោកប្រធាន ។ សូមអរគុណ ។

ប្រធានអង្គជំនុំ៖

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖

សូមអរគុណច្រើនលោកប្រធាន ។

ស៖ លោក គក ស្រស់ ខ្ញុំគឺជាចៅក្រម ឡាវែន ខ្ញុំមានសំណួរមួយចំនួនតូច តើលោកដំបូងអាចប្រាប់ខ្ញុំដែរឬទេ ថាតើលោកមានការពិបាកចំពោះការចងចាំរបស់លោក ហើយលោកពិបាកក្នុងការចាំទៅលើព្រឹត្តិការណ៍ និងហេតុការណ៍មួយចំនួន?

ឆ៖ បញ្ហាការចងចាំ ឃើញថាវារយៈពេលយូរពេកទៅ ម្ល៉ោះហើយខ្ញុំវាភ្លេចភ្លាំងអស់ហើយមិនបានចងចាំឲ្យបានអស់នៅក្នុងបញ្ហាហ្នឹងទេ ។

ស៖ តើលោកមិនបានចាំជាក់លាក់ទៅលើអ្វីដែលកើតឡើងនៅស-២១ទេ ឬយ៉ាងម៉េច? ឬក៏និយាយជាទូទៅ លោកមានបញ្ហាទៅហ្នឹងការចងចាំ? ថាតើបញ្ហាការចងចាំនេះ គឺលោកមិនបានចាំទៅលើព្រឹត្តិការណ៍កើតឡើងនៅស-២១ ឬក៏យ៉ាងម៉េច?

ឆ៖ នៅក្នុងព្រឹត្តិការណ៍ដែលចងចាំរបស់ខ្ញុំ ឃើញថាភ្លេចច្រើន ហើយណាមួយក្នុងខ្លួនខ្ញុំ ក៏វាគិតច្រើនទៀត មិនសូវមានគិតគូរអ្វី គិតគូរពីរឿងគ្រួសារប៉ុណ្ណឹងទេ ។

[១០:០០:៤៣]

ស៖ លោកបានឃើញជនជាប់ចោទ វត្តមាននៅក្នុងការសាលសវនាការ តើលោកស្គាល់គាត់ទេ តើលោកចង់ឃើញគាត់ម្តងទៀតឬទេ?

ឆ៖ នៅក្នុងសវនាការនេះ ខ្ញុំស្គាល់គាត់ គាត់ជាអ្នកដឹកនាំនៅក្នុងមន្ទីរស-២១ហ្នឹង ឈ្មោះកាលពេលនៅ ខ្ញុំហៅគាត់ថា តា ហៅគាត់ថា តាឌុចៗ ទេ ។

ស៖ តើកាលនោះ គេធ្លាប់ហៅគាត់ថា បងខាងកើតដែរឬទេ?

ឆ៖ ហ្នឹងក៏ ខ្ញុំមិនធ្លាប់ដែរឮដែរ ។

ស៖ អ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតបានសម្ភាសលោកនៅក្នុងឯកសារD78/10 ហើយលោកបានពន្យល់ថា បន្ទាប់ពីការជម្លៀសទីក្រុងភ្នំពេញរួចហើយ លោកបានធ្វើការនៅកន្លែងមួយដែលលោករៀបរាប់ថា ជាគុកធំមួយ ។ ឥឡូវនេះ លោកមិនរៀបរាប់ពីគុកធំនោះទេ ប៉ុន្តែតើលោកនៅចាំអ្វីដែលលោកនិយាយនោះដែរឬទេ?

ឆេ៖ ហ្នឹង កន្លែងហ្នឹង ក៏ខ្ញុំអត់សូវបានចាំដែរហ្នឹង ភ្លេចច្រើនហើយ ។

សៈ តើលោកមានបញ្ហាលើការចងចាំ ដោយហេតុថា លោកត្រូវបានគេសម្ភាសហ្នឹងរួចហើយ នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៨ តើការចងចាំរបស់លោកច្បាស់ដែរឬទេ នៅថ្ងៃទី៣ ខែមេសា ឆ្នាំ ២០០៨ ហើយមកដល់ពេលនេះ លោកមិនមានការចងចាំល្អ តើអ៊ីចឹងមែនឬទេ? តើលោកមានបញ្ហាការចងចាំពិសេសដែរឬទេបន្ទាប់ពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៨ មកនោះ?

ឆេ៖ អាហ្នឹង ខ្ញុំចាំបានតែបញ្ហាពីព្រឹមថ្ងៃទី៣ ខែមេសា ហ្នឹងមក អាហ្នឹងគឺចាំប៉ុណ្ណឹង ។ ការងារអ្វីៗទៀតឃើញថាភ្លេចអស់ច្រើនហើយ ព្រោះអត់សូវមានការយកចិត្តទុកដាក់នៅលើបញ្ហាអស់ទាំងហ្នឹង ។

សៈ លោក គក ស្រស់ តើលោកមានការភ័យខ្លាចទេថ្ងៃនេះ? ហើយប្រសិនបើមានការភ័យខ្លាច តើលោកភ័យខ្លាចពីរឿងអ្វី ឬក៏លោកខ្លាចអ្នកណា?

ឆេ៖ ថ្ងៃនេះ ខ្ញុំអត់មានភ័យខ្លាចអីទេ ។ ខ្លាចក៏អត់មានខ្លាចអ្នកណាដែរ ។

[១០:០៥:០៦]

សៈ ដូច្នេះ ចំណុចសំខាន់បំផុតរបស់លោកគឺគិតតែពីរឿងក្រុមគ្រួសារ ចិញ្ចឹមគ្រួសារ តើអ៊ីចឹងមែនទេ?

ឆេ៖ ពិតមែនហើយ ។

សៈ ប៉ុន្តែលោកបានដឹងថា ក្នុងឋាន:ជាសាក្សីលោកបានធ្វើការសម្បថ ហើយច្បាប់តម្រូវឲ្យលោកចូលរួមនៅក្នុងការស្វែងរកការពិត តើលោកបានដឹងពីចំណុចនេះទេ?

ឆេ៖ នៅលើបញ្ហាចំណុចនេះ ខ្ញុំបានដឹងទាំងអស់ ។ កាលណាកន្លែងណាខ្ញុំចាំច្បាស់ទៅ ក៏ខ្ញុំបាននិយាយប្រាប់ទៅ កន្លែងណាចាំមិនច្បាស់ហ្នឹង ក៏ខ្ញុំមិនអាចនិយាយប្រាប់បានដែរ ភ្លេចភ្លាំងទៅវាច្រើន ។

សៈ នៅខណ:ពេលនេះ តើលោកនៅចាំឬទេ អ្វីដែលលោកបានរៀបរាប់ថាជាគុកធំ ហៅថា *ប៉ែហ្ស៊ី (PJ)* នោះ ដែលនៅខាងត្បូងផ្សារធំថ្មីនោះ តើលោកនៅចាំថាលោកបានជម្រាបអ្នកស៊ើបអង្កេតថា ឌុច គឺជាប្រធាននៅគុកនោះដែរនោះ?

ឆេ៖ ហ្នឹងខ្ញុំបាន មកនៅហ្នឹងបានតែ មួយថ្ងៃមួយយប់ ហើយក៏អ្នកដឹកនាំហ្នឹង ក៏បញ្ជូនខ្ញុំឲ្យទៅនៅតាឡៅនោះវិញទៅ ហើយអ្នកទទួលខុសត្រូវហ្នឹង តាមមិត្តយើងនៅហ្នឹង គាត់ប្រាប់ ខ្ញុំចេះតែស៊ើបសួរថាចុះអ្នកទទួលខុសត្រូវកន្លែងហ្នឹងឈ្មោះអី? ហើយឮសូរមិត្តយើងនៅហ្នឹង គាត់ថា អ្នកទទួលខុស

ត្រូវនៅហ្នឹងកន្លែង តាឌុច ។ ហ្នឹង គាត់ប្រាប់ខ្ញុំអីចឹង ។

សៈ តើលោកបានឃើញគាត់នៅទីនោះទេ? ឬក៏គ្រាន់តែជាអ្វីដែលលោកនិយាយថា គេប្រាប់លោក? តើនៅគុកនោះមានហេតុការណ៍ដូចម្តេចដែរ?

ឆៈ ខ្ញុំមិនដែលឃើញគាត់ផងទេ គ្រាន់តែបានថា គេអ្នកនៅកន្លែងហ្នឹង គេប្រាប់ប៉ុណ្ណឹងទេ ។

សៈ តើលោកបានឮពីឈ្មោះគាត់ទេ មុនពេលលោកនៅកន្លែងនុះនោះ?

ឆៈ កាលពីមុនពេលខ្ញុំចូលមកកន្លែងហ្នឹង អត់មានដែលឮសូរឈ្មោះគាត់ផងហ្នឹង ។

សៈ លោកបានពន្យល់ថា បន្ទាប់មកលោកបានទៅគុកតាខ្មៅ ហើយលោកក៏បាននិយាយដែរថា អ្នកទោសនៅតៅខ្មៅនោះ ត្រូវបានគេបញ្ជូនទៅគុកកន្លែងកណ្តាលមួយដើម្បីសួរចម្លើយ ។ តើលោកបានឃើញដោយផ្ទាល់ភ្នែក ឬក៏គ្រាន់តែឮពាក្យគេប្រាប់លោកទេ?

[១០:០៨:៥០]

ឆៈ ហ្នឹង ក៏ឮសូរគេប្រាប់ដែរហ្នឹង ។

សៈ លោក គក ស្រស់ តើជាលើកដំបូងដែលលោកបានធ្វើការនៅកន្លែងគេឃុំខ្លួននោះ ក្នុងមួយជីវិតរបស់លោក តើលោកធ្លាប់បានធ្វើការនៅកន្លែងឃុំខ្លួនពីមុនមកទេ?

ឆៈ មួយជីវិតខ្ញុំមិនដែលបានចូលមកធ្វើការនៅកន្លែងមន្ទីរអ្នកទោសអីចឹងទេ ទើបមកបច្ចុប្បន្នកាលជំនាន់ខ្មែរក្រហមហ្នឹងទេ បានអង្គការចាត់តាំងឲ្យមកកន្លែងហ្នឹង ។

សៈ តើនោះជាការងារធម្មតាដែរឬទេតាមគំនិតរបស់លោក? ឬក៏ជាការងារពិសេស? តើវារក្សាឲ្យលោកចងចាំច្បាស់ដែរឬទេ? ឬក៏លោកគិតថា ការងារនោះជាការងារធម្មតាដែលមិនសូវចាំហ្នឹង?

ឆៈ បើតាមខ្ញុំពិនិត្យមើលទៅ ការងារនេះ ខ្ញុំថាការងារជាការធម្មតា ។

សៈ តើលោកអាចបញ្ជាក់បន្ថែមដែរទេ ថាតើការងារនោះវាធម្មតាៗដូចម្តេច?

ឆៈ បានជាខ្ញុំថាការងារធម្មតា ឃើញថានៅកន្លែងណា ក៏ដូចកន្លែងណា ម្ល៉ោះហើយដល់ខ្ញុំមកនៅកន្លែងយាមការពារអ្នកទោសនៅគុកអីចឹងទៅ ដល់ខ្ញុំពិនិត្យខ្លួនខ្ញុំយូរៗឃើញថា ការងារបានខ្ញុំថាធម្មតាអីចឹងទៅបណ្តោយទៅ ។ ព្រោះអានេះទទួលភារកិច្ចរបស់អង្គការចាត់តាំងមកឲ្យការពារអីចឹងការពារបណ្តោយ ។

សៈ លោក គក ស្រស់, ថ្ងៃនេះ ប្រសិនបើគេឲ្យលោកធ្វើការងារធម្មតាដូច្នោះទៀត បើសិនជាគេសុំឲ្យលោកធ្វើអីចឹងម្តងទៀត តើលោកនឹងធ្វើទេ?

ឆៃ៖ ត្រឹមថ្ងៃនេះតទៅមុខ បើមានគេសុំឲ្យខ្ញុំធ្វើការហ្នឹង គឺលែងហើយ រាងហើយ ។

សៃ៖ អ៊ីចឹង ការសម្រែកដែលលោកបានឮហ្នឹង តើជារឿងធម្មតាដែរ ឬក៏ជារឿងមិនធម្មតា? តើមនុស្សដែលស្រែក ឬក៏សម្រែកយំហ្នឹង របស់មនុស្ស និងសត្វហ្នឹងវាខុសគ្នាដូចម្តេច?

ឆៃ៖ សម្រែកដែលស្រែកហ្នឹង មនុស្សយើងស្រែកវាខុសសត្វ សត្វវាស្រែកផ្សេង មនុស្សយើងស្រែកផ្សេង មិនដូចគ្នាទេ ។

សៃ៖ ទាក់ទងទៅនឹងរបួសដែលលោកបានឃើញនៅលើអ្នកទោស តើរាងកាយរបស់មនុស្ស ឬក៏រាងកាយអ្នកណា? ក្តិនដែលលោកបានធុំក្តិននោះ តើជាក្តិនអ្វីដែលលោកកត់សម្គាល់បាន?

ឆៃ៖ ធម្មតាអ្នករបួសនោះរាងកាយជាមនុស្សហើយ តែក្តិនធុំក្តិនមិនដឹងជាក្តិនអីទៅវិញទេ ធុំក្តិនតែស្អុយអ៊ីចឹងៗ ខ្ញុំអត់ដឹងថាក្តិនវាទៅរបៀបសត្វ ទៅជារបៀបមនុស្សម៉េច ខ្ញុំអត់ដែលដឹងដែរ ។

[១០:១៣:៣១]

សៃ៖ តើលោកនៅចងចាំពីក្តិននៅពេលនោះ ពេលនេះ? តើលោកធុំក្តិនអ្វីនៅកាលនោះ ឬក៏ការធុំក្តិនសាកសពដែលស្អុយដូចដែលលោកបានប្រាប់ពីខាងដើមនោះទេ? តើជាក្តិនអ្វីដែលលោកបានដឹងនៅកាលនោះ?

ឆៃ៖ នៅកាលនោះ ខ្ញុំដឹងថាក្តិនស្អុយអ៊ីចឹង ។ សាកសពមនុស្សក៏ស្អុយអ៊ីចឹង សាកសពសត្វដទៃក៏ធុំក្តិនស្អុយអ៊ីចឹងដូចតែគ្នាដែរ ។ ខ្ញុំមិនអាចថាសម្គាល់ថា មនុស្សធុំក្តិនរបៀបម៉េច? សត្វធុំក្តិនស្អុយរបៀបម៉េច? ក៏ខ្ញុំអត់ដឹងដែរ ។

សៃ៖ តើ“អង្គការ” គឺជាពាក្យមួយដែលលោកនៅចងចាំ តើការចងចាំពាក្យ “អង្គការ” នោះមានន័យដូចម្តេច? ថាតើជាពាក្យធម្មតា ឬក៏ពាក្យ “អង្គការ” ហ្នឹង កាលណាឮធ្វើឲ្យលោកមានការភ័យខ្លាច ឬយ៉ាងម៉េច?

ឆៃ៖ ធម្មតាពាក្យ “អង្គការ” គឺតាមខ្ញុំដឹង ន័យជាធម្មតា គេហៅថា “អង្គការៗ” អ៊ីចឹងតែម្តង ហើយត្រង់ខ្លាចអត់ឮសូរថា “អង្គការ” ហ្នឹងថាខ្លាច ក៏ខ្ញុំអត់មានខ្លាចដែរ ព្រោះពាក្យហ្នឹងហៅជាធម្មតាមក ។

សៃ៖ ហើយពាក្យថា “អាណិតអាសូរ” តើគេធ្លាប់ប្រើពាក្យហ្នឹងទេនៅសៃ-២១? តើលោកនៅចាំថាមានអ្នកទោសណាម្នាក់ ដែលសុំឲ្យលោកជួយទេ អង្វរករឲ្យលោកជួយទេ? តើលោកនៅចាំអំពីហេតុការណ៍បែបនោះដែរឬទេ?

ឆៃ៖ ហ្នឹងខ្ញុំនៅស-២១ ក៏មិនដែលឮស្ងរ ថាពាក្យ “អាណិត” ពាក្យអីហ្នឹង គឺថាអត់មាន ។

ស៖ តើលោកនៅចាំថា មានអ្នកទោសដែលសុំអង្វរឲ្យលោកជួយ ដែលសុំថា “ហេតុអ្វីបានជាគេឃុំខ្លួនខ្ញុំនៅកន្លែងនេះ?” តើលោកនឹកឃើញទេ? តើលោកបាននិយាយទៅអ្នកទោស ឬក៏មិនដែលនិយាយទៅរកអ្នកទោសណាម្នាក់ទាល់តែសោះនោះ?

ឆៃ៖ ពេលអ្នកទោសចាប់យកមកដាក់នៅក្នុងបន្ទប់ គាត់តែងនិយាយថា គាត់មានកំហុសអី? គាត់សួរមកខ្ញុំអ្នកការពារហ្នឹង ។ សួរថា គាត់មានកំហុសអី បានជាទៅចាប់គាត់យកមក ហើយខ្ញុំក៏បានប្រាប់ថា “ខ្ញុំអត់ដឹងទេ ស្រេចលើអង្គការទេ ព្រោះភារកិច្ចរបស់ខ្ញុំ តែមកដល់កន្លែងនេះមានតែខ្ញុំទេការពារមើលខុសត្រូវហ្នឹង” ។

[១០:១៧:២៩]

ស៖ តើគេបានសុំឲ្យលោកជួយដែរឬទេ? នៅពេលដែលមានការឈឺចាប់តើគេសុំឲ្យលោកជួយដែរឬទេ?

ឆៃ៖ អ្នកទោសមានការឈឺចាប់ហ្នឹង ក៏បានជាសុំខ្ញុំណាស់ដែរ។ ក៏ប៉ុន្តែ ខ្ញុំថា ខ្ញុំជួយមិនបានទេ អ្នកណាធ្វើអ្នកហ្នឹងទទួលហើយ មិនដឹងធ្វើម៉េចទេ ។

ស៖ ដូច្នេះ គឺជាការងារធម្មតា ឬយ៉ាងម៉េច? តើមិនថាជាការចង់ចាំល្អ ឬមិនល្អទេ ឬក៏គ្រាន់តែលោកមិនចង់ចាំអំពីការងារនុ៎ង មែនឬទេ?

ឆៃ៖ ការងារហ្នឹងខ្ញុំចង់ចាំបានខ្លះ មិនបានខ្លះអីចឹងទៅ តែឲ្យខ្ញុំចាំអស់រលីង ក៏ខ្ញុំចាំមិនបានអស់ដែរ ព្រោះរយៈពេលវាយូរពេក ។

ស៖ ហើយក្នុងអំឡុងពេលដែលលោកធ្វើការងារនោះ តើលោកនៅចាំថាមានអ្នកទោសណាម្នាក់ដែលប្រព្រឹត្ត បាននិយាយថាធ្វើអត្តឃាតដែរឬទេ?

ឆៃ៖ ហ្នឹង ក៏ខ្ញុំអត់ដែលដឹងដែរអាហ្នឹង អត់បានឃើញ អត់បានឮដែរ ។

ស៖ តើលោកបានឮពីរឿងហ្នឹងដែរឬទេ? តើលោកបានទទួលការណែនាំដើម្បីឲ្យធ្វើយ៉ាងណាកុំឲ្យអ្នកទោសធ្វើអត្តឃាត ឬក៏សម្លាប់ខ្លួនឯងដែរឬទេ?

ឆៃ៖ ក្នុងការណែនាំពីថ្នាក់ដឹកនាំ ឃើញថា គាត់ណែនាំពិតប្រាកដអីចឹងមែន ។

[១០:២០:០៤]

ស៖ តើលោកបានឃើញអ្នកណាម្នាក់ស្លាប់នៅ ស-២១ ដែរឬទេ?

ឆេ៖ នៅក្នុងស-២១ ខ្ញុំអត់បានឃើញអ្នកស្លាប់នៅហ្នឹងទេ ។

សៈ តើលោកបានឮអំពីថា មានអ្នកទោសស្រីដែលត្រូវបានគេធ្វើបាប ឬក៏ត្រូវបានគេរំលោភដែរឬទេ? តើលោកមានការណែនាំអ្វីទេទាក់ទងទៅនឹងការយាមអ្នកទោសស្ត្រីនោះ?

ឆេ៖ នៅទីនោះក៏ខ្ញុំមិនបានយាមអ្នកទោសស្រីហ្នឹងដែរទេ មិនដឹងថា អ្នកទោសស្រីហ្នឹងដាក់នៅកន្លែងណាអីកន្លែងណាក៏ខ្ញុំអត់បានដឹងដែរ ។

សៈ ខ្ញុំសួរសំណួរហ្នឹងម្តងទៀត តើលោកធ្លាប់ឮអំពីថាអ្នកទោសស្ត្រីណាម្នាក់ត្រូវបានគេរំលោភដែរឬទេ? តើលោកបានឮពាក្យ ឬក៏អ្នកណានិយាយអំពីរឿងហ្នឹងដែរឬទេ?

ឆេ៖ ហ្នឹង ខ្ញុំនៅកន្លែងហ្នឹងអត់បានឮផង ។

សៈ ដូច្នេះយើងនិយាយអំពីជនជាប់ចោទវិញ ។ តាមទស្សនៈរបស់លោក តើលោកគិតថាគាត់ជាអ្នកមេដឹកនាំធម្មតា ឬយ៉ាងម៉េច? តើលោកអាចរៀបរាប់ប្រាប់យើងដូចម្តេចអំពី ឌុច ថាតើបុគ្គលិកលក្ខណៈរបស់គាត់ដូចម្តេច?

ឆេ៖ តាមខ្ញុំរស់នៅជាមួយគាត់ ឃើញថា គាត់ដឹកនាំឲ្យធ្វើការហ្នឹងធម្មតា អត់មានទៅបង្ខំ អត់មានទៅអីទេ ។

សៈ តើនោះមានន័យដូចម្តេច? អ្វីដែលលោកប្រាប់យើងហ្នឹង តើមានន័យដូចម្តេចថា ធម្មតាៗនោះ?

ឆេ៖ ធម្មតាៗហ្នឹង ដែលខ្ញុំប្រាប់ហ្នឹងឃើញថា ការងារប្រចាំថ្ងៃគ្រប់ពេលគ្រប់វេលាទៅអីចឹងរហូតទៅថ្ងៃណាក៏ដូចថ្ងៃណាអីចឹងទៅ ខំបំពេញការងារជាហែហូរហូត ។

សៈ នៅពេលដែលអ្នកស៊ើបអង្កេតសម្ភាសន៍លោក ខ្ញុំយោងទៅឯកសារ D78 នៅក្នុងទំព័រទី ២៣ គេសួរទៅលោក។ ថាតើលោកស្គាល់ ឌុច រយៈពេលប៉ុនណា តើ ឌុច ជាមនុស្សបែបម៉េច? ហើយលោកបានឆ្លើយដូច្នេះ គាត់ជាមនុស្សមាឌតូច គាត់មានអារម្មណ៍ដូចកក់ក្តៅនឹងការងារ ។ ប៉ុន្តែ ម៉ឺងម៉ាត់ណាស់ ។ ខ្ញុំបានស្គាល់គាត់នៅ តាំងតែពីខ្ញុំទទួលមុខងារជាអ្នកយាមនៅស-២១ ។ ខ្ញុំបានទៅជួបគាត់ម្តង ជួប ឌុច ម្តងពេលដែលខ្ញុំយកអ្នកទោសដែលអាចនឹងកត់ត្រាឯកសារមួយនៅផ្ទះរបស់គាត់ ។ ផ្ទះរបស់គាត់នោះនៅខាងមុខច្រកចូលធំ នៃនៅភាគខាងត្បូងឈរឆ្ងាងខាងកើត ហើយ ឌុច បានប្រាប់ខ្ញុំ ហើយសុំឲ្យខ្ញុំទុកអ្នកទោសនោះយាម ឲ្យយាមអ្នកទោសដែលមានព័ត៌មានឯកសារល្អ ។ ឌុច គឺជាប្រធានស-២១ ហើយគាត់ជាអ្នកទទួលខុសត្រូវលើឯកសារដែលទាក់ទងទៅនឹងចម្លើយសារភាព ហើយ

គាត់បានជាអ្នកបញ្ជោទាក់ទងទៅនឹងការសម្លាប់ជាដើម។ ដូច្នេះ ថ្ងៃលោកប្រាប់យើងដូចម្តេច? ថាគាត់ជាមនុស្សរាក់ទាក់ ប៉ុន្តែជាមនុស្សម៉ឺងម៉ាត់ក្នុងការងារដដែលឬទេ? ថាតើគាត់ជាមនុស្សធម្មតា ឬយ៉ាងម៉េច?

[១០:២៥:៣៨]

ឆេ៖ ហ្នឹងពិតៗប្រាកដតាមចម្លើយរបស់ខ្ញុំនៅក្នុងឯកសារហ្នឹង ។

សៃ៖ លោកបានចំណាយពេលធ្វើការនៅទីនោះ គឺថាប្អូនឆ្នាំនៅស-២១ តើអ៊ីចឹងមែនទេ? តើលោកអាចនិយាយបានទេថាការចងចាំនេះវាធ្វើឲ្យលោកឈឺចាប់ ឬក៏ធម្មតាមិនមែនជារឿងល្អ ឬមិនមែនជារឿងអាក្រក់ ឬលោកយល់ថាការងារពេលនោះអ៊ីចឹង?

ឆេ៖ ពេលខ្ញុំនៅស-២១ តាំងពីឆ្នាំ១៩៧៥ មកដល់រហូត ដល់បែក៧មកវានេះឃើញថា ក្នុងខ្លួនខ្ញុំហ្នឹងវាមានការឈឺចាប់ដែរ តែមិនដឹងគេចទៅណារួចអំពីតាមសម័យសង្គមដែលបំពាក់បំប៉នឲ្យឃើញថារស់នៅហ្នឹងក៏ពិបាកវេទនាដែរ ប៉ុន្តែទ្រាំៗទៅក្រែងលោ មានដឹងថា សង្គមនោះសម្លាប់មនុស្សដល់ថ្នាក់ហ្នឹងឯណា ក៏អត់បានដឹងដែរទេ ចេះតែទ្រាំៗរស់នៅធ្វើការនៅហ្នឹងទៅ បានរស់នៅរហូតដល់សព្វថ្ងៃហ្នឹងទៅ ។

សៃ៖ ដូច្នេះ ខ្ញុំព្យាយាមធ្វើការសង្ខេប ប្រសិនបើលោកចងចាំមិនល្អ ដោយហេតុថា ខ្លួនលោកផ្ទាល់ក៏ទទួលរងការឈឺចាប់ តើអ៊ីចឹងដែរឬ អ៊ីចឹងត្រឹមត្រូវទេ ឬក៏លោកមិនចងចាំដោយសារៗមានអ្នកផ្សេងមានការឈឺចាប់ច្រើននៅស-២១ ឬក៏ការឈឺចាប់ហ្នឹងវាមានលក្ខណៈធម្មតាទេ?

ឆេ៖ ឃើញនៅក្នុងស-២១ ហ្នឹងមានការឈឺចាប់ហ្នឹង ឃើញថា វាឈឺចាប់ខ្លាំងណាស់ក្នុងការបំពេញការងារនៅក្នុងស-២១ ហ្នឹង ម្នាក់ៗឃើញថា ឈឺចាប់គ្រប់តែគ្នា តែគ្រាន់ថា មិនដឹងគេចទៅណាទៅហើយ ចេះខំទៅ ធ្វើៗទៅ ថ្ងៃណាក៏ថ្ងៃហ្នឹងទៅ តាមមួយដំណើរអ៊ីចឹងទៅ ។

សៃ៖ នេះជាសំណួរចុងក្រោយរបស់ខ្ញុំលោក គក ស្រស់។ ការឈឺចាប់ខ្លាំងជាងគេបំផុត ថាតើលោកជាអ្នកឈឺចាប់ ឬក៏បុគ្គលិកផ្សេងៗ ឬក៏អ្នកទោសទេ ជាអ្នកឈឺចាប់ខ្លាំងជាងគេបំផុតនៅពេលនោះ?

ឆេ៖ បើគិតទៅឃើញថា អ្នកទោសមានការឈឺចាប់ច្រើនជាងបុគ្គលិកនៅក្នុងមន្ទីរស-២១ ។

ចៅក្រម ហ្សង់ម៉ាក ឡាវែន៖

អរគុណ ។ ខ្ញុំមិនមានសំណួរអ្វីផ្សេងទៀតទេ លោកប្រធាន ។

ប្រធានអង្គជំនុំ៖

ឥឡូវនេះ ដល់ម៉ោងត្រូវសម្រាក អង្គជំនុំជម្រះប្រកាសសម្រាក ហើយដប់ប្រាំពីរនាទី រហូតដល់ម៉ោងដប់មួយខ្វះដប់ប្រាំនាទីនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចពិភាក្សាដេញដោលតទៀត ។ មន្ត្រីតុលាការសម្របសម្រួលដល់សាក្សី គក ស្រស់ ដើម្បីផ្តល់ឱ្យគាត់ទូរកន្លែងសម្រាកសមរម្យ ហើយនាំគាត់មកកាន់សាលសវនាការវិញ ឱ្យបានមុនម៉ោងដប់មួយខ្វះដប់ប្រាំនាទី ។

[សវនាការសម្រាកពីម៉ោង ១០:៣០នាទី ដល់ម៉ោង ១០:៥១នាទី]

ប្រធានអង្គជំនុំ៖

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលស្តាប់សក្ខីកម្មសាក្សី គក ស្រស់ ដល់ភាគី ។ មុននឹងប្រគល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះធ្វើសេចក្តីប្រកាសទូរសេចក្តីសម្រេច និងសេចក្តីណែនាំដែលជាលទ្ធផលនៃប្រជុំពិភាក្សារៀបចំការងារឆ្ពោះតបទៅនឹងសំណូមពររបស់ភាគីដូចខាងក្រោម៖

១) សេចក្តីណែនាំទាក់ទងនឹងការសួរសំណួរដល់ជនជាប់ចោទ ក្នុងអំឡុងពេលធ្វើសក្ខីកម្មសាក្សី កាលពីថ្ងៃទី២២ ខែកក្កដា កន្លងទៅនេះសហព្រះរាជអាជ្ញាបានលើកឡើងទូរបញ្ហាទាក់ទងទៅនឹងសំណួរដល់ជនជាប់ចោទក្នុងអំឡុងពេលធ្វើសក្ខីកម្មសាក្សីដោយកត់សម្គាល់ថា ការអនុវត្តបែបនេះអាចជាការបំភ័យដល់សាក្សី ។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ក៏បានស្នើសុំផងដែរថា ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីក្រុមណាមួយមានបំណងចោទសួរដល់ជនជាប់ចោទ ក្នុងអំឡុងពេលធ្វើសក្ខីកម្មសាក្សី នោះគប្បីផ្តល់ពេលវេលាបន្ថែមសម្រាប់គោលបំណងនេះ ។

ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះសូមធ្វើការណែនាំដល់ភាគីទាំងអស់ឱ្យបានជ្រាបថា៖

១) មិនមានការហាមឃាត់ភាគីក្នុងការសួរសំណួរដល់ជនជាប់ចោទ ក្នុងដំណាក់កាលដែលពាក់ព័ន្ធក្នុងពេលធ្វើសក្ខីកម្មសាក្សីនោះទេ ។ អង្គជំនុំជម្រះនឹងសម្រេចអំពីការអនុញ្ញាត ឬមិនអនុញ្ញាតនូវការសួរសំណួរបៀបនេះអាស្រ័យទៅលើករណីជាក់ស្តែងនីមួយៗ ។

២) ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ អាចប្រើពេលវេលាដែលបានប្រគល់ឱ្យសម្រាប់សួរសំណួរ

ដល់សាក្សី សួរសំណួរដែលពាក់ព័ន្ធដល់ជនជាប់ចោទបាន។ ក៏ប៉ុន្តែ មិនមានការផ្តល់ពេលវេលាបន្ថែមសម្រាប់ការសួរសំណួរក្នុងករណីបែបនេះទេ ។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ បានស្នើសុំឲ្យសួរសំណួរដែលនៅសេសសល់ដល់សាក្សី ឬជនជាប់ចោទ ដែលមេធាវីមិនមានលទ្ធភាពសួរចប់ក្នុងអំឡុងពេលដែលបានប្រគល់ឲ្យជូនទៅអង្គជំនុំជម្រះ ។ សហព្រះរាជអាជ្ញាបានគាំទ្រសំណើនេះ ។ ប៉ុន្តែ បានកត់សម្គាល់ថា ប្រសិនបើអង្គជំនុំជម្រះប្រកាន់យកនូវការអនុវត្តបែបនេះ នោះសំណួរគួរតែត្រូវបានបែងចែកជាប្តង់ដោយផ្តាល់មាត់ ដើម្បីសន្សំពេលវេលាដែលតម្រូវឲ្យមានការបកប្រែជាលាយលក្ខណ៍អក្សរជាបីភាសា ។ មេធាវីការពារជនជាប់ចោទបានជំទាស់ទៅនឹងសំណើនេះដោយលើកឡើងថា នេះគ្រាន់តែជាមធ្យោបាយសាមញ្ញមួយ ដើម្បីទទួលបានពេលវេលាបន្ថែមសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីសួរសំណួរប៉ុណ្ណោះ ។

[១០:៥៤:១៤]

សម្រេចអង្គជំនុំជម្រះ មានកាតព្វកិច្ចធានាថា សវនាការត្រូវប្រព្រឹត្តទៅដោយទាំងយុត្តិធម៌ ទាំងឆាប់រហ័ស ។ មានតម្រូវការជាចាំបាច់ដើម្បីពិនិត្យឡើងវិញនូវពេលវេលាដែលបានប្រគល់ឲ្យភាគីសម្រាប់សួរសំណួរខណៈដែលត្រូវធានាថា មេធាវីការពារជនជាប់ចោទក៏ត្រូវមានពេលវេលាគ្រប់គ្រាន់ផងដែរ។ អង្គជំនុំជម្រះនឹងមិនប្រកាន់យកនូវការអនុវត្តដែលជាការបន្ថែមពេលវេលា ដែលបានប្រគល់ឲ្យដល់ភាគីសម្រាប់សួរសំណួរនោះទេ ពីព្រោះថាការធ្វើដូច្នេះអាចធ្វើឲ្យបាត់បង់នូវតុល្យភាពពេលវេលាដែលបានបែងចែកទៅឲ្យភាគី ដោយរួមទាំងមេធាវីការពារជនជាប់ចោទផងដែរ ។

សេចក្តីសម្រេចលើសំណើសុំរបស់សហមេធាវីការពារក្តី ដែលទាមទារឲ្យមានការកំណត់ពេលវេលាក្នុងការសួរសំណួរទៅសាក្សីក្នុងរយៈពេលមួយស្មើគ្នាទៅនឹងចំរវេលាសរុបនៃចំរវេលាដែលអង្គជំនុំជម្រះបានផ្តល់ឲ្យសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។

អង្គជំនុំជម្រះបានទទួលសំណើសុំរបស់សហមេធាវីការពារក្តីដែលបានស្នើសុំឲ្យមានការផ្តល់នូវចំរវេលានៃការចោទសួរដល់សាក្សីនីមួយៗក្នុងរយៈពេលមួយស្មើគ្នាទៅនឹងរយៈពេលសរុបដែលផ្តល់ជូនសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់ពីការតាំងសំណួរដោយអង្គជំនុំជម្រះ ។

ដោយហេតុថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឲ្យធ្វើការតាំងសំណួរក្នុងគោលបំណងគាំទ្រនូវការចោទប្រកាន់ អង្គជំនុំជម្រះយល់ឃើញថា ដើម្បីធានាដល់ការគោរពសិទ្ធិក្នុងការការពារខ្លួន និងជាពិសេសសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដោយធ្វើយ៉ាងណាធានាឲ្យ

មានសមភាពនៃកម្លាំងនោះ វាអាចជាការចាំបាច់មួយដែលអង្គជំនុំជម្រះត្រូវអនុញ្ញាតឲ្យមានការបន្ថែមពេលវេលាដល់សហមេធាវីការពារ ដើម្បីធ្វើការចោទសួរលើសពីពេលវេលាបានកំណត់មិនបានប្រកាសនៅក្នុងពេលសវនាការកន្លងមក ទាក់ទងនឹងការបែងចែកពេលវេលាសម្រាប់ភាគី ។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះត្រូវធានាថា ដំណើរការជំនុំជម្រះក្តីលើជនជាប់ចោទ ត្រូវប្រព្រឹត្តទៅក្នុងចិរវេលាមួយសមស្រប ដើម្បីឆ្លើយតបទៅនឹងកិច្ចដឹកនាំសវនាការបានល្អ ។ ដោយទីមួយ ភាគីត្រូវបានកំណត់ពេលវេលាឲ្យធ្វើការតាំងសំណួរ និងទីពីរ សំណួរដែលមានលក្ខណៈច្រំដែល ឬមិនពាក់ព័ន្ធទៅនឹងអង្គហេតុមិនត្រូវបានអនុញ្ញាតឲ្យសួរទេ ។ ដោយផ្អែកលើទិដ្ឋភាពជាក់ស្តែង អង្គជំនុំជម្រះបានធ្វើការកត់សម្គាល់ឃើញថា មកទល់នឹងពេលនេះ សហមេធាវីការពារក្តីពុំដែលបានដាក់សំណើសុំឲ្យមានការបន្ថែមពេលវេលាណាមួយដល់ខ្លួន ដើម្បីធ្វើការចោទសួរនោះទេ ហើយខ្លួនក៏មិនដែលបានបានលើកឡើងអំពីបញ្ហាពាក់ព័ន្ធនឹងចិរវេលានេះដែរ បន្ទាប់ពីការបញ្ចប់ការធ្វើសក្ខីកម្មសាក្សីនីមួយៗ ។

[១០:៥៧:៥៥]

ផ្ទុយទៅវិញ មេធាវីការពារក្តីតែងតែបញ្ជាក់ថា ខ្លួនគ្មានសំណួរនឹងត្រូវសួរទៅសាក្សីទៀតទេ ទោះបីជា ពេលវេលាដែលអនុញ្ញាតឲ្យធ្វើការតាំងសំណួរនោះមិនទាន់ត្រូវបានប្រើប្រាស់អស់ក៏ដោយ ។

អង្គជំនុំជម្រះយល់ឃើញថា ដើម្បីអនុញ្ញាតឲ្យមានការរៀបចំកម្មវិធីសវនាការមួយប្រកបដោយភាពត្រឹមត្រូវនិងអាប់រហ័សនោះ ចិរវេលាបច្ចុប្បន្នដែលបានផ្តល់ជូនដល់ភាគីរួចហើយនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនត្រូវតែបានរក្សាទុកនៅដដែល ។ ប្រសិនបើជាមេធាវីការពារក្តីយល់ឃើញថា វាមានភាពចាំបាច់ចំពោះការសួរសំណួរដែលនៅសេសសល់ មេធាវីការពារក្តីអាចធ្វើការស្នើសុំមកអង្គជំនុំជម្រះដើម្បីសុំការអនុញ្ញាតឲ្យមានការបន្ថែមពេលវេលាក្នុងការចោទសួរនូវសំណួរដោយមេធាវីយល់ឃើញថាសមស្របនឹងធ្វើការចោទសួរ ដើម្បីធានាឲ្យមានការគោរពនូវសិទ្ធិរបស់ខ្លួននោះ អង្គជំនុំជម្រះនឹងធ្វើការសម្រេច តាមករណីជាក់ស្តែងនីមួយៗ ។

ហេតុដូច្នេះ សម្រេច អង្គជំនុំជម្រះសម្រេចរក្សាទុកវិញ:ពេលនៃការតាំងសំណួរ ដូចដែលបានផ្តល់ជូនដល់ភាគីមេធាវីការពារក្តីកន្លងមក អង្គជំនុំជម្រះធ្វើការបញ្ជាក់ផងដែរថា មេធាវីការពារក្តីមានសិទ្ធិស្នើសុំតាមវិញ: តាមករណីជាក់ស្តែងនីមួយៗ និងយោងទៅលើខ្លឹមសារនៃការសួរដេញដោលឲ្យមានការបន្ថែមពេលវេលាក្នុងការចោទសួរសំណួរ ដែលមេធាវីការពារក្តីយល់ឃើញថាសមស្របដែលនឹងត្រូវចោទសួរដើម្បីធានាឲ្យមានការគោរពដល់សិទ្ធិរបស់ខ្លួន ។

នេះជាសេចក្តីណែនាំនិងសេចក្តីសម្រេចពាក់ព័ន្ធជាមួយនិងសំណើសុំ និងមតិយោបល់ដែលភាគីបានលើកឡើងនៅសវនាការចុងក្រោយនៃថ្ងៃពុធ សប្តាហ៍មុន ។

ជាកិច្ចបន្តនេះ សូមប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានលទ្ធភាពនៅក្នុងការតាំងសំណួរដល់សាក្សីរូបនេះ ពាក់ព័ន្ធនឹងអង្គហេតុដែលបានចោទប្រកាន់បន្ទុកលើជនជាប់ចោទ ហើយសូមជម្រាបផងដែរថា តំណាងសហព្រះរាជអាជ្ញាមានរយៈពេលសួរករណីនេះដប់ប្រាំនាទី ។

សូមអញ្ជើញ ។

[១១:០០:៣០]

សួរដោយលោក តាន់ សេណារ៉ុង៖

អរគុណលោកប្រធានអង្គជំនុំជម្រះ និងសូមស្វាគមន៍លោក គក ស្រស់ ។

ស៖ សំណួរទីមួយជូនលោក លោកបានជម្រាបជូនអង្គជំនុំជម្រះរួចមកហើយថា លោកត្រូវបានចាត់តាំងឲ្យយាមនៅមន្ទីរស-២១ ក្នុងមួយខែផ្លាស់វេនម្តង គឺមួយខែផ្លាស់វេនខាងក្នុង និងមួយខែទៀតវេនយាមនៅខាងក្រៅ។ សំណួរសួរថា តើបញ្ហាផ្លាស់ប្តូរវេនយាមនេះ តើអ្នកណាអ្នកសម្រេចឲ្យលោក? ហើយតើលោកយាមចាប់ពីម៉ោងប៉ុន្មាន ដល់ម៉ោងប៉ុន្មាននៅក្នុងវេនយាមនីមួយៗ?

អ៊ុ៖ ការសម្រេចផ្លាស់ប្តូរវេនយាមហ្នឹងនៅលើប្រធានកងរយ ។ ការយាមរយៈពេលផ្លាស់ប្តូរគ្នាបើយាមព្រលប់ពីម៉ោងប្រាំមួយ ទៅរហូតដល់ម៉ោងដប់ពីរ ហ្នឹងដូរវេនគ្នាម្តង ។

ស៖ អរគុណលោក គក ស្រស់ ។ សំណួរទីពីរជូនលោក នៅក្នុងរយៈពេលនៃការយាមកាមរបស់លោកទាំងខាងក្នុងអគារនៅក្នុងបរិវេណមន្ទីរស-២១ក្តី នៅក្នុងខាងក្រៅអគារក្តី តើនៅពេលដែលលោកយាមកាមនោះ តើលោកដែលមានឃើញវិន័យសន្តិបាល ដែលគេបានសរសេរនៅក្នុងអគារនៅតាមអគារនីមួយៗហ្នឹងដែរឬទេ? និងសុំការអនុញ្ញាតពីលោកប្រធានអង្គជំនុំជម្រះដើម្បីបង្ហាញនូវឯកសារមួយដែលមានលេខ ERN 00181448 ដល់សាក្សីឈ្មោះ គក ស្រស់ ។

ប្រធានអង្គជំនុំ៖

មន្ត្រីផ្នែកខាងសោតទស្សន៍ដាក់បង្ហាញ នូវឯកសារដែលមានលេខ ERN 00181448 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ តាមសំណើរបស់តំណាងសហព្រះរាជអាជ្ញា ។

សួរដោយលោក តាន់ សេណារ៉ុង៖

ស៖ លោក គក ស្រស់ លោកបានឃើញនូវវិន័យសន្តិបាលហ្នឹងទេ នៅពេលដែលលោកយាម?

ឆេ៖ ពេលដែលខ្ញុំយាម អត់មានបានឃើញវិន័យសន្តិបាលហ្នឹងទេ ។

លោក តាន់ សេណារ៉ុង៖

អរគុណលោក ។ សុំការអនុញ្ញាតពីលោកប្រធានអង្គជំនុំជម្រះផងដែរ ដើម្បីបង្ហាញនូវរូបភាពរួមរបស់សារមន្ទីរទួលស្លែងដែលមានលេខ ERN 00189137 ។

ប្រធានអង្គជំនុំ៖

មន្ត្រីផ្នែកខាងសោតទស្សន៍បង្ហាញនូវឯកសារ ដែលមានលេខ ERN 00189137 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ តាមសំណើរបស់តំណាងសហព្រះរាជអាជ្ញា ។

[១១:០៤:១២]

សួរដោយលោក តាន់ សេណារ៉ុង៖

ស៖ លោក គក ស្រស់! នេះគឺជារូបភាពនៃសារមន្ទីរទួលស្លែងដែលបានថតពីលើអាកាស ហើយបង្ហូមមកដែលមានអគារអក្សរ “A” ហ្នឹង “ក”, “B” ហ្នឹង “ខ” ,“C” ហ្នឹង “គ”, “D” ហ្នឹង “ឃ” និង “ង” តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា នៅក្នុងរយៈពេលបំពេញការងារនៅក្នុងសារមន្ទីរនៅក្នុងមន្ទីរស-២១ ន៎ុងនាពេលនោះ តើលោកយាមអាចចង្អុលបង្ហាញថា តើអគារណាមួយដែលលោកបានធ្លាប់យាមហ្នឹង? ហើយបើយាមខាងក្រៅលោកយាមនៅលើទីតាំងណាមួយ និងខាងក្នុងនៅទីតាំងណាមួយនៃអគារទាំងនោះ?

សូមជម្រាបជូនអង្គជំនុំជម្រះដែរថា រូបភាពនេះគឺជារូបភាពចាស់របស់ការិយាល័យសហព្រះរាជអាជ្ញាដែលបានដាក់ឯកសារជូនអង្គជំនុំជម្រះ ហើយប៉ុន្តែ ក្រុមអ្នកជំនាញរបស់ការិយាល័យសហព្រះរាជអាជ្ញា បានរៀបចំបន្ថែមផ្លូវនៅក្នុងរូបភាពនេះ ដើម្បីឲ្យងាយស្រួលក្នុងការដាក់បង្ហាញជូនសាក្សី ក៏ដូចជាអង្គជំនុំជម្រះ ដើម្បីងាយយល់ផងដែរ ។ សូមអញ្ជើញលោក គក ស្រស់ ។

ឆេ៖ ពេលដែលខ្ញុំយាមនៅអគារ “C” ផ្នែកខាងក្នុង ហ្នឹងពេលយាមនៅក្នុងអគារ យាមអគារ “C” ហ្នឹង ដល់ពេលដូរមកយាមខាងក្រៅ នៅតាមខាងក្រោយអគារ “C” ហ្នឹង ក៏នៅខាងលិចនៅតាមរបងទ័ព្ធជុំវិញអគារហ្នឹង ។

លោក តាន់ សេណារ៉ុង៖

អរគុណលោក គក ស្រស់ ។ សំណួរបន្ទាប់ទៀត សុំការអនុញ្ញាតពីលោកប្រធានអង្គជំនុំជម្រះដើម្បីបង្ហាញរូបភាពមួយ ដែលមាននៅក្នុងឯកសារលេខ ERN លេខ 00326351 នៅក្នុង E63 ។

រូបភាពនេះគឺជារូបភាពដែលគូរដោយលោក វ៉ាន់ ណាត បង្ហាញពីជាប់ច្រវាក់នៅក្នុងបន្ទប់មន្ទីរឃុំឃាំង ដែលមានលេខពីរ នៅក្នុងរូបភាពលេខពីរ នៅក្នុងឯកសារដែលខ្ញុំបានជម្រាបជូនអម្ចាញ់មិញ ។

ប្រធានអង្គជំនុំ៖

មន្ត្រីសោតទស្សន៍ដាក់បង្ហាញនូវឯកសារដែលមានលេខ ERN 00326351 ឬក៏ E63 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍តាមសំណើរបស់តំណាងសហព្រះរាជអាជ្ញា ។

សួរដោយលោកតាន់ សេណារ៉ុង៖

ស៖ សំណួរជូនលោក គក ស្រស់ ថាតើលោកបានឃើញ ក្នុងនាមលោកជាអ្នកយាម តើលោកបានឃើញទិដ្ឋភាពការដាក់ច្រវាក់អ្នកទោសនៅក្នុងមន្ទីរឃុំឃាំងនោះ ដូចរូបដែលបានបង្ហាញជូនហ្នឹងមែនទេ?

ឆ៖ ពិតប្រាកដមែន ។

[១១:០៧:៥៣]

ស៖ អរគុណលោក គក ស្រស់ ។ ខ្ញុំសូមចូលទៅរូបគំនូរមួយទៀត ដែលមាននៅក្នុងឯកសារដដែល ដែលមានលេខ P00000027 នៅក្នុងរូបភាពធំហ្នឹង តើក្នុងនាមលោកជាអ្នកយាម លោកបានឃើញថាការឃុំឃាំង និងដាក់ច្រវាក់អ្នកទោសឲ្យដេកតម្រាបគ្នាដូចក្នុងរូបភាពរបស់លោក វ៉ាន់ ណាត អ៊ីចឹងមែនទេ?

ឆ៖ ពិតប្រាកដមែន ។

លោក តាន់ សេណារ៉ុង៖

អរគុណលោក គក ស្រស់ ។ ខ្ញុំអស់សំណួរ សូមបង្វិលសំណួរបន្ទាប់ទៅសហការីរបស់ខ្ញុំ ។

សួរដោយលោក អានីស អះមេដ៖

សូមគោរពលោកប្រធាន! ដោយសារថា ពេលវេលាខ្លីខ្ញុំនឹងសំណួរតូច ហើយឯកសារ 00186795 រហូតដល់ 0086801 សូមស្នើបង្ហាញឯកសារនេះ ហើយខ្ញុំនឹងសួរសំណួរ ។

ស៖ លោក គក ស្រស់ តើលោកចេះអក្សរខ្មែរ ហើយលោកអានភាសាខ្មែរបានតើមែនឬទេ?

ប្រធានអង្គជំនុំ៖

មន្ត្រីសោតទស្សន៍បង្ហាញនូវឯកសារដែលមានលេខ ERN តាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដែលបានលើកឡើងអម្ចាញ់មិញ ។

សួរដោយលោក អានីស អះមេដ៖

ស៖ ខ្ញុំនឹងសួរសំណួរម្តងទៀត តើលោកចេះអក្សរ ឬក៏មិនចេះអក្សរ តើលោកអានភាសាខ្មែរបានឬទេ?

ឆ៖ អក្សរខ្ញុំចេះ ក៏ប៉ុន្តែបច្ចុប្បន្នឥឡូវមើលទៅជាប់គ្នាទាំងអស់ អត់បានមើលទៅដាច់ៗគ្នាទេ ជាប់គ្នារហូត ម្ល៉ោះហើយមើលអត់ដាច់ទេ ។

ស៖ ឯកសារចំពោះមុខលោកនេះ គឺចម្លើយដែលបានឆ្លើយមួយឆ្នាំទៅហើយ ដែលចៅក្រមឡាវែន៍ បានសួរវ៉ៃកលោក ដែលថា នៅខាងក្រោមនោះមានស្នាមមេដៃ ហើយនិងហត្ថលេខារបស់លោក ដែលលោកបានផ្តិតនៅលើនោះ តើលោកនៅចាំទេ?

ឆ៖ នៅចាំ ។

[១១:១០:៣៥]

ស៖ នេះគឺជាចម្លើយដែលលោកបានឆ្លើយទៅឲ្យអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតដែលផ្តល់នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៨ លោកបានប្រាប់អ្នកស៊ើបអង្កេតថា ឌុច ជាអ្នកជាប់ចោទនៅទីនោះ ជាអ្នកត្រួតត្រារួមនៅទីតាំងនោះ ហើយគាត់មានអំណាចរាប់ទាំងការបញ្ជាឲ្យសម្លាប់មនុស្ស។ តើលោកយល់ស្រប ឬក៏លោកបញ្ជាក់ថាការហ្នឹងពិតឬទេ?

ឆ៖ ខ្ញុំយល់ស្របតាម ព្រោះនៅក្នុងទីនោះមានតែគាត់ទេ ដែលធំជាងគេបង្អស់ ។

ស៖ លោកក៏បានប្រាប់ទៅអ្នកសង្កេតដែរថា នៅពេលដែលទាហានវៀតណាមចូលមកដល់ ឌុច បានបញ្ជាឲ្យមានការសម្លាប់អ្នកជាប់ឃុំដែលនៅសល់ទាំងអស់ តើត្រឹមត្រូវដែរឬទេ?

ឆ៖ អ្នកជាប់ឃុំទាំងអស់ហ្នឹងបើគាត់មិនបញ្ជា ក៏គ្មាននរណាប៊ានសម្លាប់ដែរ ។

ស៖ សូមអរគុណ ។ លោកបានប្រាប់ទៅអ្នកអង្កេតដែរថា កុមារមិនត្រូវបានឃុំទេ ប៉ុន្តែកូនរបស់អ្នកធំៗ គឺជាពាក្យរបស់លោកថា កូនរបស់អ្នកធំក៏ត្រូវបានឃុំខ្លួន តើសម្តីនោះពិតដែរឬទេ?

ឆ៖ កន្លែងហ្នឹងក៏ខ្ញុំអត់មាននិយាយដែរ ។

ស៖ លោកក៏បានប្រាប់អ្នកស៊ើបអង្កេតដែរថា ពេលខ្លះមន្ត្រីយោធាជាន់ខ្ពស់ក៏ត្រូវបានឃុំខ្លួនហើយនៅជាមួយអ្នកនោះ គឺថាមានទាហានទាំងក្រុមក៏ត្រូវបានជាប់មកឃុំខ្លួន ហើយអ្នកខ្លះមិនមានទោសអ្វីទេ ។ តើលោកឯកភាពថាលោកបាននិយាយអ៊ីចឹងដែរទេ?

ឆ៖ ហ្នឹងក៏ខ្ញុំអត់មានបាននិយាយអ៊ីចឹងដែរ ។

សៈ លោកក៏បានប្រាប់អ្នកស៊ើបអង្កេតនោះថា អ្នកទោសសំខាន់ៗទោះបីតែមានចំនួនតិចក៏ដោយ ត្រូវបានគេសម្លាប់នៅរបងខាងក្រៅស-២១ តើលោកឯកភាពថា លោកបានបញ្ជាក់បែបនោះឬទេ?

ឆៃ ខ្ញុំឯកភាពតាម ។

សៈ លោកក៏បានប្រាប់អ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតថា មានអ្នកទោសបរទេសជាច្រើន មានឥណ្ឌា មានថៃ ហើយជាពិសេសអ្នកទោសវៀតណាមត្រូវបានឃុំខ្លួននៅស-២១ ។ តើអ៊ីចឹងត្រឹមត្រូវឬទេ?

ឆៃ ត្រឹមត្រូវ ។

សៈ សំណួរចុងក្រោយរបស់ខ្ញុំ ដោយសារខ្ញុំអស់ពេលហើយ លោកបានដកស្រង់សម្តីឌុចថា ឌុច និយាយថា បានបញ្ជាឲ្យមានការឃុំខ្លួនបុគ្គលិកស-២១ ។ ខ្ញុំមិនមែនដកស្រង់សម្តី ឌុច ទេ សម្តីរបស់លោក ។ លោកថា ឌុច បញ្ជាឲ្យមានការឃុំខ្លួនបុគ្គលិក ស-២១ ប្រសិនបើគេមានការពាក់ព័ន្ធ ឬក៏មាននិន្នាការទៅនឹងមេរបស់គេ ។ ថាតើលោកនៅចាំទេ សម្តីហ្នឹងថា ឌុច ជាអ្នកបញ្ជាអ៊ីចឹងមែនទេ? [១១:១៤:២៦]

ឆៃ ហ្នឹងខ្ញុំនៅចាំ ។

សៈ សំណួរចុងក្រោយ ខ្ញុំនៅមានពេលមួយមីនុត។ លោកបាននិយាយថា មិនមានអ្នកជាប់ឃុំណាម្នាក់ត្រូវបានដោះលែងឲ្យរស់វានមានជីវិតនោះទេ ។ តើត្រឹមត្រូវឬទេសម្តីនោះ?

ឆៃ ត្រឹមត្រូវ ។

លោក អានីស អះមេដ៖

លោកប្រធានខ្ញុំមិនមានសំណួរអ្វីទៀតទេ ។ សូមអរគុណ ។

ប្រធានអង្គជំនុំ៖

ជាបន្តសូមប្រគល់វេទិកាទៅមេធាវីអ្នកតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ហើយដោយចាប់ពីមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយមុន ប្រសិនជាមានសំណួរសូមអញ្ជើញ ។ លោកមេធាវីមានរយៈពេលប្រាំមីនុត សម្រាប់ការសួរសំណួរដល់សាក្សីរូបនេះ ។

លោក អាឡាំង វ៉ែនណឺ៖

សូមគោរពលោកប្រធាន អស់លោក លោកស្រីចៅក្រម ហើយយើងមានឯកភាពក្នុងចំណោមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺថាមេធាវីតែម្នាក់នឹងត្រូវសួរទៅសាក្សី ។ អ៊ីចឹង ក្នុងករណីនេះយើង

អនុញ្ញាតឲ្យមេធាវី ស្វូតហ្សីនស្គី ជាអ្នកសួរ ។ សូមអរគុណ ។

ប្រធានអង្គជំនុំ៖

អញ្ជើញមេធាវី ស្វូតហ្សីនស្គី ។ មើលម៉ោងស្រួលបួលម៉ោងប៉ុន្មាន? ដប់មួយដប់បួននាទី ។ អញ្ជើញ ។

សួរដោយលោកស្រី ស៊ីលឃី ស្វូតហ្សីនស្គី៖

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំម៉ោងដប់មួយដប់បួននាទី ។ សូមជម្រាបសួរលោក គក ស្រស់ ខ្ញុំឈ្មោះមេធាវី ស្វូតហ្សីនស្គី ខ្ញុំតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ហើយខ្ញុំសូមសួរសំណួរទៅលោកមួយចំនួន ។ សំណួរទីមួយរបស់របស់ខ្ញុំគឺ សួរថាតើលោកបានឃើញជនជាប់ចោទចូលទៅក្នុងកន្លែងសួរចម្លើយនៅខាងក្រៅគុក-- នៅក្រៅបរិវេណគុក ដើម្បីឈរមើល ហើយនិងត្រួតពិនិត្យមើលការសួរចម្លើយដែរឬទេ?

[១១:១៦:៣៨]

ឆ៖ ខ្ញុំធ្លាប់ឃើញគាត់ម្តង គាត់មកដើរចូលមកកន្លែងអ្នកសួរចម្លើយ តែគាត់និយាយម៉ែចៗទៀតក៏ខ្ញុំអត់ដឹងដែរ គ្រាន់តែឃើញគាត់ដើរចូលមក ។

ស៖ តើលោកចាំទេ តើគាត់នៅកន្លែងសួរចម្លើយ បន្ទប់សួរចម្លើយនោះអស់រយៈពេលប៉ុណាដែរ?

ឆ៖ ហ្នឹងក៏ខ្ញុំអត់ដឹង ។

ស៖ តើលោកនៅចាំទេ តើអ្នកទោសៗដែលគេសួរកន្លែងហ្នឹង អ្នកទោសប្រភេទអី? អ្នកទោសសំខាន់ ឬក៏អ្នកទោសអីពេលដែលគាត់មកនោះ?

ឆ៖ នៅពេលគាត់មកហ្នឹង អ្នកទោសមិនដឹងសំខាន់ មិនសំខាន់ខ្ញុំក៏អត់បានដឹងដែរ ។

ស៖ តើលោកនៅចម្ងាយប៉ុណាពីកន្លែងសួរចម្លើយ ពេលដែលលោកឃើញគាត់ចូលមកកន្លែងបន្ទប់សួរចម្លើយនោះ?

ឆ៖ ខ្ញុំមើលឃើញចម្ងាយប្រហែលជាហាម៉ែត្រ ខ្ញុំនៅដើរតាមផ្លូវ ហើយបែរមុខទៅផ្លូវឯកើតទៅឃើញគាត់ដើរចូលទៅ ។

ស៖ តើលោកបានឃើញជនជាប់ចោទមកជាញឹកញាប់ទៅមើលកន្លែងឃុំខ្លួនដែរឬទេ ដែលចេញមកពី ខាងក្រៅមកខាងក្នុង តើលោកធ្លាប់សង្កេតឃើញគាត់អីចឹងដែរឬទេ?

អ៖ ខ្ញុំធ្លាប់ឃើញគាត់មកយូរៗមកម្តង តែគាត់មិនដែលចូលដល់ក្នុងនឹងគេទេ គាត់នៅតែខាងក្រៅទេ ។

ស៖ សំណួរតើត្រឹមត្រូវទេ គាត់បានមកមើលកន្លែងឃុំខ្លួន ទៅបន្ទប់ឃុំខ្លួន តើគាត់មកពិនិត្យហ្នឹងញឹកញាប់ដែរឬទេ?

អ៖ គាត់មកយូរៗម្តងទេ តែគាត់អត់មានបានចូលទៅខាងក្នុងទេ គ្រាន់តែគាត់មើលពីក្រៅទៅទេ ។

[១១:២០:០០]

ស៖ សំណួរចុងក្រោយរបស់ខ្ញុំទាក់ទងទៅនឹងការធ្វើអត្តឃាត ឬការសម្លាប់ខ្លួននៅស-២១។ ថ្ងៃនេះលោកនិយាយថ្ងៃនេះថា លោកមិនបានដឹងពីការធ្វើអត្តឃាត ឬក៏ការសម្លាប់ខ្លួនឯងរបស់អ្នកទោសទេ ។ ខ្ញុំសូមសួរលោកទាក់ទងទៅនឹងចម្លើយដែលលោកបានផ្តល់ទៅឲ្យ ដេវីដ ឆេនដ៍ល័រ ដែលលោស្រីចៅក្រម ខាតរ៉ាយថ៍ បានសួរបទសម្ភាសន៍នោះដប់ឆ្នាំមកហើយ លេខERN0064564 ជាអត្ថបទភាសាអង់គ្លេសនោះ ។ នៅកន្លែងនោះ លោកនិយាយថា និយាយប្រាប់លោក ឆេនដ៍ល័រ ថាមានករណីជាច្រើនដែលអ្នកទោសធ្វើអត្តឃាត ឬក៏សម្លាប់ខ្លួនឯងតាមរបៀបនេះ ។ ផ្អែកទៅលើសម្តីខាងដើមដែរថា អ្នកខ្លះចងកខ្លួនឯង អ្នកខ្លះគឺថាបាន-- អ៊ីចឹងហើយដែលយើងត្រូវប្រុងប្រយ័ត្នឲ្យក្នុងការការពារ ។ តើលោកនៅចាំទេ ដែលលោកប្រាប់លោក ដេវីដ ឆេនដ៍ល័រ ថាដែលមានករណីដែលអ្នកទោសធ្វើអត្តឃាតហ្នឹងច្រើន?

អ៖ អ្នកហ្នឹង ខ្ញុំនៅចាំ ។ ដូចបញ្ហា ដូចថាអ្នកទោសចងក ចងអី អ៊ីចឹងទៅ ឃើញថាមាន ដល់មានអ៊ីចឹង កម្មាភិបាល គាត់ពង្រឹងជំហរអ្នកការពារហ្នឹង ថាឲ្យប្រុងប្រយ័ត្នយាមឲ្យបានដិតដល់ កុំឲ្យមានបញ្ហាហ្នឹង វាកើតឡើងទៀត ។

ស៖ តើលោកបានឃើញអ្នកទោស លោកឃើញផ្ទាល់ភ្នែកទេ ថាអ្នកទោសចងកខ្លួនឯងនោះ?

អ៖ ខ្ញុំមិនដែលបានឃើញទេ ព្រោះមុខសញ្ញាខុសគ្នា ។

ស៖ ប៉ុន្តែបានប្រាប់ ឬក៏លោកឲ្យគេប្រាប់អំពីការធ្វើអត្តឃាតរបស់អ្នកទោសហ្នឹង ឬយ៉ាងម៉េច?

អ៖ គេបានប្រាប់ខ្ញុំ ដោយសារគេយាមមុខសញ្ញា មានសកម្មភាពអ៊ីចឹងទៅ ដល់ពេលដូរវេនចេញមកជួបគ្នា បានមិត្តយើងប្រាប់អ៊ីចឹងទៅ បានខ្ញុំដឹងនោះ ។

ឆៃ៖ ខ្ញុំចង់ដឹងបន្តទៅទៀត តើលោកនឹកឃើញទេ ថាតើមានមនុស្សប៉ុន្មាននាក់នៅក្នុងក្រុមរបស់លោកជាក្រុមអ្នកយាម?

ឆៃ៖ ចំណែកនៅក្នុងកងខ្ញុំហ្នឹង មានបួនក្រុមសម្រាប់យាមការពារ ដូរគ្នាទៅវិញទៅមក ។ ក្នុងមួយក្រុមមានគ្នាដប់នាក់ ជួនកាលដប់ពីរនាក់ ។

សៈ តើមានប៉ុន្មានក្រុម? ដែរថា មួយក្រុមៗមានដប់ទៅដប់ពីរនាក់ តើមានបាត់មនុស្សក្នុងក្រុមហ្នឹង ប៉ុន្មាននាក់ ក្រោយមកនោះ?

[១១:២៤:០៨]

ឆៃ៖ ក្រោយមកការពារយូរៗទៅ ចេះតែបាត់មនុស្សថយទៅៗ តែចំនួនប៉ុន្មាននាក់ អត់ដឹងផង។ ពេលបាត់ទៅ កម្លាំងចេះតែថែមមកទៀត ។

សៈ តើលោកអាចបញ្ជាក់បានទេ? ខ្ញុំនិយាយអំពីតែក្រុមរបស់លោកទេ គឺក្រុមអ្នកដែលលោកធ្វើការជាមួយគ្នាជិតស្និទ្ធនោះ តើត្រឹមត្រូវទេ ដែលខ្ញុំនិយាយថា លោកៗ-- សមាជិកនៅក្នុងក្រុមរបស់លោក ដូចជា ចាត់ទុកដូចជា បងប្អូន ឬក៏ជាអ្នកជិតសិទ្ធនៅក្នុងការនោះ?

ឆៃ៖ តែនៅក្នុងក្រុមរបស់ខ្ញុំហ្នឹង គ្នាដប់នាក់ហ្នឹង ឃើញថាធ្លាប់ៗនៅមួយគ្នាហ្នឹងយូរៗ ទៅមានបាត់ដែរ ។ បើក្នុងក្រុមខ្ញុំ បាត់អស់ពីរនាក់ ។

សៈ ខ្ញុំចង់សុំសួរបន្តនៅទៀតទៅលើចម្លើយដែលលោកបានផ្តល់បទសម្ភាសន៍ដប់ឆ្នាំហើយនោះ លេខ ERN លេខ 00164580 ហើយនៅកន្លែងនោះ គេសួរលោកដោយ ដេវីដ ឆេនដ៍លែ៍រ បានសួរលោកថាតើមានសមាជិកប៉ុន្មាននៅក្នុងកងរបស់លោកក្រុមរបស់លោក ។ លោកឆ្លើយថា គឺមានមនុស្សម្ភៃនាក់ ហើយអ្នកទាំងអស់នោះត្រូវបានស្លាប់អស់ហើយ លើកលែងតែខ្ញុំពីរនាក់ដែលនៅសេសសល់ ។ ក្រោយមកគេយកអ្នកថ្មីមកជំនួស អ្នកដែលបាត់នោះ នេះគឺវាខុសពីអ្វីដែលលោកបញ្ជាក់នៅពេលនេះ ។ មានន័យថា ចំពោះ ដេវីដ ឆេនដ៍លែ៍រ លោកនិយាយថា សមាជិកភាគច្រើនក្នុងក្រុមរបស់លោកត្រូវបានបាត់ខ្លួន ហើយស្លាប់ ។ តើលោកអាចនៅចាំទេ? ថាតើចំនួនណាដែលត្រឹមត្រូវ? ថាតើក្រុមរបស់មិត្តៗ ឬក៏បងប្អូនរួមក្រុមរបស់លោកហ្នឹង បាត់ខ្លួនប៉ុន្មាននាក់?

ឆៃ៖ តាមចម្លើយថា នៅក្នុងកងម្ភៃនាក់ហ្នឹងមិនពិតប្រាកដទេ ។ ក្នុងកងហ្នឹងប្រហែលជាពីររយនាក់ឯណោះ ។ ដោយនៅជាមួយគ្នាយូរៗទៅ អ៊ីចឹង ចេះតែបាត់ទៅៗ ក៏មិនដឹង-- ខ្ញុំមិនដឹងទៅណាមកណាដែរ ដល់ខ្ញុំពិនិត្យទៅចុងក្រោយនេះ ឃើញថាធ្លាប់ស្គាល់គ្នាហ្នឹង ឃើញថានៅតែពីរនាក់ ។

សៈ នេះមិនមែនជាចម្លើយទៅរបស់ទេ ប៉ុន្តែខ្ញុំនឹងសុំបន្តទៅទៀតនូវចំណុចនេះ ។ តើលោកមានការភ័យខ្លាចទេ? នៅពេលដែលលោកបានសង្កេតឃើញថា មនុស្សកាន់តែច្រើនៅក្នុងក្រុមរបស់លោកត្រូវបានបាត់ខ្លួននោះ ។ តើលោកផ្ទាល់ មានការភ័យខ្លាចទេ កាលនោះ?

ឆៈ កាលពេលនោះ ក៏ក្នុងចិត្តនោះ ក៏ភ័យខ្លាចដែលហ្នឹង ថាមិនដឹងជាថ្ងៃទៅថ្ងៃទេ ប៉ុន្តែនៅលើគោលជំហរ ខំបំពេញការងារហ្នឹងឲ្យខ្លាំងទៅ ក្រែងដូចថាអត់អី ។

[១១:២៨:១០]

សៈ ហើយលោកអាចគ្រប់គ្រងខ្លួនឯងរបៀបមួយ ដែលថាលោកមានការភ័យខ្លាច ទោះបីជាណាក៏ដោយ មិត្រភក្តិអ្នករួមការងារបាត់ច្រើន ក៏លោកនៅតែបន្តការងារតទៅទៀត ។ អ៊ីចឹង គឺថាជារៀបមួយ ដែលលោកអាចរំងាប់ការភ័យខ្លាច ហើយធ្វើការតទៅទៀត តើអ៊ីចឹង ឬយ៉ាងម៉េច?

ឆៈ ពិតមែន អ៊ីចឹងហើយ ។

សៈ ឥឡូវនេះ ខ្ញុំចូលទៅដល់ឆ្នាំ១៩៧៩ ។ នៅចុងឆ្នាំ១៩៧៨ ខ្ញុំចង់ដឹងចំណុចមួយ ថាតើលោកបានទទួលដំណឹងអ្វីទេ នៅក្នុងចុងឆ្នាំ១៩៧៨ ហើយនៅដើមឆ្នាំ១៩៧៩ ដែលថាកងទ័ពវៀតណាមនិងចូលឈ្លានពាន ឬឈ្លានពាន ឬក៏ត្រៀមនឹងចូលមកស្រុកខ្មែរ តើលោកបានទទួលដំណឹងបែបនេះដែរឬទេ?

ឆៈ ខ្ញុំអត់បានមានទទួលដំណឹងផង ។

សៈ អ៊ីចឹង ខ្ញុំក៏សុំសួរបន្តទៅទៀតនូវចម្លើយរបស់លោកដែលលោកបានផ្តល់បទសម្ភាសន៍ដប់ឆ្នាំកន្លងទៅហើយ នៅក្នុងលេខ 00164572 ។ លោកឆ្លើយទៅនឹងសំណួរមួយដែលលោកប្រាប់លោក ដេវីដ ឆេនដ៍លែរ ថា *(ខ្ញុំដកស្រង់សម្តីលោក)* “ប្រហែលជាពីរសប្តាហ៍ មុនពេលដែលកម្លាភិបាលកោះហៅឲ្យមានប្រជុំ គេបានប្រាប់យើងអំពីរឿងនេះ ហើយនេះពេលនោះ លោកនិយាយថា ការចូលឈ្លានពានរបស់វៀតណាម” ។ សំណួរខ្ញុំ តើលោកនៅនឹកឃើញ-- លោកនឹកឃើញទេ ដែលថាមានការប្រជុំមួយ ពីរសប្តាហ៍មុនពេលដែលទ័ពវៀតណាមចូលមកនោះ?

ឆៈ កាលពេលនោះ ប្រជុំអ៊ីចឹង ប្រជុំកងរយ តែក៏អត់មានយោបល់ប្រាប់មកថា ឲ្យមិត្តយើងទាំងអស់ហ្នឹងសន្សំសំចៃឲ្យមែនទែន ។ ពីត្រឹមថ្ងៃនេះទៅ មិនដឹងយើងដេកផ្ទះ ហើយដេកក្នុងព្រៃទេ ។ ហ្នឹង គ្រាន់តែបានថាអ៊ីចឹង ។

សៈ តើនៅពេលណាដែលលោកបានចាកចេញពីស-២១ ទៅនោះ? តើពេលចុងក្រោយ ដែលលោកនៅស-២១ នោះ គឺខ្ញុំនិយាយត្រង់ចំណុចពេលពីឆ្នាំ១៩៧៨ និង១៩៧៩?

ឆេ៖ មុននឹងខ្ញុំចេញពីស-២១ ហ្នឹងទៅ មុនបែកនឹងប្រហែលជាកន្លះខែ ជាងកន្លះហ្នឹង ខ្ញុំចេញពីមន្ទីរស-២១ ទៅនៅស-២១ ដែរ ប៉ុន្តែនៅកន្លែងស្រែ ទៅធ្វើស្រែឯណោះ លិចឯណោះទៅពីខាងត្បូងកន្លែងគុកព្រៃសឯណោះ នៅធ្វើស្រែធ្វើចម្ការឯណោះទេ ។

[១១:៣២:១៦]

សៈ តើលោកបានត្រឡប់ទៅស-២១ វិញដែរឬទេ?

ឆេ៖ ដល់ពេលចុងក្រោយហ្នឹង គឺអត់បានត្រឡប់ចូលមកវិញទេ ។ ដល់ពេលយួនវៀចូលមកស្រុកមក ខ្ញុំនៅឯស្រែនុំង ក៏នាំគ្នារត់ទៅលិចបណ្តោយទៅ ។

សៈ ខ្ញុំនឹងសួរលោកតទៀត អំពីចម្លើយដែលលោកបានផ្តល់ទៅឲ្យ លោក ដេវីដ ឆេនដ៍លែរ ត្រង់លេខ ERN លេខ 00 ដូចលេខ ERN ខ្ញុំហៅខាងដើមនោះ គឺនៅកន្លែងនោះ គេសួរលោកថា នៅពេលដែលលោកចាកចេញទៅ ហើយទ័ពវៀតណាមក៏បានចូលមកដល់ ។ បន្ទាប់មកទៀត លោកបានឆ្លើយថា មុនពេលដែលយើងចេញទៅ ពួកគេបានមកដល់ច្បារអំពៅ ស្ពានមុនីវង្សទៅហើយ ។ តើលោកនៅចាំសម្តី ដែលលោក ដែលថាលោកនៅស-២១ ដែលថាពួកទ័ពវៀតណាម គេចូលមកដល់ស្ពានមុនីវង្សនោះ?

ឆេ៖ កន្លែងហ្នឹង ក៏ខ្ញុំអត់ដឹងដែរ ភ្លេចអស់ហើយ ។

សៈ ហើយខ្ញុំសោកស្តាយណាស់ ដែលថានេះជាសំខាន់ ជាពេលសំខាន់ដែលទ័ពវៀតណាមចូលមកដល់ភ្នំពេញ ហើយលោកបញ្ជាក់ថា លោកមិនបានដឹងពីរឿងហ្នឹង ។ អ៊ីចឹង ខ្ញុំសុំបន្តទៅទៀតប្រយោគមួយ សួរថានៅពេលដែលលោកត្រូវត្រឡប់មកវិញស-២១ វិញទេ ដែលលោកប្រាប់លោក ដេវីដ ឆេនដ៍លែរ ថាលោកត្រឡប់មកយកឯកសារបានតែប្រហែលជា១/៣ ឯកសារនោះទេ ។ តើលោកនៅចាំថា លោកបានមកប្រមូលយកឯកសារ មកពីនៅស-២១ ទេ ដែលថា ដាក់នៅក្នុងទូខោអាវនោះ?

ឆេ៖ ហ្នឹង ក៏ខ្ញុំអត់ដឹងដែរ ។ ខ្ញុំអត់មានបានត្រឡប់មកវិញផង ។ អត់មានបានចូលមកដល់ផ្ទះបានយកខោអាវអីណា ឯកសារអី អត់ទាំងអស់ ចោលនៅនឹងផ្ទះហ្នឹងទាំងអស់ ។ អត់មានបានចូលមកទេ ។

[១១:៣៥:០០]

សៈ អ៊ីចឹង សំណួររបស់ខ្ញុំ គឺដកស្រង់ចុងក្រោយដែលលោកបានឆ្លើយប្រាប់លោក ដេវីដ ឆេនដ៍លែរ នៅក្នុងទំព័រដដែល គេសួរថាតើលោកបានដុតចោលឯកសារនៅគុកនោះទេ? លោកឆ្លើយថា (ខ្ញុំដក

ស្រង់សម្តីលោក) លោកឆ្លើយថា ទេ យើងបានយកឯកសារហ្នឹងទៅឆ្ងាយ ហើយឯកសារខ្លះជ្រុះរប៉ាត់រប៉ាយតាមផ្លូវដែលយកមកពីស-២១ ដែលខ្ញុំយកពីទូខោអាវមកពីស-២១" តើលោកនៅចាំទេ?

ឆៃ៖ ហ្នឹងកន្លែងហ្នឹងក៏ខ្ញុំអត់មានមកយកឯកសារថា យកទៅណាៗ គឺក្រសួងខ្ញុំអត់មានត្រូវការវិលចូលមកយកឯកសារវិញទេ ។ ចម្លើយនេះមិនពិតប្រាកដទេ ។

លោកស្រី ស៊ីលវី ស្វូតហ្សីនស្តី៖

សូមអរគុណលោកប្រធាន ។ ឥឡូវនេះ ខ្ញុំអស់ពេលដែលបានកំណត់ហើយ ហើយខ្ញុំមានសំណួរច្រើនទៀត យើងមានសំណួរច្រើនទៀត ប៉ុន្តែយើងមិនមានពេលដើម្បីនឹងសួរទេ ។ សូមអរគុណ លោកប្រធាន។ សូមអរគុណលោក គក ស្រស់ ។

ប្រធានអង្គជំនុំ៖

អ៊ីចឹងខ្ញុំប្រគល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការសួរដល់សាក្សីរូបនេះប្រសិនបើមាន ។ សូមអញ្ជើញលោកមេធាវី ។

សួរដោយលោក ការ សារុត្ថ៖

សូមអរគុណលោកប្រធាន ។ សូមគោរពលោកប្រធាន សូមគោរពលោកចៅក្រមជាតិ និងអន្តរជាតិ ។ សូមគោរពអង្គសវនាការ ។

ស៖ លោក គក ស្រស់ នៅក្នុងឯកសារ ERNលេខ 00186796 D78/10នៅបន្ទាត់ទីមួយខាងក្រោមបំផុតលោកបានឆ្លើយថា "ខ្ញុំបានត្រូវអង្គការចាត់តាំងឲ្យខ្ញុំទៅគុកធំ ប៉ៃហ្សឺ នៅខាងត្បូងផ្សារធំថ្មី ខ្ញុំនៅទីនោះបានមួយឆ្នាំមួយថ្ងៃ ។ អ្នកដឹកនាំនៅទីនោះគឺ ឌុច" ។ អ៊ីចឹងតើលោកមានស្គាល់លោក អ៊ុន លន ហៅ ណាត ឬទេពេលនោះ?

ឆៃ៖ ពេលនោះខ្ញុំអត់ស្គាល់ផង ។

ស៖ សូមអរគុណ ។ តើពេលមួយរយៈពេលដែលលោកការពារនៅស-២១ តើលោកដែលឃើញមានអ្នកទោសជាទាហានវៀតណាមដែរឬទេ?

[១១:៣៨:១៣]

ឆៃ៖ ពេលដែលខ្ញុំការពារហ្នឹងឃើញតែវៀតណាមទេ ទាហានអត់មានឃើញទេ ឃើញតែស្លៀកពាក់ស៊ីវិល ។

សៈ សូមអរគុណ ។ អ៊ីចឹង លោកការពារនៅស-២១ លោកអត់ដែលឃើញមានអ្នកទោសជាទាហានវៀតណាមទេ ។ សំណួរមួយទៀត លោកថា លោកមិនដែលឃើញ ឌុច សួរចម្លើយ និងធ្វើទារុណកម្ម ឬសម្លាប់អ្នកទោសទេ អ៊ីចឹងត្រូវឬខុស? តើលោកយល់ស្របហ្នឹងចម្លើយហ្នឹងទៀតទេ?

ឆៃ យល់ស្រប ។

សៈ សូមអរគុណ ។ លោកថា ឌុច ជាអ្នកបញ្ជាឲ្យយកទៅសម្លាប់។ តើលោកមានដឹងទេថាតើអ្នកណាជាអ្នកបញ្ជាពីលើតាឌុចទៀត លោកមានដឹងទេសូមលោកបញ្ជាក់មើល?

ឆៃ នៅចំណុចហ្នឹងក៏ខ្ញុំអត់បានដឹងដែរ ។

សៈ សូមអរគុណ ។ លោកជាអ្នកការពារនៅទីនោះ តើលោកធ្លាប់ឃើញមានការដោះលែងជនជាតិថៃនៅស-២១ ឬទេ?

ឆៃ ចំណុចហ្នឹងក៏អត់ដែលឃើញដែរ ។

សៈ សូមអរគុណ ។ នៅក្នុងក្រុមរបស់លោក តើអ្នកណាជាមេក្រុមផ្ទាល់របស់លោក?

ឆៃ នៅក្នុងក្រុមខ្ញុំហ្នឹង ខ្ញុំភ្លេចឈ្មោះគាត់ហើយ ។

សៈ អ៊ីចឹងលោកភ្លេចឈ្មោះមេក្រុមរបស់លោកហើយ ។ អ៊ីចឹងសំណួរមួយទៀត ។ អ៊ីចឹងអ្នកណាដែលជាមេរបស់មេក្រុមរបស់លោកដែលត្រួតពីលើមេក្រុមរបស់លោកនោះ តើលោកមាននៅចាំឈ្មោះទេ?

ឆៃ អ្នកដែលត្រួតនៅលើមេក្រុមរបស់ខ្ញុំទៀតគឺឈ្មោះ ប៉ែង ។

សៈ សូមអរគុណ ។ តើមុខងាររបស់មេក្រុមរបស់លោកគេធ្វើអីខ្លះ សូមលោកជួយបញ្ជាក់មើល?

ឆៃ មុខងាររបស់មេក្រុម កាលណាពេលចូលការពារទៅនាទីរបស់មេក្រុមដើរត្រួតពិនិត្យមើលសមាជិកដែលយាមតាមមុខសញ្ញារៀងៗខ្លួនហ្នឹង ដើម្បីការពាររឿងងោកងុយ ជួយដាស់គ្នា ។

[១១:៤១:១៤]

សៈ សូមអរគុណ ។ ចុះមុខងាររបស់មេធំដែលត្រួតពីលើមេក្រុមហ្នឹង តើគេមានមុខងារធ្វើអីខ្លះ លោកមានដឹងទេ សូមជួយបញ្ជាក់ផង?

ឆៃ មុខងាររបស់កងរយ គាត់ប្រចាំនៅមុខអគារឃុំឃាំងហ្នឹង សម្រាប់ពិនិត្យមើលការចេញចូលអ្នកទោសដែលយកទៅសួរចម្លើយហ្នឹង ។

សៈ សូមអរគុណ ។ អ៊ីចឹងតើលោកមានដឹងទេ? តើមុខងាររបស់ប្រធានស-២១ តាឌុច ហ្នឹង គាត់មានធ្វើអីខ្លះបានជាដើរទៅតាមអើតតាមបន្ទប់? បើលោកបានឆ្លើយថា តាឌុច ធ្លាប់បានឃើញ អើតតាមបន្ទប់អីនោះ តើមុខងាររបស់ តាឌុច ហ្នឹងគាត់ធ្វើអីខ្លះបានជាគាត់ដើរអើតតាមបន្ទប់? សូម លោកជួយបញ្ជាក់ ។

[១១:៤២:១៣]

អេ បញ្ហាមុខងាររបស់គាត់គឺថាទូទៅតែម្តង អត់មានចាំថាអ្នកណាបញ្ជាគាត់ទេគឺគាត់ធំជាងគេ ស្រេចតែគាត់ គាត់ដើរមើលនេះ មើលនោះទៅអាហ្នឹងស្រេចតែគាត់ទេ ការងាររបស់គាត់ ខ្ញុំក៏មិន បានដឹងដែរ ឃើញតែដើរអ៊ីចឹងពិនិត្យមើលខ្លះទៅធ្វើការរបស់គាត់ទៅ ។

លោក ការ សារុត្ថ៖

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ ។

ប្រធានអង្គជំនុំ៖

ជាចុងក្រោយនេះអង្គជំនុំជម្រះប្រគល់នាទីនៃពេលវេលាសម្រាប់ជនជាប់ចោទ អាចធ្វើការកត់ សម្គាល់ទ្វេសក្តីកម្មរបស់សាក្សីរូបនេះដែលបានឆ្លើយរួចមកហើយ ហើយបើសិនជាមានបំណង។ ទីពីរគឺ អង្គជំនុំជម្រះបញ្ជាក់ថា ការធ្វើការកត់សម្គាល់នេះគឺជនជាប់ចោទនិយាយឱ្យអង្គជំនុំជម្រះទាំងមូលស្តាប់ ជាពិសេស គឺអង្គជំនុំជម្រះនៃសាលាដំបូងនៃអង្គចៅក្រម ចៀសវាងប្រើអាកប្បកិរិយា ឬពាក្យសម្តី ដាក់សម្ពាធទៅលើសាក្សី ដែលជាកំហុសមិនមែនជានីតិវិធីទេនោះ សូមអញ្ជើញ ។

ជនជាប់ចោទ៖

សូមអរគុណលោកប្រធាន ។ សូមជម្រាបបញ្ជាក់បញ្ហាដូចតទៅ៖ ឈ្មោះ គក ស្រស់ នេះខ្ញុំចាប់ អារម្មណ៍តាំងពីពេលដែលខ្ញុំអានសៀវភៅរបស់ ដេវីដ ឆេនដ៍លែ នេះមកម្ល៉េះ ។ ខ្ញុំនៅរង់ចាំមើលតើអ្នក ណាជា គក ស្រស់? ពេលដែលមកនៅក្នុងអង្គសវនាការនេះខ្ញុំខំសម្លឹងមុខ តែរកនឹកមិនឃើញ ។ ថាខ្ញុំ ធ្លាប់ឃើញកាលនៅស-២១ នឹកមិនឃើញថាខ្ញុំធ្លាប់ឃើញទាល់តែសោះ នៅតែនឹកថាខ្ញុំមិនធ្លាប់ឃើញ ។ នេះទីមួយ ។

[១១:៤៤:២៦]

ទីពីរទៀត ខ្ញុំសូមនិយាយអំពីសក្តីភាព សក្តីកម្មរបស់លោក គក ស្រស់ ដែលខ្ញុំមិនទទួលស្គាល់។ លោក គក ស្រស់ មានប្រសាសន៍ថា ខ្ញុំទៅអើតមន្ទីរឃុំឃាំងយូរៗម្តង បើយើងស្តាប់ដូចទំនងមែន ។

ក៏ប៉ុន្តែ តាមពិតខ្ញុំអត់ទៅអើតទេ ។ ខ្ញុំសូមបដិសេធថា នេះជាសក្ខីកម្មដែលធ្វើមិនឲ្យខ្ញុំជឿ ថាលោក គក ស្រស់ ជាបុគ្គលិករបស់មន្ទីរស-២១ ។

ទីពីរ សក្ខីកម្មដែលនាំឲ្យខ្ញុំមិនជឿថាលោក គក ស្រស់ ជាបុគ្គលិករបស់មន្ទីរស-២១ គឺគាត់មានប្រសាសន៍ថា ខ្ញុំបង្រៀនកងការពារអំពីគោលនយោបាយចំពោះខ្មាំងជាក់លាក់ដែលជាអ្នកទោសនៅស-២១ ។ បើកាលណាខ្ញុំបង្រៀនកងការពារមែន និយាយអំពីសភាពការណ៍ទូទៅនិយាយអំពីខ្មាំងជារួមនៅតាមឯកសារដែលបក្សកំណត់ គឺខ្មាំងទូទាំងប្រទេស។ ដូច្នេះ ដល់និយាយថាខ្ញុំបង្រៀនកងការពារអំពីខ្មាំងជាក់លាក់ដែលទៅជាប់គុកនៅមន្ទីរស-២១ មិនមែនទេ ។ សក្ខីកម្មនេះធ្វើឲ្យខ្ញុំមិនជឿទៀត ថាលោក គក ស្រស់ ជាបុគ្គលិករបស់មន្ទីរស-២១ ។

បញ្ហាទីបី ដែលលោក គក ស្រស់ មានប្រសាសន៍ថា ខ្ញុំបានឲ្យអ្នកទោសទៅជួសជុល ឬក៏ទៅថតឯកសារ ។ សក្ខីកម្មនេះធ្វើឲ្យខ្ញុំមិនជឿថាលោក គក ស្រស់ ជាបុគ្គលិករបស់មន្ទីរស-២១ ។ សូមបញ្ជាក់ថា នៅស-២១ មានម៉ាស៊ីន បែបនេះបី ។ ម៉ាស៊ីនទីមួយ គឺម៉ាស៊ីនថតឯកសារដែលយើងហៅថាហ្វូតូកូពី ។ ម៉ាស៊ីនទីពីរ គឺម៉ាស៊ីនអេឡិចត្រូនិចសម្រាប់ ដាក់*ស្តេបស្ទិនស៊ីល* ។ ម៉ាស៊ីនទីបី គឺម៉ាស៊ីន*រ៉ូណេអូ* ។ ម៉ាស៊ីនេះ ជា កេរតំណែលពី ៧០៣មក ។ មុននឹងខ្ញុំឡើងធ្វើជាប្រធាន បុគ្គលិករបស់មន្ទីរស-២១ ដែលមានកំណើតពី៧០៣ គេចេះ គេម្ចាស់ការហើយ ។ ថ្វីត្បិតតែម៉ាស៊ីនទាំងបីនេះមេឲ្យខ្ញុំយកមកទុកនៅផ្ទះខ្ញុំ ចៀសវាងកុំឲ្យគេប្រើពាសវាលក៏ដោយ ក៏ពេលណាខ្ញុំត្រូវការប្រើខ្ញុំហៅបុគ្គលិកស-២១ យកទៅប្រើអត់មានយកអ្នកទោសទៅប្រើទេ ។ ដូច្នេះ សក្ខីកម្មនេះនាំឲ្យខ្ញុំមិនជឿទៀត ថាលោក គក ស្រស់ ជាអតីតកងការពាររបស់ស-២១ ។

[១១:៤៧:០៨]

តទៅនេះ ខ្ញុំសូមជូនជាព្រឹត្តិការណ៍ដែលខ្ញុំសុំសង្កេត ។ លោក គក ស្រស់ អត់ស្គាល់ អ្នកណាច្បាស់លាស់ក្រៅពីមនុស្សដែលសាធារណជនស្គាល់ហើយគឺ ប៉ែង គឺមិត្ត ហ៊ុយ ស្រែ, គឺមិត្ត ហ៊ុយ ភ្នំពេញ គឺមិត្តហ៊ គឺខ្ញុំ ។ ក្រៅពីនោះសូម្បីតែមេខ្ញុំ មេស-២១ ដំបូងគឺបងណាត ក៏លោក គក ស្រស់ លោកអត់ស្គាល់ ។ សក្ខីកម្មនេះធ្វើឲ្យខ្ញុំកាន់តែមិន-- សូមជូនជាសេចក្តីសង្កេតថា វាមិនបង្ហាញថា លោក គក ស្រស់ ជាអតីតកងការពាររបស់មន្ទីរស-២១ ទេ ។ ហើយចុងបញ្ចប់ខ្ញុំសូមជូនភស្តុតាងមួយទៀតដែលធ្វើខ្ញុំជូនជាការសង្កេត ។ លោក គក ស្រស់ មានប្រសាសន៍អំពីប្រជុំជីវភាពដែល ពេញ ដឹកនាំ ។ លោកមានប្រសាសន៍ជាទូទៅ ហាមមិនឲ្យអ្នកទោសរត់ហាមមិនអី។ ក៏ប៉ុន្តែ បើសិនធ្វើជីវភាពគាត់ធ្លាប់

រស់នៅក្រោមការគ្រប់គ្រងរបស់មិត្ត ប៉ែង មែន ខ្ញីមសារដែលប្រជុំត្រូវស្របទៅតាមឯកសារដែលមានចំណងជើងថា "សារាចរ" ស្នើមិត្តទាំងអស់អនុវត្តន៍តាមសាចរឲ្យបានដាច់ខាត ។ ជាឯកសារមន្ទីរ សដ-២១ ដែលមានលេខ ERN00008091 ។ បើសិនជាមិត្ត ប៉ែង ប្រជុំមែនត្រូវតែអនុវត្តន៍យកឯកសារនេះទៅប្រជុំ ។ សរុបមក មានបញ្ហាជាច្រើនដែលធ្វើឲ្យខ្ញុំចាប់អារម្មណ៍ថា លោក គក ស្រស់ មិនមែនជាអតីតកងការពារមន្ទីរសដ-២១ ។ តែខ្ញុំមិនទាន់ប៉ានបដិសេធទេ ។ ប្រសិនបើការិយាល័យព្រះរាជអាជ្ញាលោកបង្ហាញបញ្ជីបុគ្គលិករបស់សដ-២១ ជូនតុលាការទាំងមូល អាហ្នឹងវាស្រួលវិនិច្ឆយ ។ នេះខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ។

ប្រធានអង្គជំនុំ៖

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក។

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖

ស៖ ចំពោះខ្ញុំ បន្ទាប់ពីការផ្តល់ចម្លើយទាំងអស់នេះ គឺសាក្សីគួរតែអនុញ្ញាតឲ្យផ្តល់ការបញ្ជាក់នូវអ្វីដែលខ្ញុំទើបតែឮពីជនជាប់ចោទ ។ ហើយជាពិសេសសាក្សីគាត់អាចបញ្ជាក់ដែរឬទេ? ថាតើសាក្សីនេះ ធ្លាប់ជាបុគ្គលិកនៅសដ-២១ ដែរឬទេ?

[១១:៥០:០០]

ឆ៖ ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ ខ្ញុំជាបុគ្គលិកនៅមន្ទីរសដ-២១ហ្នឹង តាំងពីឆ្នាំ៧៥រហូតមកដល់ ពីចុងឆ្នាំ៧៥ រហូតមកដល់ពេលបែកភ្នំពេញហ្នឹងរហូត ។ សូមអស់យោបល់ ។

ចៅក្រម ហ្សង់ម៉ាក ឡាវែន៖

ដូច្នេះ តាមអ្វីដែលខ្ញុំយល់ពីជនជាប់ចោទនោះគឺថា ដរាបណាយើងមិនមានឯកសារជាលាយ-លក្ខណ៍អក្សរដែលឯកសារទាំងអស់នោះ អាចបញ្ជាក់ទៅលើបញ្ហាទាំងអស់នេះបាន ជនជាប់ចោទជឿថាចម្លើយរបស់លោក គក ស្រស់ គឺនៅមានមន្ទិលសង្ស័យ ។ នេះគឺជាអ្វីដែលលោកជនជាប់ចោទបានលើកឡើងឬក៏យ៉ាងម៉េច? ប៉ុន្តែប្រសិនបើខ្ញុំផ្តល់ឯកសារជាលាយលក្ខណ៍អក្សរជូនលោក ហើយបញ្ជាក់ថា លោកសាក្សី គឺជាបុគ្គលិកមួយនៅសដ-២១ នៅពេលនោះជនជាប់ចោទ ទើបគាត់ទទួលស្គាល់ ឬក៏យ៉ាងម៉េច?

ជនជាប់ចោទ៖

ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំសូមបញ្ជាក់ថា បញ្ជីបុគ្គលិករបស់មន្ទីរសដ-២១ តាំងពីខ្ញុំ

ចូលមក តាំងពីសម័យស៊ើបអង្កេតម្ល៉េះ មិនដែលឃើញសហព្រះរាជអាជ្ញាប្រគល់ជូនតុលាការទេ អត់សោះ នេះបញ្ហាទីមួយ ។ បញ្ហាទីពីរ ដោយឡែកចំពោះលោក គក ស្រស់ ហើយនិងអ្នកផ្សេងទៀតដែលប្រកាសតាំងខ្លួនថាជាបុគ្គលិករបស់មន្ទីរស-២១ មានមនុស្សមួយចំនួនដែលខ្ញុំមិនស្គាល់សោះ ធ្វើឲ្យខ្ញុំសង្ស័យ ។ ប្រសិនបើឃើញឯកសារពិតរបស់មន្ទីរស-២១ អំពីបញ្ជីឈ្មោះរបស់បុគ្គលិកស-២១ ខ្ញុំទទួលដោយឥតលក្ខខណ្ឌ ថាមនុស្សហ្នឹងពិតជាបុគ្គលិករបស់មន្ទីរស-២១មែន ។ នេះគឺសូមបញ្ជាក់ជូនប៉ុណ្ណោះ សូមចប់ ។

ចៅក្រម ហ្សង់ម៉ាក ឡាវែន៖

តើលោកអាចជម្រាបអង្គជំនុំជម្រះនៅថ្ងៃនេះដែរឬទេថា លោកខ្លួនឯងស្គាល់រាល់និងគ្រប់បុគ្គលិកទាំងអស់នៅ ស-២១ ឬក៏លោកអត់ស្គាល់គ្រប់ទាំងអស់ទេ?

ជនជាប់ចោទ៖

ជម្រាបប្រសាសន៍លោកចៅក្រម បុគ្គលិករបស់មន្ទីរ ស-២១ ដែលមកពី ម-១៣ ខ្ញុំស្គាល់ទាំងអស់ អត់ចន្លោះមនុស្សម្នាក់ទេ ដូចជា បង ម៉ម ណៃ ហៅ ចាន់, ទុង ស៊ុនហឿន ហៅ ប៉ុន, មិត្ត ប្រាក់ ណាន, មិត្តអ៊ុន, មិត្តអឿន, មិត្តទិត ខ្ញុំស្គាល់អត់ចន្លោះទេ ។ ដោយឡែក បុគ្គលិកដែលមកពីកម្លាំងតស៊ូខាងក្រុងភ្នំពេញ មកប្រាំនាក់ ខ្ញុំនៅចាំឈ្មោះទាំងប្រាំនាក់ អត់ចន្លោះទេ ។ បុគ្គលិករបស់មន្ទីរស-២១ ដែលមកពី៧០៣ ខ្ញុំស្គាល់មួយចំនួន មិត្តហ៊ិ, មិត្ត ហ៊ុយ ស្រៃ, មិត្តហ៊ុយ កងពិសេស មិត្តផល មិត្តស្ងួន, មិត្ត ប៉ូច មិត្តអ្នកសួរចម្លើយប៉ុន្មាននាក់ផ្សេងទៀត ខ្ញុំស្គាល់ ។ ដូច្នេះ អ្នកណាដែលខ្ញុំស្គាល់ ដូច សួស ធី អ៊ី មិនបាច់បើកបញ្ជីទេ ចេញមកទទួលស្គាល់ភ្លាម អត់ប្រកែក ។

ដូច្នេះ ខ្ញុំសូមសរុបខ្លីប៉ុណ្ណោះ បុគ្គលិករបស់មន្ទីរ៧០៣ អ៎ន!មកពី៧០៣ ខ្ញុំរាប់មិនទាន់អស់ទេ ខ្ញុំនឹងរាប់ បើសិនជាលោកចៅក្រមអនុញ្ញាតឲ្យខ្ញុំរាប់ ។

[១១:៥៤:៣៨]

ចៅក្រម ហ្សង់ម៉ាក ឡាវែន៖

ដូច្នេះហើយ តើលោកអាចបញ្ជាក់រំឭកឡើងវិញជូនយើងខ្ញុំដែរឬទេ អំពីចំនួនមនុស្សដែលធ្លាប់ជាបុគ្គលិកស-២១ ហើយមកពី៧០៣ ជាពិសេសអ្នកដែលមានពីម-១៣ តើលោកអាចបញ្ជាក់ទេ គឺថាជាងប៉ែតសិបភាគរយ គឺបុគ្គលិកមកពីកងពល៧៣០ ឬក៏យ៉ាងម៉េច?

ជនជាប់ចោទ៖

ជម្រាបប្រសាសន៍លោកចៅក្រម! ស្តិតដែលយើងយកបានពីសេនាធិការហើយ ដែលការិយាល័យសហព្រះរាជអាជ្ញា ដាក់ជូនតុលាការមាន ពីរពាន់បីរយប្តាយនាក់ ។ ERN ខ្ញុំភ្លេចហើយ បញ្ជីនោះគឺអត់បានយកមកទេ ពីរពាន់បីរយប្តាយនាក់ ។ ក្នុងចំណោមពីរពាន់បីរយប្តាយនាក់នេះ មកពីម-១៣ គិតទាំងក្មេង ទាំងចាស់ រួមទាំងម្តាយធម៌ឪពុកធម៌ខ្ញុំ ដែលខ្ញុំយកពីអមលាំងផង ទាំងអស់ដប់ប្រាំពីរនាក់នេះមកពីខាងម-១៣ ។ ចំណែកមកពីខាងក្រុងភ្នំពេញ មានប្រាំនាក់ប្រុសៗ មានបីនាក់មានប្រពន្ធហើយស្រេចមានកូន ។ ឯចំណែកពីរនាក់ទៀត ទើបតែនឹងការនៅពេលមកនៅស-២១ នេះកម្លាំងខាងក្រុង ។ ទន្ទឹមនេះ មានកម្លាំងយុវជនក្មេងជំទង់ដែលមកពីកំពង់ឆ្នាំងប្រហែលជាសែសិបនាក់ ។ ក្នុងចំណោមសែសិបនាក់នេះ ខ្ញុំស្គាល់ច្បាស់ប្អូននាក់ ស្គាល់ឈ្មោះ ស្គាល់មុខ ខ្ញុំស្គាល់ច្បាស់ប្អូននាក់ ។ ក្រៅពីនោះសុទ្ធតែពួក៧០៣ទាំងអស់ឫកទៅលើសពីកៅសិបប្រាំភាគរយនៃសមាសភាពស-២១ដែលមកពី៧០៣។

នេះសូមបញ្ជាក់ជូនលោកចៅក្រមប៉ុណ្ណោះ ។ សូមគោរព ។

[១១:៥៦:៤១]

ចៅក្រម ហ្សង់ម៉ាក ឡាវែន៖

ដូច្នេះ ចំពោះមនុស្សជាងពីរពាន់បីរយនេះដែលលោកបាននិយាយ លោកថាស្គាល់ជាងមួយរយនាក់ តើអ៊ីចឹងទេ?

ជនជាប់ចោទ៖

ជម្រាបប្រសាសន៍លោកចៅក្រម! មិនដល់ទេ មិនដល់មួយរយនាក់ទេ តិចណាស់ ។

ចៅក្រម ហ្សង់ម៉ាក ឡាវែន៖

ខ្ញុំពុំមានសំណួរបន្ថែមទៀតទេ សូមអរគុណលោកប្រធាន ។

[១១:៥៧:២០]

ប្រធានអង្គជំនុំ៖

ឥឡូវនេះ ដំណើរការនៃនីតិវិធីពិភាក្សាដេញដោល ស្តាប់សក្ខីកម្មសាក្សី គក ស្រស់ បានដល់ទីបញ្ចប់ហើយ ហើយមកដល់ពេលនេះក៏ត្រូវពេលពិសាអាហារថ្ងៃត្រង់ផង អង្គជំនុំជម្រះនឹងផ្អាកសវនាការសម្រាប់ព្រឹកនេះត្រឹមនេះ ហើយសវនាការបន្តទៅពេលរសៀល ។ លោក គក ស្រស់ ហើយអង្គជំនុំជម្រះអរគុណដល់លោក ដែលបានអញ្ជើញមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលា

ដំបូង តាមការកោះហៅ ហើយយើងក៏មានការកត់សម្គាល់ថា អំពីការលំបាកលំបិនរបស់លោកដែរនៅក្នុងការដែលអញ្ជើញមកផ្តល់សក្ខីកម្មនៅទីនេះ ដោយហេតុផលនៃការប្រឈមនឹងសំណួរជាច្រើនពីអង្គជំនុំជម្រះនិងពីភាគីនានា ហើយដែលត្រូវស្នូរលោក។ ហើយទីពីរ គឺហេតុផលនៃអង្គហេតុដែលកើតឡើងជាយូរឆ្នាំហើយ អង្គហេតុខ្លះសាមសិបឆ្នាំ ហើយអង្គហេតុខ្លះ គឺរហូតដល់សាមសិបប្រាំឆ្នាំ សាមសិបបួនឆ្នាំហើយ ។ បើគិតពីឆ្នាំ៧៤,៧៥,៧៦ គឺ៣៤,៣៣ឆ្នាំមកហើយនោះ គឺរយៈពេលវែង ហើយការចងចាំរបស់មនុស្សទូទៅក៏មានកម្រិតដែរ កាលណារយៈពេលកាន់តែវែង គឺមានការភ្លេចភ្លាត់ភ្លេចខ្លះដូច្នេះ ។ ក៏ប៉ុន្តែទោះបីយ៉ាងម៉េចក៏ដោយ អង្គជំនុំជម្រះអរគុណ ហើយដោយសារនីតិវិធីនៃការស្តាប់សក្ខីកម្មរបស់លោក គឺបានចប់សព្វគ្រប់ហើយ ។ អ៊ីចឹង គឺលោកអាចត្រឡប់ទៅលំនៅដ្ឋានរបស់លោកវិញបានហើយ ។

មន្ត្រីតុលាការរៀបចំសម្របសម្រួលដល់លោក គក ស្រស់ ដើម្បីទំនាក់ទំនងជាមួយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើម្បីរៀបចំគាត់ បានត្រឡប់ទៅលំដ្ឋានរបស់គាត់វិញ ។ ដោយឡែកនៅរសៀលនេះចាប់ពីម៉ោងមួយកន្លះ អង្គជំនុំជម្រះនឹងចាប់ផ្តើមធ្វើការស្តាប់នូវសក្ខីកម្មសាក្សីមួយរូបទៀត គឺKW-07 ចាប់ពីម៉ោងមួយសាមសិបនាទីរសៀលនេះ ។ អ៊ីចឹង អង្គជំនុំជម្រះប្រកាសសម្រាកសម្រាប់ព្រឹកនេះត្រឹមនេះ ហើយតទៅរសៀល ។

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់មកកាន់បន្ទប់សវនាការនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី ។

លោកស្រី សែ កុលវុឌ្ឍី៖

សូមអញ្ជើញក្រោកឈរឡើង ។

[សវនាការសម្រាកពីម៉ោង ១២:០០នាទី ដល់ម៉ោង ១៣:៣៣នាទី]

ប្រធានអង្គជំនុំ៖

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោល ដោយស្តាប់សក្ខីកម្មសាក្សីជាបន្ត ។

1 មន្ត្រីតុលាការអញ្ជើញសាក្សី សួស ធី មកកាន់បន្ទប់សវនាការ ។

2 *[លោក សួស ធី ចូលមកកាន់បន្ទប់សវនាការ]*

3 **សួរដោយប្រធានអង្គជំនុំ៖**

4 **ស៖** សាក្សី តើលោកមានឈ្មោះអ្វីដែរ?

5 **លោក សួស ធី៖**

6 **ឆ៖** ខ្ញុំបាទឈ្មោះ សួស ធី ។

7 **ស៖** លោកមានឈ្មោះហៅផ្សេង ក្រៅពីឈ្មោះ ធី ដែរឬទេ?

8 **ឆ៖** ខ្ញុំអត់មានឈ្មោះផ្សេងក្រៅពីឈ្មោះ ធី ទេ ។

9 **ស៖** លោកមានអាយុប៉ុន្មានឆ្នាំហើយ?

10 **ឆ៖** ខ្ញុំមានអាយុ ៥៨ឆ្នាំហើយ ។

11 **ស៖** សព្វថ្ងៃនេះ លោកប្រកបមុខរបរអ្វីដែរ?

12 **ឆ៖** សព្វថ្ងៃនេះ ខ្ញុំប្រកបរបរកសិធ្វើស្រែចម្ការ ។

13 **ស៖** តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការពីព្រឹកមិញថា លោកពុំមានចំណងលោហិត
14 ឬក៏ញាតិពន្ធ ឬក៏ជាសហព័ទ្ធជាមួយនឹងភាគីនៃរឿងក្តីនេះទេ ហើយលោកមុននឹងចូលក្នុងបន្ទប់សវនាការ
15 នេះបានស្បថរួចហើយ តើជាការពិតដែរឬទេ?

16 **ឆ៖** បាទ, ជាការពិត ។

17 **ស៖** លោក សួស ធី ក្នុងនាមលោកជាសាក្សី ដែលត្រូវមកធ្វើសក្ខីកម្ម នៅចំពោះមុខអង្គជំនុំ
18 ជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លោកមានសិទ្ធិនិងករណីកិច្চដូចខាង
19 ក្រោមនេះ៖

20 ក្នុងនាមលោកជាសាក្សី លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬក៏ការសុំឲ្យធ្វើអំណះ
21 អំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង ។
22 មានន័យថា ដោយសារតែចម្លើយ ឬក៏អំណះអំណាងនោះ នាំឲ្យនឹងត្រូវទទួលរងនូវការចោទប្រកាន់ ។

23 [១៣:៣៦:៥៥]

24 ទន្ទឹមនឹងនេះ លោកក្នុងនាមជាសាក្សី លោកមានករណីកិច្চនិយាយតែការណ៍ណាដែលពិត ដែល
25 លោកបានដឹង បានឮ បានឃើញដោយផ្ទាល់ ហើយចម្លើយរបស់លោកមិនគប្បីធ្វើជាសេចក្តីសន្និដ្ឋាន

តបនឹងសំណួរនោះទេ ។ តើលោកយល់ដែរឬទេនូវអ្វីដែលយើងបានប្រាប់នេះ?

ឆេ៖ បាទ, ខ្ញុំបានយល់ ។

សៈ លោក សួស ធី តើលោកបានចូលនៅក្នុងចលនាបដិវត្តន៍នៅពេលណាដែរ?

ឆេ៖ ពី លន់ នល់ ។ ខ្ញុំក្រោយពី លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ គឺខ្ញុំបានឈប់រៀន ហើយបានមកផ្ទះ ។ នៅចុងឆ្នាំ៧១ ដោយមានការអំពាវនាវរបស់សម្តេចនរោត្តម សីហនុ ខ្ញុំក៏បានចូលធ្វើជាកងទ័ព ។ ជាដំបូង គឺនៅក្នុងស្រុកឃុំកោះខែល រហូតដល់ឆ្នាំ៧២ គេក៏បានបញ្ជូនខ្ញុំឲ្យមកនៅក្នុងអង្គភាពភូមិភាគពិសេសខាងត្បូងភ្នំពេញ ចូលជាយុទ្ធជននៅក្នុងអនុសេនាធំ២៣ វរសេនាតូច១១២ កងអនុសេនាតូចទី៣ ។ ខ្ញុំនៅក្នុងសមរភូមិខាងត្បូងភ្នំពេញហ្នឹង រហូតដល់ឆ្នាំ៧៣ ដោយខ្ញុំត្រូវរបួសជាទម្ងន់ ខ្ញុំក៏បានគេបញ្ជូនឲ្យមកដេកពេទ្យរយៈពេលពីរខែ ដល់ពេលចេញពីពេទ្យវិញ គេក៏បានប្តូរនាទីខ្ញុំឲ្យធ្វើជាពេទ្យប្រចាំអង្គភាពវិញ គឺប្រចាំនៅក្នុងកងអនុសេនាតូចទី៣ អនុសេនា២៣ វរសេនាតូច១១២ ។ រហូតដល់ឆ្នាំ៧៤ ដោយសារតែរបួសខ្ញុំវាចេះតែធ្លាក់ឈាមតាមមាត់ពេក គេក៏បញ្ជូនខ្ញុំមកនៅក្នុងអង្គភាពមន្ទីរបស់អនុសេនាធំ២៣វិញ ។ ហើយខ្ញុំនៅបន្ទាយសេនាធំ២៣ៗ ក៏បានបញ្ជូនខ្ញុំឲ្យនៅក្នុងមន្ទីរវរសេនាតូច១១២ វិញ ដែលមាន ហ៊ុយ ជាបញ្ជាការវរសេនាតូច១១២នោះ ។ ហើយខ្ញុំ ក៏បាន ហ៊ុយ ចាត់តាំងឲ្យធ្វើជាបញ្ជី ជាអ្នកកាន់បញ្ជីក្តាប់ចំនួនកម្មាភិបាលយុទ្ធជនរបួសនិងពលីនៅក្នុងសមរភូមិព្រមទាំងចំនួនគ្រាប់រំសេវកាំភ្លើងសព្វាវុធទាំងអស់ ដើម្បីរាយការណ៍ទៅខាងលើ ខាងមកវរសេនាធំ ។

ខ្ញុំនៅធ្វើជាបញ្ជីនៅក្នុងវរសេនាតូច១១២ហ្នឹង ចាប់ពីឆ្នាំ៧៤រហូតដល់ឆ្នាំ៧៥ ។ ក្រោយរំដោះភ្នំពេញប្រហែលជារយៈពេលពីរខែ គេក៏ដកខ្ញុំចេញពីមន្ទីរឲ្យមកនៅក្នុងកាន់អង្គភាពវិញ គឺនៅក្នុងអនុសេនាតូចទី៣-- អនុសេនាធំ២៣ វរសេនាតូច១១២ ដដែល ហើយជាតួនាទីជាអនុក្រុម ។

[១៣:៤០:៤៦]

សៈ ចុះចាប់ពីក្រោយថ្ងៃរំដោះ អំមិញលោកបាននិយាយបន្តិចហើយ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ តើលោកធ្វើការងារអ្វីខ្លះ? ហើយនៅអង្គភាពណាខ្លះ?

ឆេ៖ ក្រោយពីឆ្នាំ៧៥ រហូតដល់ឆ្នាំ៧៩ ជាដំបូង គឺក្រោយពីរំដោះបានពីរខែ គេក៏ចាត់តាំងឲ្យខ្ញុំមកនៅក្នុងអង្គភាព ។ រហូតដល់ចុងឆ្នាំ៧៥ ខ្ញុំបានឃើញ ហ៊ិ មកក្នុងវរសេនាតូចរបស់ខ្ញុំ ដែលមាន ហ៊ុយ កាន់កាប់ហ្នឹង គេចាត់តាំង ហ៊ិ ហ្នឹង គឺគេយកខ្ញុំឲ្យមកនៅជាមួយគេ មកនៅក្នុង *ប៊ីហ្ស៊ី* កន្លែងជិតផ្សារថ្មីនេះ ។ ខ្ញុំមកមុនដំបូង គឺគេមិនទាន់ចាត់តាំងអីទេ ក្រោយមកបាន ហ៊ិ គេប្រគល់បញ្ជីអ្នក

ទោសឲ្យខ្ញុំធ្វើនៅក្នុង *ប៊ីហ្គី* ហ្នឹង ។ ហើយដល់ចុងឆ្នាំ៧៥ ខ្ញុំចាំមិនច្បាស់ ឬក៏ដើមឆ្នាំ៧៦ កន្លែងគុកហ្នឹងក៏ផ្លាស់មកនៅទួលស្លែងនេះ ។ ខ្ញុំមកនៅទួលស្លែងហ្នឹង គឺនៅក្នុងផ្នែកកងការពារដែល គឺ ហ៊ិ គេឲ្យកាន់កាប់ខាងបញ្ជើ ដើម្បីឲ្យដឹងចំនួនអ្នកទោសចូលប៉ុន្មាន? ចេញប៉ុន្មាន? ហើយនឹងកត់ធ្វើប្រវត្តិរូបអ្នកទោសជាសង្ខេប ។ រហូតដល់ឆ្នាំ-- ខ្ញុំធ្វើបញ្ជើហ្នឹងរហូតដល់ឆ្នាំ៧៩ បែកភ្នំពេញ ។

[១៣:៤៣:០០]

សៈ លោកអម្បាញ់មិញលោកបាននិយាយថា លោកកាន់ក្តាប់នូវបញ្ជើយុទ្ធជនពលីរបួស និងអាវុធគ្រាប់រំសេវនៅពេលដែល-- នៅក្នុងសង្គ្រាម សម័យជំនាន់៧០-៧៥ ដែលវាយសំដៅរំដោះទីក្រុងភ្នំពេញពីរបប លន់ នល់ នោះ ដែលមានប្រធានវរសេនាតូចឈ្មោះ ហ៊ុយ ។ ហ៊ុយ ហ្នឹង ហ៊ុយ មួយណា? ដែលលោកស្គាល់ត្រកូលគាត់ទេ?

ឆេ ហ៊ុយ ហ្នឹង គឺ ហ៊ុយ ស្រែ ។ ហ៊ុយ-- នុន ហ៊ុយ ដែលជាបញ្ជាការវរសេនាតូច ។

សៈ លោកបាននិយាយអំមិញហើយថា ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ បានន័យថា និយាយអំមិញមិនចាំច្បាស់ ប៉ុន្តែប្រហែលជាចុងឆ្នាំ១៩៧៥ ហ៊ិ បានយកលោកមកធ្វើការនៅគុកមួយដែលកាលនោះ គេយកអតីត *ប៊ីហ្គី* យកធ្វើជាទីតាំងគុក ។ អ៊ីចឹងមែនទេ?

ឆេ បាទ, អ៊ីចឹងមែន ។

សៈ ហ៊ិ ដែលលោកនិយាយនេះ មាននាមត្រកូលឈ្មោះអីទៅ? ហើយគាត់មានឋានៈយ៉ាងម៉េចនៅក្នុងមន្ទីរសន្តិបាលស-២១?

[១៣:៤៥:០០]

ឆេ ហ៊ិ ហ្នឹងគឺនាមត្រកូលខ្ញុំចាំអត់បានទេ ដឹងតែឈ្មោះ ហ៊ិ ប៉ុន្តែអតីតគាត់ គឺជាប្រធានវរសេនាធំរបស់កងពល៧០៣ វរសេនាធំ២៦៧ កងពល៧០៣ តែក្រោយមកគាត់មកនៅក្នុងមន្ទីរស-២១ គាត់ទទួលនាទីជាអនុប្រធានគុកទួលស្លែង ។

សៈ កាលដែលឈ្មោះ ហ៊ិ យកលោកមកធ្វើការងារនៅក្នុង នៅគុកមួយដែលយកអតីត *ប៊ីហ្គី* ធ្វើជាគុកដំបូងឡើយហ្នឹងមានទីតាំងនៅកន្លែងណាដែលលោកថា *ប៊ីហ្គី* ហ្នឹង មានទីតាំងនៅកន្លែងណាបច្ចុប្បន្នបើយើងប្រៀបធៀបកន្លែងបច្ចុប្បន្ននេះ? លោកយកគោលដៅណាមួយដើម្បីធ្វើការប្រៀបធៀបបាន ឧទាហរណ៍ដូចជាផ្សារថ្មី នៅខាងណាផ្សារថ្មី? ផ្សារធំថ្មីយើងទីក្រុងភ្នំពេញនេះ?

ឆេ ទីតាំងគុក *ប៊ីហ្គី* គឺនៅបច្ចុប្បន្ននេះ គឺស្នងការដ្ឋាននគរបាលរាជធានីបច្ចុប្បន្ននេះ ។

សៈ នៅខាងត្បូង ម្តុំខាងត្បូងផ្សារធំថ្មីហ្នឹងមែនទេ? ប្រហែលជាចម្ងាយ ប្រហែលជាពីរបីម៉ែត្រ ពីខាងត្បូងផ្សារធំថ្មីហ្នឹងមែនទេ?

ឆៈ បាទ, នៅខាងត្បូងផ្សារធំថ្មីហ្នឹង ។

សៈ ព្រោះអីកាលណាលោកនិយាយថា បច្ចុប្បន្នហ្នឹងគឺជាកន្លែងស្នងការនគរបាល ។ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បាននិយាយថា កន្លែងហ្នឹងគេដោះដូរហើយ ។ អីឡូវនេះ គេទៅនៅខាងជើងអង់តែន ទូរទស្សន៍ឆ្ងាយប្រហែលជាពីរបីគីឡូពីអង់តែនទូរទស្សន៍ទៀត។ អ៊ីចឹងកុំឲ្យមានការភាន់ច្រឡំ បាននិយាយថា អាហ្នឹងជាអតីត អតីតកាលគឺក្រោយឆ្នាំ៧៩ ទីនុំងក៏គេយកធ្វើជាស្នងការដ្ឋាននគរបាលក្រុងភ្នំពេញ ។ កាលនោះ ពេលលោកមកដល់ហ្នឹង តើអ្នកណាជាប្រធាននៃមន្ទីរដែលលោកអះអាងអំមិញថាគុកដែល យកទីតាំងអតីត *ប៉េហ្គុី* ធ្វើជាគុកហ្នឹង តើនរណាជាប្រធាននៃគុកនុំង?

ឆៈ ទីតាំង *ប៉េហ្គុី* ដែលខ្ញុំមកនៅមុនដំបូងហ្នឹង ខ្ញុំក៏មិនទាន់បានដឹងច្បាស់ដែរ ប៉ុន្តែទីតាំងហ្នឹង ខ្ញុំ មិននឹក អត់ដឹងថាមន្ទីរស-២១ ទេ ប៉ុន្តែពីមុនគឺជារបស់កងពល៧០៣ ដែលមានតា ណាត ជាប្រធានហើយ ហ៊ិ ហ្នឹងវរសេនាធំហ្នឹងជាអនុ ហើយនិង ហ៊ុយ ជាសមាជិកក្នុងគុក*ប៉េហ្គុី*ហ្នឹង ។

សៈ លោកមកធ្វើការនៅគុកដែលយក *ប៉េហ្គុី* ធ្វើជាគុកកាលនោះ អស់រយៈពេលប្រហែលប៉ុន្មានទៅបានផ្លាស់ពីទីតាំងពីទីនោះមកកន្លែងបច្ចុប្បន្នដែលយើងស្គាល់ជាទូទៅហៅថា សារមន្ទីរទួលស្លែង ឬក៏ពីដើម ឬក៏យើងប្រើពាក្យពីមុនគេហៅថា មន្ទីរសន្តិសុខស-២១ មជ្ឈមណ្ឌលភ្នំពេញនោះ?

[១៣:៣៨:៣៩]

ឆៈ ខ្ញុំចាំមិនច្បាស់ គឺខ្ញុំប្រហែលជាមួយខែ ឬពីរខែ នៅក្នុង*ប៉េហ្គុី*នោះ ។ រួចហើយបានគេផ្លាស់មកនៅគុកទួលស្លែងវិញ ។

សៈ កាលពីលោកមកដល់ធ្វើការ មួយខែ ឬក៏ទៅពីរខែ មុនពេលផ្លាស់ទីតាំងគុកពីអតីត*ប៉េហ្គុី* នៅខាងត្បូងផ្សារធំថ្មីមក ទួលស្លែងតើលោកដែលស្គាល់ជនជាប់ចោទឈ្មោះ ឌុច ដែរឬទេ? កាលនោះដែលស្គាល់ដែរឬទេ?

ឆៈ កាលនៅ*ប៉េហ្គុី*នោះ គឺខ្ញុំមិនបានស្គាល់ទេ ។

សៈ លោកចាប់ស្គាល់ឈ្មោះ ឌុច ហ្នឹងនៅពេលណា?

ឆៈ កាលដែលខ្ញុំស្គាល់ឈ្មោះ ឌុច នេះគឺនៅរហូតដល់គេឯក តាណាត ចេញបានដឹងថា ឌុចហ្នឹងគេឡើងប្រធានមន្ទីរស-២១ ។

សៈ លោកដឹងទេថា ការដកឈ្មោះ អ៊ុន លន ហៅ ណាត ហ្នឹងចេញពីប្រធានមន្ទីរស-២១ ហ្នឹងកាលនោះមន្ទីរ ស-២១ នៅអតីតប៉ៃហ្សឺខាងត្បូងផ្សារធំថ្មីបច្ចុប្បន្ន ឬមួយក៏បានផ្លាស់ទីតាំងមកនៅទួលស្លែង បច្ចុប្បន្នដែលគេស្គាល់ទូទៅគេហៅថា សារមន្ទីរគុកទួលស្លែងនោះហើយ?

ឆៃ ខ្ញុំសូមសំណួរម្តងទៀត ស្តាប់អត់ទាន់ច្បាស់ ។

សៈ អម្បាញ់មិញលោកនិយាយថា មានការផ្លាស់ប្តូរប្រធាន ដោយសារការផ្លាស់ប្តូរដកយកឈ្មោះ ណាត ចេញទៅពីប្រធាន ហើយដាក់ប្រធានថ្មីមកជំនួស ណាត គឺឈ្មោះ ឌុច ។ សំណួរសួរថា ការផ្លាស់ប្តូរនេះ កាលនោះទីតាំងគុកនៅកន្លែង*ប៉ៃហ្សឺ* ដែលលោកនិយាយថា ជាកន្លែង*ប៉ៃហ្សឺ*នៅខាងត្បូងផ្សារធំថ្មី ឬក៏ការផ្លាស់ប្តូរហ្នឹង ទីតាំងគុកហ្នឹងបានមកផ្លាស់មកនៅកន្លែងបច្ចុប្បន្ន ដែលគេហៅស្គាល់ជាទូទៅថា សារមន្ទីរគុកទួលស្លែងរួចហើយ?

ឆៃ គេផ្លាស់ប្តូរតាណាត ហ្នឹងគឺនៅកន្លែងប៉ៃហ្សឺនោះ មិនមែននៅកន្លែងគុកទួលស្លែងបច្ចុប្បន្ននេះទេ ។

សៈ អ៊ីចឹងបានសេចក្តីថា កាលពីលោកចូលមកធ្វើការដំបូងនៅ *ប៉ៃហ្សឺ* គឺមាន ណាត ជាប្រធានទេ ប៉ុន្តែមួយរយៈក្រោយមកក៏មានការផ្លាស់ប្តូរប្រធាន ដោយដក ណាត ចេញដាក់ ឌុច ជាប្រធាន ហើយបន្ទាប់មកទើបមានការរើទីតាំងពីកន្លែងគុកហ្នឹង ពីកន្លែងប៉ៃហ្សឺមកកន្លែងសារមន្ទីរគុកទួលស្លែងបច្ចុប្បន្ន អ៊ីចឹងមែនទេ?

[១៣:៥២:៤២]

ឆៃ បាទ, អ៊ីចឹងមែន ។

សៈ ក្នុងនាមលោកដែលគេឈ្មោះ ហ៊ែ នាំឲ្យធ្វើការ លោកបាននិយាយថា គេឲ្យលោកមកធ្វើកាន់កាប់ខាងបញ្ជីគ្រប់គ្រងអ្នកទោស ។ សំណួរទីមួយ កាលពីលោកមកដល់ដំបូងនៃកន្លែងធ្វើការរបស់លោកនៅ*ប៉ៃហ្សឺ*នោះ ទីនោះជា ជាពាក្យ ឬក៏ជាឈ្មោះជំនាន់ទុំងគេប្រើ គេកំណត់ថា ឈ្មោះកន្លែងដែលលោកធ្វើហ្នឹងហៅយ៉ាងម៉េច? ទីមួយ ។ បញ្ហាទីពីរ តើការងាររបស់លោកដែលគេប្រគល់ឲ្យលោកហ្នឹង លោកមានមុខងារធ្វើអី កាលពីមកដល់ភ្លាម?

ឆៃ ជាឈ្មោះកាលនៅ*ប៉ៃហ្សឺ*នោះ គឺខ្ញុំដឹងថា ជាគុករបស់កងពល៧០៣ ហើយការងារដែលគេឲ្យខ្ញុំមកដល់ គេក៏ឲ្យខ្ញុំទទួលធ្វើបញ្ជីអ្នកទោសចំនួនដែលចូលមានប៉ុន្មានក្នុងមួយថ្ងៃៗ ។

សៈ លោកមានដែលឮគេនិយាយថា មានគុកដាំផែង ទេ? លោកដែលឮពាក្យនេះទេកាលនោះ?

ឆេ៖ កាលនោះខ្ញុំអត់បានជាចាប់អារម្មណ៍ថា គុក ដាំ ផែង ជាអីទេ ពីព្រោះខ្ញុំនៅកន្លែងមន្ទីរ ហ្នឹងគិតថា នៅតែកន្លែង មួយកន្លែង សម្រាប់ធ្វើបញ្ជីហ្នឹង ។

សៈ លោកនិយាយរៀបរាប់ប្រាប់ដល់អង្គសវនាការអំពីកិច្ចការរបស់លោកដែលលោកប្រតិបត្តិការនៅក្នុងការធ្វើបញ្ជីអ្នកទោសចូលនៅក្នុងអំឡុងពេលនៃ ចាប់ពីពេលដែលលោកចូលមកធ្វើការនៅគុកដែលលោកនិយាយអំមិញ គឺគុកនៃកងពល៧០៣ រហូតដល់ពេលផ្លាស់ទីតាំងទុំងមកទួលស្លែង បានន័យថាទួលស្លែង គឺមិនទាន់ឲ្យនិយាយទេ ។ គឺនិយាយនៅក្នុងអំឡុងពេលដែលលោកប្រតិបត្តិការនោះ តើលោកធ្វើការងារបញ្ជី ស្នាមបញ្ជីអ្នកទោសនោះយ៉ាងដូចម្តេចខ្លះ?

ឆេ៖ កាលដែលគេឲ្យខ្ញុំធ្វើបញ្ជីនៅក្នុងគុកកងពល៧០៣ កន្លែង*ប៊ីហ្គឺ*នោះ គឺតួនាទីរបស់ខ្ញុំ គឺពេលអ្នកទោសចូលមក គឺខ្ញុំត្រូវកត់ឈ្មោះប្រវត្តិរូបសង្ខេប គឺកត់តែឈ្មោះ អាយុ នាទី និងឈ្មោះឪពុកម្តាយ រួមទាំងភូមិឃុំតែប៉ុណ្ណឹងទេ ហើយរាយការណ៍ជាប្រចាំថ្ងៃយកទៅឲ្យខាងមន្ទីររបស់ដែលខាងកងពល គឺមាន ម៉ែង ជាអ្នកកាន់កាប់ គឺខ្ញុំរាយការណ៍ជាប្រចាំថ្ងៃ ។

សៈ កាលពីចាប់មនុស្សយកដាក់ឃុំឃាំងនៅគុកកងពល៧០៣ កាលដែលលោកទៅមកធ្វើនោះ មានថតរូបដែរឬទេ?

[១៣:៥៦:៥៩]

ឆេ៖ កាលនោះ គឺអត់ទាន់មាន ខ្ញុំមិនបានចាំច្បាស់ទេ ពីរឿងថតរូប ប៉ុន្តែកាលហ្នឹង គឺខ្ញុំគ្រាន់តែធ្វើប្រវត្តិរូបហើយ អត់មានជាងថតទេ គេៗយកអ្នកទោសដាក់ចូលទៅ ។ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់កាលនៅគុក៧០៣ អ្នកទោសចូលតិចណាស់ ។ ដូច្នេះ ការធ្វើបញ្ជីនេះ គឺអត់មានថតរូបទេ កាលហ្នឹង ។

សៈ អ្នកដែល មនុស្សដែលគេចាប់យកមកដាក់គុកនៃកងពល៧០៣ កាលនោះដែលលោកក្តាប់ថា មានចំនួនតិចក្នុងអំឡុងពេលដែលលោកធ្វើការនៅទីនោះ ។ តើលោកទទួលធ្វើបញ្ជីបញ្ចូលមនុស្សដែលចាប់ខ្លួនទៅក្នុងគុកហ្នឹងបានប្រហែលចំនួនប៉ុន្មាននាក់ដែរ?

ឆេ៖ កាលដែលខ្ញុំធ្វើបញ្ជីនៅកន្លែងកងពល៧០៣ហ្នឹង គឺបញ្ជីអ្នកទោស គឺមានស្រាប់រួចហើយ ដូច្នេះ កាលដែលខ្ញុំធ្វើបន្តែមហ្នឹងប្រហែលជាតិចតួចទេកាលហ្នឹង អ្នកទោសដែលចូលមកក្នុងកងពលហ្នឹង ប៉ុន្តែ សរុបចំនួនគឺខ្ញុំប៉ាន់មិនត្រូវទេ ប៉ុន្តែតិចតួចទេ ។

សៈ តិចតួចហ្នឹង សំដៅលើអ្នកទោសដែលលោកធ្វើបញ្ជី ដែលគេឲ្យបង្គាប់ឲ្យលោកបំពេញភារកិច្ចធ្វើបញ្ជី។ ចំណែកឯ អ្នកទោសដែលជាប់ឃុំឃាំងរួចហើយហ្នឹង ឬកជាមួយនិងអ្នកទោសដែល

ចាប់មកថ្មី ហើយបញ្ជូលទៅឃុំឃាំង ដោយធ្វើឡើង លោកដែលត្រូវគេបានចាត់ធ្វើបញ្ជី សរុបទាំងអស់ប្រហែលប៉ុន្មានកាលពីៗទៅដល់ទីនោះ អ្នកទោសនៅក្នុងនុំងទាំងមូលប្រហែលជាប៉ុន្មាននាក់?

ឆេ៖ ចំនួនអ្នកទោសដែលគេចាប់រួចមកហើយ ហើយបន្តែមចំនួនដែលខ្ញុំកត់បន្តែម គឺខ្ញុំស្មានវាមិនច្បាស់ គឺប្រហែលជាមួយរយនាក់ជាងបន្តិចបន្តួចទេ ។

[១៣:៥៩:១៩]

សេ៖ លោកជាអ្នកគ្រប់គ្រងខាងឯកសារ តើលោកដឹងទេថា អ្នកទោសប្រហែលជាមួយរយនាក់ជាងដែលគេចាប់ឃុំឃាំងនៅក្នុងគុកនៃកងពល៧០ពាកាលនោះ ជាប្រភេទមនុស្សប្រភពមកពីណាដែរ? ជាកងទ័ពបដិវត្តន៍ ជាកម្មាភិបាលបដិវត្តន៍ ឬក៏ជាអតីត ជាទាហានលន់នល់ ឬក៏ជាមន្ត្រីរាជការ អ្នករដ្ឋការរបបលន់នល់ ដែលបានចាញ់សង្គ្រាមនោះ ឬយ៉ាងម៉េច?

ឆេ៖ កាលដែលនៅក្នុងគុក៧០ពានោះ គឺអ្នកទោសអត់ទាន់មានអ្នកទោសផ្ទៃក្នុងទេ គឺច្រើនតែអ្នករាជការ កម្មការរោងចក្រ ហើយនិង-- ប៉ុន្តែចំពោះផ្ទៃក្នុងគឺអត់មានទេ គឺមានតែផ្នែកដែលខាងកម្មកររោងចក្រ ហើយនិងដែលខាងអ្នក១៧មេសា ។

សេ៖ លោកដឹងទេថាមនុស្សទាំងអស់នេះគេចាប់យកពីណាមក? កងពល៧០ពាហ្នឹងចាប់មនុស្សហ្នឹងពីណាមកយកមកដាក់គុកនៅទីនោះជាងមួយរយនាក់ហ្នឹង?

ឆេ៖ ខ្ញុំ គឺមិនបានដឹងទេ គឺព្រោះការចាប់ពីក្រៅមក គឺខ្ញុំអត់បានដឹងទេ ។

សេ៖ មនុស្សជាងមួយរយនាក់ដែលថា ដាក់គុកនៅគុកនៃមន្ទីរកងពលនៃ៧០ពា ដែលលោកបាននិយាយអំមិញហ្នឹង ក្រោយពេលផ្តាស់ទីតាំងពី *ប៊ីហ្គ្រី* មកនៅគុកទួលស្លែងបច្ចុប្បន្ននេះ យើងហៅថាសារមន្ទីរគុកទួលស្លែង តើអ្នកទោសទាំងអស់ជាងមួយរយនាក់ហ្នឹងនាំយកទៅឯណា?

ឆេ៖ ក្រោយពីគុក៧០ពាផ្តាស់មកនៅក្នុងទួលស្លែង គឺអ្នកទោសគេដឹកជញ្ជូនពីនោះមកទាំងអស់យកមកដាក់ក្នុងគុកទួលស្លែង ។

សេ៖ នៅក្នុងអំឡុងពេលនៃ ដែលលោកទៅធ្វើការហ្នឹង ក្រៅពីលោកធ្វើបញ្ជីអ្នកទោសចូល តើលោកមានបានធ្វើបញ្ជីអ្នកទោសចេញដែរទេ? បានន័យថា មានការបញ្ចេញអ្នកទោសចេញក្រៅដែរទេក្រោពីអ្នកទោសសេសសល់ដែលដឹកយកមកកាន់មន្ទីរសន្តិសុខស-២១ បច្ចុប្បន្នគេហៅស្គាល់ជាទូទៅគេហៅថា សារមន្ទីរគុកទួលស្លែងនោះ បានន័យថា អំឡុងពេលនោះតើមានការបញ្ចេញអ្នកទោសវិញដែរទេ ព្រោះលោកអំមិញបាននិយាយថា ធ្វើកាន់បញ្ជីបញ្ចូល សួរថាចុះបានបញ្ចេញដែរឬអត់ ក្រៅពីការ

បញ្ជេញអ្នកដែលនៅសល់មកកាន់មន្ទីរសន្តិសុខស-២១ថ្មី ដែលនៅទួលស្លែង?

ឆៃ៖ កាលដែលផ្លាស់មន្ទីរគុករបស់កងពល៧០៣មកមន្ទីរទួលស្លែងនេះ គឺអ្នកទោសគេអត់មានយកចេញទេគេយកទាំងអស់ គឺមកចូលក្នុងគុកទួលស្លែងទាំងអស់ គឺកាលណោះគឺអត់ទាន់មានការកាប់សម្លាប់ទេ ។

[១៤:០៣:២៧]

សៃ៖ ក្នុងអំឡុងពេលដែលលោកមកធ្វើការនៅកន្លែងចំណុច *ប៉េហ្ស៊ី* ដំបូងហ្នឹង តើលោកបានដែលទៅដល់គុកមួយទៀតនៃកងពល៧០៣ ដែលមានទីតាំងនៅមន្ទីរពេទ្យឆ្កួតនៅតាខ្មៅដែរឬទេ?

ឆៃ៖ កាលដែលខ្ញុំមកនៅក្នុងគុក៧០៣ កន្លែង *ប៉េហ្ស៊ី* នេះ គឺខ្ញុំមិនដែលទៅកន្លែងគុកតាខ្មៅទេ ពីព្រោះកន្លែងគុកតាខ្មៅ គេមានអ្នកកាន់បញ្ជីខាងណោះដោយឡែក ។

សៃ៖ ឥឡូវនេះ យើងចូលមកដល់កិច្ចការដែលលោកមកធ្វើការងារ ជាអ្នកកាន់បញ្ជីនៅមន្ទីរសន្តិបាល ឬក៏មន្ទីរសន្តិសុខស-២១ មជ្ឈមណ្ឌលភ្នំពេញ ដែលទីតាំងបច្ចុប្បន្នយើងរំឭកម្តងទៀតថាជាទីតាំងនៃបច្ចុប្បន្នដែលគេស្គាល់ជាទូទៅថា ជាសារមន្ទីរនៃគុកទួលស្លែងបច្ចុប្បន្ននេះ ។ ពេលមកដល់ទីនេះ តើលោកមានគេចាត់ឲ្យលោកធ្វើការងារអ្វី? ហើយនៅក្នុងការងាររបស់លោកហ្នឹង តើលោកមានភារកិច្ចធ្វើអ្វីខ្លះ?

ឆៃ៖ កាលដែលគុក៧០៣ ផ្លាស់មកនៅទួលស្លែង គឺខ្ញុំមកដល់ទួលស្លែង គឺគេឲ្យធ្វើបញ្ជីដដែល គឺធ្វើបញ្ជីអ្នកទោសដែលចូលហើយនិងចេញ ។ ហើយភារកិច្ចទៀត គឺកត់ប្រវត្តិរូបអ្នកទោសដាក់ក្នុងក្រដាសមួយដែលមានឯកសារហ្នឹងសម្រាប់បិតរូបថត ហើយនិងរាយការណ៍ជាប្រចាំលើចំនួនអ្នកទោសចេញនិងចូលប្រចាំថ្ងៃជូនទៅខាងមន្ទីរខាង ២១(ក) ដែលមាន ម៉ែង ជាអ្នកទទួលបញ្ជីនៅខាង២១(ក) ។

សៃ៖ អង្គភាពរបស់លោកហ្នឹង គេហៅអង្គភាពអ្វីដែរ? ហើយមានគ្នាប៉ុន្មានអ្នក? អ្នកណាជាប្រធាន?

ឆៃ៖ អង្គភាពរបស់ខ្ញុំ គឺគេហៅថា អង្គភាពស-២១ (ខ) គឺផ្នែកខាងនិយាយឲ្យខ្លី គឺផ្នែកខាងការពារ ដែលមាន ហ៊ិ ជាប្រធាន ។

សៃ៖ ហ៊ិ ជាអនុប្រធាន ទទួលបន្ទុកជាប្រធាន ទទួលខុសត្រូវរួមផ្នែកខាងការងារកងការពារ ប៉ុន្តែក្រុមរបស់លោកនេះ ផ្នែកខាងឯកសារនេះ តើមានគ្នាប៉ុន្មាននាក់? ហើយអ្នកណាជាប្រធាន?

ឆៃ៖ ក្រុមអ្នកធ្វើបញ្ជីនៅក្នុងការពារគឺអត់មានទេ គឺមានតែខ្ញុំម្នាក់ឯងទេដែលធ្វើបញ្ជី ពីព្រោះ

បញ្ហើអ្នកទោសនេះ គឺគ្រាន់តែកត់សង្ខេបៗចំនួនតែប៉ុណ្ណឹង ចេញហើយនិងចូលតែប៉ុណ្ណឹងទេ ។ ដូច្នេះ ខ្ញុំមានតែម្នាក់ឯងទេ ។

[១៤:០៧:៣៨]

សៈ ចុះផ្នែកខាងថតរូប គាត់នៅខាងណា? ផ្នែកជាមួយលោកដែរ ឬក៏ផ្នែកដាច់ដោយឡែកផ្សេងពីលោក?

ឆៈ ផ្នែកខាងថតរូប គឺគេនៅខាងផ្នែកមន្ទីររបស់ស-២១(ក) ក្រោមការគ្រប់គ្រងរបស់ ម៉ែង ដែលជាអ្នកធ្វើបញ្ហើនៅស-២១(ក)ហ្នឹង ។

សៈ យើងដូចជាអត់ទាន់ លេចឮពាក្យ ២១(ក), ២១(ខ) ទើបមកពេលនេះស្រាប់តែចេញ ២១(ក) ២១(ខ) ។ កាលពីធ្វើសវនាការឃ្សរមកហើយនេះ បានស្តាប់ពាក្យនេះ តែនៅក្នុង ម-១៣(ក), ម-១៣(ខ) នៅអមណាំងទេ ។ ហើយក្រោយមកទៀត គឺមន្ទីរស-២១នេះ មានពីរ មន្ទីរស-២១ មជ្ឈមណ្ឌលភ្នំពេញ ហើយនិងមន្ទីរមួយគេហៅថា មន្ទីរស-២៤ ឬក៏គេហៅថា មជ្ឈមណ្ឌលអប់រំកែប្រែនៅព្រៃស កែប្រែសាជាថ្មីព្រៃស ឬក៏ស-២៤ ។ ឥឡូវហ្នឹងមាន ២១(ក) មាន២១(ខ) ។ ២១(ក)ហ្នឹង អ្នកណាជាអ្នកធ្វើប្រធានគ្រប់គ្រងមន្ទីរ២១(ក)? ហើយមានមុខងារធ្វើអី?

ឆៈ ប្រធានមន្ទីរ២១(ក) ខ្ញុំសូមបញ្ជាក់ មាន ឌុច ហ្នឹងដែលជាប្រធានរួម គេទទួលមើលការខុសត្រូវលើមន្ទីរស-២១(ក)ហ្នឹងទាំងអស់ ។ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់បន្ថែម ដើម្បីឲ្យងាយស្តាប់ ស-២១(ក) គឺគេ គឺជាអង្គភាពសួរចម្លើយ ហើយស-២១(ខ) គឺជាអង្គភាពខាងកងការពារ ហើយស-២១(ឃ) គឺអង្គភាពផ្នែកស្រែ ដល់ក្រោយមកគេហៅមន្ទីរ២៤ ។

សៈ អ៊ីចឹងនិយាយពីរចនាសម្ព័ន្ធ បើយើងគិតរចនាសម្ព័ន្ធវិញគឺមន្ទីរស-២១ហ្នឹង គឺជាមន្ទីរយើងហៅថា មន្ទីរសន្តិសុខស-២១ ឬក៏គុកស-២១ ហ្នឹងគឺជាមន្ទីររួម ហើយនៅក្នុងមន្ទីរនេះ គឺចែកចេញជាបីអង្គភាពធំៗ មន្ទីរសន្តិសុខស-២១(ក) គឺផ្នែកខាងអង្គភាពសួរចម្លើយ ហើយ(ខ) ផ្នែកខាងការពារ ហើយ(ឃ) គឺមន្ទីរអប់រំកែប្រែសាជាថ្មីនៅព្រៃស ។ អ៊ីចឹងមែនទេ រចនាសម្ព័ន្ធដែលលោកនិយាយ (ក) (ខ), (ឃ) នេះ?

ឆៈ បាទ, ពិតជាអ៊ីចឹងមែន ។

សៈ ឥឡូវហ្នឹង និយាយពីរចនាសម្ព័ន្ធឲ្យបានច្បាស់លាស់តែម្តង ពីព្រោះវាមានលេចជាសញ្ញាណថ្មីនៃពាក្យ “ក” “ខ” ថែមពាក្យ “ឃ” ទៀត អត់ឃើញ “គ” ទេ មានៗមន្ទីរ២១(គ) ទេបើឥឡូវវាដល់

ឆៃ៖ ២១(ឃ) ទៅហើយ? ឬក៏ស២៤ តើមានមន្ទីរ២១(គ) ដែរឬទេ?

[១៤:១១:៣៩]

ឆៃ៖ នេះគឺខ្ញុំអត់ដែលឮសួរថាស-២១(គ)ទេ ប៉ុន្តែបើតាមខ្ញុំដឹង គឺមានតែ “ក” “ខ” ហើយនិង “ឃ” ។

សៃ៖ លោកនិយាយថា ២១(ក) ហ្នឹង គឺជាអង្គភាពសួរចម្លើយ ឬក៏ផ្នែកសួរចម្លើយ តើវាមានផ្នែកណាផ្សេងទៀតទេនៅក្នុងអង្គភាពស-២១(ក)?

ឆៃ៖ គឺក្នុងផ្នែកស-២១(ក) ហ្នឹង គឺមានតែកងសួរចម្លើយ ហើយដូចជាផ្នែកខាងសេដ្ឋកិច្ចក៏នៅខាងស-២១(ក) ផ្នែកខាងថតក៏នៅ២១(ក) ខាងវាយអង្គុលីលេខក៏នៅខាងស-២១(ក) សរុបគឺស-២១(ក) មានប៉ុន្មានផ្នែកហ្នឹង ។

សៃ៖ ចុះ២១(ខ) អង្គភាព២១(ខ) មានអង្គភាពណាចំណុះនៅក្នុងអង្គភាពស-២១(ខ)ខ្លះ?

ឆៃ៖ ស-២១(ខ) គឺអង្គភាពចំណុះ គឺអត់មានទេ មានតែកងការពារ ក្នុងកងការពារហ្នឹងគឺមានតែក្រុមដាំបាយ គឺនៅក្នុងអង្គភាពចំណុះរបស់ស-២១(ខ)។ ក្រុមដាំបាយ គឺក្រុមដាំបាយឲ្យអ្នកទោស ។

សៃ៖ ចុះកងពិសេស ឬកងអនុសេនាធំហ្នឹង នៅចំណុះអង្គភាពណាមួយក្នុងចំណោមអង្គភាពទាំងបីនេះ? លោកដែលឮទេពាក្យ កងពិសេស ឬក៏កងអនុសេនាធំ?

ឆៃ៖ កងអនុសេនាធំ គឺនៅក្នុងចំណុះរបស់កងការពារទាំងអស់ ។ ចំណែក កងពិសេស កាលលើកដំបូង គឺនៅក្នុងកងរបស់ កងពលរបស់៧០៣ គឺកងពិសេសគេដកពីណោះមក រហូតមកចូលនៅក្នុងស-២១ ក៏នៅកងពិសេសអាហ្នឹង គេយកអ្នកកងពិសេសហ្នឹងដដែល បានគេហៅកងពិសេសជាប់រហូតមក ។

សៃ៖ ប៉ុនយើងចង់ដឹងកងពិសេសទេនេះ កងពិសេសដែលយកពីកងពល៧០៣មកហ្នឹង យកមកបញ្ចូលនៅក្នុងកងអង្គភាពណានៃស-២១(ខ) ព្រោះលោកអំមិញនិយាយតែកងការពារទេ ប៉ុន្តែអាហ្នឹងវានៅកងពិសេសដែលលោកបាននិយាយអំមិញទទួលស្គាល់ថា មួយកងពិសេសដែលយកពីកងពល៧០៣មក យកមកចូលនៅក្នុងស-២១ ប៉ុន្តែនៅក្នុងអំមិញគឺលោកនិយាយជារចនាសម្ព័ន្ធកងការពារទេ ។

អ៊ីចឹងសំណួរសួរថា កងពិសេសហ្នឹងនៅក្នុងរចនាសម្ព័ន្ធនៃអង្គភាពណាមួយក្នុងចំណោមអង្គភាពទាំងបីនេះ?

[១៤:១៥:០០]

ឆៃ៖ ខ្ញុំសូមបញ្ជាក់ គឺថា កងពិសេសកាលនៅគុក *ប៊ីហ្ស៊ី* រចនាសម្ព័ន្ធរបស់កងពិសេសនៅក្រោមការគ្រប់គ្រងរបស់ តាណាត ផ្នាល់ គឺរបស់កងពល ប្រធានកងពល ។ តែទើបមកដល់នៅក្នុងគុកទួលស្លែងកងពិសេស គឺវានៅក្រោមការគ្រប់គ្រងរបស់កងការពារដែលមានឈ្មោះ ហ៊ិ ជាប្រធាន។

សៈ ចុះផ្នែកខាងយានយន្ត ខាងគ្រប់គ្រងយានយន្ត អ្នកបើកបរអីអ៊ីចឹង ហើយនៅខាងណា?

ឆៃ៖ ផ្នែកខាងយានយន្ត អ្នកបើកបរគឺនៅក្នុងកងពិសេស ។ ខ្ញុំសូមបញ្ជាក់បន្ថែមបន្តិច ផ្នែកកងពិសេសហ្នឹង គឺពីដើមមកគឺនៅក្នុងកងពល៧០៣ គេសុទ្ធតែនីរសារ នីរសាររបស់កងពល ។ ហើយក្រោយមកបានមកដល់ទួលស្លែង គឺគេហៅកងពិសេសជាប់រហូតមក គឺមកនៅក្រោមការគ្រប់គ្រាប់របស់កងការពារ ហ៊ិ គ្រាប់គ្រាប់វិញ ។

សៈ មាននៅកងណាទៀតទេ? ចុះពេទ្យ ពួកក្រុមពេទ្យនៅខាងណា?

ឆៃ៖ ក្រុមពេទ្យក៏នៅក្រោមការគ្រប់គ្រងរបស់មន្ទីរស-២១ (ក) ដែរ គឺខាងការសួរចម្លើយ ។ ប៉ុន្តែ ដល់រហូតគេចាប់ពេទ្យអស់ទៅ ពេទ្យដែលចូលថ្មីអាហ្នឹងបានខាងកងការពារគ្រាប់វិញ ។

សៈ ចុះខាងអ្នកដាំស្លរសម្រាប់កម្មាភិបាលបុគ្គលិកស-២១ ស្ថិតនៅចំណុះខាងអង្គភាពណាមួយ ២១ (ក), ២១ (ខ) ឬក៏ ២១ (ឃ)?

ឆៃ៖ អ្នកដាំបាយឲ្យកម្មាភិបាល គឺនៅចំណុះរបស់ស-២១ (ខ) គឺកងការពារ ។ អ្នកដាំបាយគេហៅសេដ្ឋកិច្ចហ្នឹង គឺដាំបាយឲ្យកម្មាភិបាលយុទ្ធជនផង និងដាំបាយឲ្យអ្នកទោសផង ។

សៈ កន្លែងរោងបាយហ្នឹងរួមគ្នា ឬក៏រោងបាយដោយឡែកពីគ្នា?

ឆៃ៖ កន្លែងរោងបាយ គឺនៅរួមគ្នាទាំង ២១ (ក) និង ២១ (ខ) ។ ទាំងផ្នែកសួរចម្លើយ និយាយឲ្យខ្លី ផ្នែកសួរចម្លើយ និងផ្នែកការពារ គឺនៅរួមគ្នាតែមួយទេ ។

សៈ យើងចង់ដឹងថា អំមិញលោកបានបែងចែកហើយនៅក្នុងកងការពារហ្នឹង នៅក្នុង ២១ (ខ) ហ្នឹងមានទាំងក្រុមដាំបាយឲ្យអ្នកទោស ហើយសួរទៀតថា ផ្នែកខាងសេដ្ឋកិច្ច ដែលទទួលបន្ទុកខាងដាំស្លផ្គត់ផ្គង់ដល់កម្មាភិបាលបុគ្គលិកមន្ទីរស-២១ ហ្នឹង ក៏នៅក្នុង ២១ (ខ) ដែរ ។ អ៊ីចឹង យើងសួរថា តើក្រុមដាំបាយឲ្យអ្នកទោស និងក្រុមសេដ្ឋកិច្ចដែលដាំស្លរផ្គត់ផ្គង់ដល់កម្មាភិបាលបុគ្គលិកមន្ទីរស-២១ ហ្នឹង វាមានទីតាំងជាមួយគ្នា ហើយក្រុមមនុស្សដែលធ្វើការដាំស្លរហ្នឹងជាមួយគ្នា ឬក៏ធ្វើដោយឡែកពីគ្នា?

[១៤:១៩:00]

ឆេ៖ ការណ៍នេះ គឺខ្ញុំចាំមិនច្បាស់ ពីព្រោះខ្ញុំអត់ដែលបានទៅកន្លែងដាំបាយ គឺខ្ញុំបញ្ជាក់ថា គឺខ្ញុំអត់បានដឹងច្បាស់ទេ ។

សៈ ចុះ ២១ (ឃ) លោកដឹងច្បាស់ទេ រចនាសម្ព័ន្ធយ៉ាងម៉េចទៅ ២១ (ឃ) ហើយអ្នកណាជាប្រធាននៅទីនោះ?

ឆេ៖ ចំពោះ ២១ (ឃ) រចនាសម្ព័ន្ធគឺខ្ញុំអត់បានដឹងទេ ប៉ុន្តែ ខ្ញុំដឹងប្រធាននៅទីនោះ គឺ នុន ហ៊ុយ ជាប្រធាននៅទីនោះ ។

សៈ ឥឡូវនិយាយពីរឿងការងាររបស់លោកវិញ លោកផ្ទាល់ដែលលោកធ្វើការជាអ្នកធ្វើបញ្ជីបញ្ចូលនិងបញ្ជេញអ្នកទោសនៅក្នុងមន្ទីរសន្តិសុខស-២១ ។ សំណួរដំបូងឡើយសួរថា ការងាររបស់លោកនោះ ការិយាល័យ ឬក៏ទីកន្លែងធ្វើការរបស់លោកហ្នឹង នៅកន្លែងណានៃមន្ទីរស-២១?

ឆេ៖ ការិយាល័យនៃកន្លែងផ្នែកកងការពារ គឺកន្លែង ហ៊ ហ្នឹងគឺនៅខាងក្នុងហ្នឹង ហើយ ហ៊ គេឲ្យខ្ញុំមកធ្វើបញ្ជីនៅខាងក្នុងជាមួយគេកន្លែងហ្នឹង ។ នេះគឺនៅក្នុងគុក ។

ប្រធានអង្គជំនុំ៖

មន្ត្រីតុលាការដាក់បញ្ចាំងទូរ*ម៉ាស៊ីនស្កាយ* ដើម្បីឲ្យមានរូបភាពនៅកញ្ចក់*អេក្រង់* ទូរទស្សន៍ នូវឯកសារដែលមានលេខ ERN00189137 ។ ដាក់នៅ*ស្កាយៗ* អត់មានដាក់នៅក្នុងនោះទេ ដាក់នៅនោះ អា*ម៉ាស៊ីនស្កាយ* នោះដើម្បីឲ្យបាន-- ។

ឡើងលើបន្តិចមើល៍ ហើយមាន-- ភ្លើង បន្តុយភ្លើងបន្តិចទៅភ្លឺម្ល៉េះ ។

អ្ហែ! ធំណាស់ ។ ពង្រួញបន្តិចទៅឲ្យវាច្បាស់ ។ បាន។! ។

សួរដោយប្រធានអង្គជំនុំ៖

សៈ រូបភាពនេះមើល រូបភាពនេះគឺខាងលើ ខាងលិច មិនមែនខាងជើងទេ ខាងលើខាងលិច ខាងស្តាំដៃខាងកើត-- ខាងស្តាំដៃខាងជើង ហើយខាងក្រោមហ្នឹងខាងកើត ឆ្វេងដៃខាងត្បូង ។ នេះជារូបភាពហើយមានរូបភាពអគារ យើងថតពីលើមានអគារដាក់ជាអក្សរឡាតាំងសម្គាល់នេះមានអគារចំនួនប្រាំ។ អគារនៅចូលពីកើតមកអគារខាងឆ្វេងដៃបង្អស់ គឺអគារ “A” ហើយបន្ទាប់មកទៀត អគារទទឹងថ្ងៃ ដែលនៅចំហៀងខាងត្បូង អគារ “B” ទទឹងថ្ងៃដែរ នៅអគារនៃចំហៀងខាងជើង អគារ “C” ហើយនៅខាងស្តាំដៃ អគារ “D” ហើយនៅចំពីមុខ ដែលមានរាងអក្សរ “T” នេះគេដាក់អគារ “E” ភាសាបារាំង យើងហៅថា “E” ហើយ-- តើការិយាល័យរបស់លោក កន្លែងដែលលោកធ្វើការហ្នឹងនៅ

ចំណុចណាមួយនៅក្នុងអគារទាំងប្រាំនៃគុកទួលស្លែងនេះ?

[១៤:២៤:០៥]

ឆ៖ គឺនៅខាងមុខជាប់របងមាត់ទ្វារ ខាងកើតអគារ "E" មកមុខនោះ ។

ប្រធានអង្គជំនុំ៖

មន្ត្រីតុលាការឲ្យបិទគាត់ ឬក៏ស្ទីប្រដាប់គាត់ចង្អុល ។

លោក សួស ធី៖

កន្លែងការិយាល័យនេះគឺនៅប្រឡោះនេះមកកើត មកនេះ មកត្រង់នេះ ។

ប្រធានអង្គជំនុំ៖

បានហើយ អរគុណ ។ មន្ត្រីតុលាការដកឯកសារចេញពី *ម៉ាស៊ីនស្កាយ* ។

សួរដោយប្រធានអង្គជំនុំ៖

ស៖ លោក សួស ធី សូមលោកនិយាយរៀបរាប់ជូនដល់អង្គសវនាការទាំងមូលបានដឹងអំពីរបៀបរបបជាទូទៅនៃការចុះបញ្ជីចូល និងការចុះបញ្ជីចេញ អ្នកធ្វើបញ្ជីចេញនៃមន្ទីរស-២១ តើត្រូវប្រព្រឹត្តទៅយ៉ាងដូចម្តេច? លោកកុំអាលឆ្លើយចាំស្តាប់មតិយោបល់របស់មេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ តើលោកមានបញ្ហាអីទៅ? លោកអាឡាំង វ៉ែនណឺ?

លោក អាឡាំង វ៉ែនណឺ៖

សូមអភ័យទោសលោកប្រធាន សូមឲ្យកំណត់ត្រាសូមឆ្លើយនឹងសំណួរ-- ដែលឆ្លើយសួរសំណួររបស់លោកប្រធាន ហើយគាត់បានចង្អុលបិក គាត់បានចង្អុលទៅអគារ "E" ប៉ុន្តែអត់បានថា អគារ "E" ហ្នឹងទេ ។ អ៊ីចឹងសូមឲ្យកត់ត្រានៅក្នុងកំណត់ត្រាផងទាន ។

ប្រធានអង្គជំនុំ៖

អ៊ីចឹង គឺផ្នែកខាងប្រតិចារឹកសូមកត់ត្រាផង អគារ "E។" ប៉ុន្តែផ្នែកខាងកើត ផ្នែកខាងមុខអគារ "E" ហ្នឹងបណ្តោយថ្ងៃ ។ អ៊ីចឹង គឺសំដៅផ្នែកខាងមុខ ចាប់ពីកណ្តាលមកខាងមុខ នេះជាការិយាល័យរបស់គាត់របស់លោក សួស ធី គាត់ធ្វើការ ។

[១៤:២៦:៣៣]

ស៖ តើលោកអាចនិយាយរៀបរាប់អំពីប្រតិបត្តិការរបស់លោកនៅក្នុងការធ្វើបញ្ជីទូទៅបានដែរឬទេ? របៀបដែលគេធ្វើយ៉ាងម៉េចក្នុងការធ្វើបញ្ជីទទួលអ្នកទោសចូល ហើយនិងធ្វើបញ្ជីបញ្ចេញ

អ្នកទោសពីមន្ទីរសន្តិបាលស-២១ មជ្ឈមណ្ឌលភ្នំពេញនេះ?

អ៊ុះ នៅពេលដែលអ្នកទោសគេនាំចូលមក គឺអង្គភាពកងពិសេសគឺគេនាំចូលមក ។ អង្គភាពកងពិសេសហ្នឹងគេនាំចូលពីក្រៅមក គឺគេចូលតែតាមខាងមុខ ខាងកើតហ្នឹង តាមខ្លោងទ្វារហ្នឹង ចូលមកដល់កន្លែងហ្នឹង គឺគេឲ្យអង្គុយហើយខ្ញុំបានកត់ឈ្មោះ ។ កត់ឈ្មោះនោះ គឺគេយកម្នាក់ម្តង ដើរម្នាក់ម្តងៗ យកមកកត់ឈ្មោះ ។ ឈ្មោះនោះ គឺកត់អត់វែងទេ គឺគ្រាន់តែកត់ឈ្មោះ តួនាទី ហើយនិងឈ្មោះឪពុកម្តាយ ហើយនិងភូមិឃុំតែប៉ុណ្ណឹង គឺហើយៗ អាហ្នឹងគេហៅប្រវត្តិរូបសង្ខេប ។ កត់ឈ្មោះរួចហើយ គឺ-- ប៉ុន្តែខ្ញុំសូមបញ្ជាក់ គឺថានៅពេលដែលអ្នកទោសចូលមកហ្នឹង គឺអ្នកទោសអត់មានបើកមុខអីទេ គឺចងមុខដាក់ខ្មោះទាំងអស់ ។ នៅពេលដែលកត់ឈ្មោះហ្នឹង គឺអត់មានបើកមុខដែរ ហើយអត់មានស្រាយចំណងដែរ គឺនៅជាប់ទាំងអស់ដដែល ។ នៅពេលដែលខ្ញុំកត់ឈ្មោះរួចហើយ គឺអ្នកទោសគឺបញ្ជូនទៅកន្លែងថត នៅពេល-- ពីព្រោះកន្លែងថតហ្នឹង ហើយនិងកន្លែងខ្ញុំកត់ហ្នឹង គឺនៅជាមួយគ្នា នៅជាប់គ្នាហ្នឹង ។ ខ្ញុំគ្រាន់តែកត់ខាងក្រៅទ្វារថត ហើយដល់គេថត គេយកចូលក្នុងបន្ទប់ថតហ្នឹងទៅ ។ នៅពេលថតនោះ គឺគេបើកមុខអ្នកទោសហើយ ហើយដល់ពេលថតរួចហើយ ទើបគេចងមុខអ្នកទោសវិញ រួចហើយកងការពារយកអ្នកទោសដែលថតរួចហើយហ្នឹង យកបញ្ជូលទៅតាមអគារទាំងអស់ ។ ហើយនៅពេលបញ្ជូលអគារហើយ គឺខ្ញុំបានកត់ប្រវត្តិរូបហើយ កត់ឈ្មោះហើយ គឺខ្ញុំត្រូវទៅស្រង់តើឈ្មោះណានៅបន្ទប់លេខប៉ុន្មាន លេខតូចប៉ុន្មាន លេខធំប៉ុន្មាន នៅអគារណា ដើម្បីស្រង់ចូលក្នុងបញ្ជី ដើម្បីដាក់ឲ្យដឹងថា អ្នកទោសនេះនៅបន្ទប់តូចប៉ុន្មាន បន្ទប់ធំប៉ុន្មាន និងអគារណាដើម្បីងាយស្រួលដល់កងសួរចម្លើយយកឈ្មោះអ្នកទោស យកទៅសួរចម្លើយ ។ អាហ្នឹងនិយាយអំពីរបៀបចូល ។

ហើយបើនិយាយពីរបៀបចេញវិញ គឺនៅពេលដែលមានចំណារចារពី ឌុច គឺ ឌុច គេយកបញ្ជីហ្នឹងយកមកប្រគល់ឲ្យ ហ៊ិ ហើយ ហ៊ិ គឺបញ្ជូនបញ្ជីហ្នឹង យកមកឲ្យខ្ញុំស្រង់ដាក់លេខបន្ទប់លេខអគារដើម្បីឲ្យងាយស្រួលដល់កងការពារយកចេញ ។ ហើយនៅពេលដែលយកចេញទៀត គឺអ្នកទោសត្រូវយកមកនៅទល់ខាងមុខខ្លោងទ្វារ ដើម្បីកុំឲ្យច្រឡំ ពីព្រោះ ហ៊ិ ថា ប្រសិនបើខ្ញុំធ្វើការច្រឡំអ្នកទោសគឺយើងជាខ្ទាំង យើងបំបាត់ភស្តុតាង។ ដូច្នេះ នៅពេលដែលមកដល់មាត់ទ្វារហ្នឹងហើយ គឺខ្ញុំបានសួរអ្នកទោសមួយសារទៀត ដើម្បីឲ្យត្រឹមតាមនាទី ទៅតាមឈ្មោះពិតប្រាកដ ។ នៅពេលដែលខ្ញុំសួរចប់ហើយ គឺខ្ញុំបានយកបញ្ជីនោះ ប្រគល់ឲ្យទៅ ហ៊ិ វិញ ដើម្បី ហ៊ិ គេចាត់តាំងកម្លាំង គេយកចេញ ។

សៈ អ៊ីចឹង បានសេចក្តីថា ការធ្វើបញ្ជើដំបូងនៃការបញ្ជូនអ្នកទោសចូលទៅក្នុងអគារឃុំឃាំងនីមួយៗ គឺឆ្លងកាត់ពីកងពិសេស ដែលគេបញ្ជូនពីក្រៅចូលមកដល់ គឺមកដល់លោក ការងាររបស់លោកធ្វើការដកស្រង់នូវប្រវត្តិរូបសង្ខេបរបស់អ្នកទោសជាមុនសិន មុននឹងបញ្ជូនទៅថតរូប ។ នេះជាតាមចម្លើយរបស់លោកដែលយើងបញ្ជាក់ឡើងវិញ ជាការត្រឹមត្រូវដែរឬទេ?

ឆៃ ពិត ជាការត្រឹមត្រូវ ។

សៈ ចុះពេលណា ទើបប្រវត្តិរូបអ្នកទោសត្រូវបានបិទរូបថត?

ឆៃ ការបិទរូបថតរបស់ប្រវត្តិរូបអ្នកទោស គឺធ្វើជាបណ្តើរៗ ពីព្រោះខ្ញុំម្នាក់ឯង មិនអាចធ្វើឲ្យបានលឿនទេ គឺគេឲ្យរូបថតប៉ុន្មាន បើមានពេលបិទបណ្តើរទៅ បើអត់ពេលគឺទុកសិន ចាំទទួលអ្នកទោសបន្ត ហើយនិងប្រចាំការដើម្បីកងសួរចម្លើយឲ្យដឹងឈ្មោះអ្នកទោសនៅបន្តប់ណាៗ ។

សៈ ទីពីរ អំមិញគឺលោកបានរៀបហើយ ថាក្រោយពីថតរូបរួច អ្នកទោសត្រូវបញ្ជូនទៅក្នុងអគារឃុំឃាំង ដោយមានអគារឃុំឃាំងរួម ហើយនិងអគារឃុំឃាំងដោយឡែក ហើយលោកបានអះអាងថា មានការបញ្ជាក់ថាជាថ្មីម្តងទៀត ដើម្បីឲ្យច្បាស់លាស់ថា មនុស្សណានៅក្នុងបន្តប់ឃុំឃាំងរួម ហើយមនុស្សណានៅក្នុងបន្តប់ឃុំឃាំងតូច ជាក់លាក់ដើម្បីងាយក្នុងការគ្រប់គ្រង ។ អ៊ីចឹងមែនទេ?

ឆៃ ក្នុងការបញ្ជូនអ្នកទោសទៅចូលឃុំឃាំង គឺបើសិនជាខាងបន្តប់តូច គេនៅទំនេរគឺគេបញ្ជូនទៅបន្តប់តូចទាំងអស់ លើកលែងតែ បន្តប់ធំ-- លើកលែងតែបន្តប់តូចនៅខាងក្រោមហ្នឹងពេញ បានគេបញ្ជូនទៅខាងលើ ។

[១៤:៣៣:៥២]

សៈ ប៉ុន្តែយើងធ្វើម៉េច យើងកំណត់មុន លោកជាអ្នកកំណត់មុន ថាឥឡូវបន្តប់តូចហ្នឹង វាមានទំនេរម្តែបន្តប់ ពីលេខ១ ទៅ លេខ២០ ឧទាហរណ៍ ឬឧបមាថាអ៊ីចឹង លោកអាចដាក់ស្រេចថា លោក “ក” ដែលមកហ្នឹង ត្រូវដាក់បន្តប់លេខ១ លោក “ខ” ដាក់បន្តប់លេខ២ ឬក៏លោកអត់កំណត់អ៊ីចឹងទេ លោកគ្រាន់តែធ្វើប្រវត្តិរូប ហើយបន្ទាប់មកមានការប្រគល់ផ្ទេរអ្នកទោសដែលចូលហ្នឹងឯងឲ្យទៅអ្នកកងការពារដើម្បីនាំទៅដាក់ឃុំឃាំង ។ បន្ទាប់មក ទើបលោកទៅធ្វើបញ្ជើបញ្ជាក់ម្តងទៀត ថាបន្តប់លេខប៉ុន្មាននេះ គឺជាអ្នកទោសឈ្មោះនេះ បន្តប់លេខប៉ុន្មានណោះ អ្នកទោសប៉ុន្មានណោះ បានន័យថា លោកធ្វើពីរដងធ្វើបញ្ជើរួមហើយ នឹងធ្វើបញ្ជើគ្រប់គ្រងអ្នកទោសផ្ទាល់ នៅពេលដែលចូលទៅដល់ដាក់ឃុំឃាំងរួចនោះ ។ តើអ៊ីចឹងមែនទេ? ឬក៏លោកសម្រេចខ្លួនឯងថា មនុស្សនេះត្រូវឃុំនៅក្នុងបន្តប់ឃុំឃាំងលេខ

ប៉ុន្មានណោះ? មនុស្សនេះត្រូវបន្ទប់ឃុំឃាំងលេខប៉ុន្មានណោះ?

ឆៃ៖ ការយកអ្នកទោសយកទៅដាក់ក្នុងបន្ទប់ គឺអាស្រ័យទៅលើកងការពារ គេជាអ្នកដាក់ទេ គឺខ្ញុំអត់មានសម្រេចថា អ្នកនេះត្រូវដាក់កន្លែងនេះ អ្នកនោះដាក់ទៅកន្លែងនោះទេ ពីព្រោះឲ្យតែបន្ទប់ទំនេរគឺកងការពារ គេដាក់ចូលហើយ ។ អាចជាពិសេសមុនដំបូងគឺដាក់ចូលបន្ទប់តូច ហើយខ្ញុំមិនបានសម្រេចថាឈ្មោះនេះ ត្រូវដាក់បន្ទប់នេះ ឈ្មោះនោះ ដាក់បន្ទប់នេះ អាហ្នឹងអាស្រ័យទៅលើម្ចាស់ការរបស់កងការពារទេ ។

សៈ សំណួរករណីនេះ លោកធ្វើយ៉ាងណាម៉េចទៀត បន្តនៃបញ្ជើរបស់លោក? លុបប្រវត្តិរូប ហើយដែលលោកគ្រប់គ្រងថា អ្នកទោសណាដែលនៅក្នុងមន្ទីរ-- នៅកន្លែងឃុំឃាំងណា? ឃុំឃាំងរួម? ឬក៏ឃុំឃាំងដោយឡែកណាៗដែលលោកគ្រប់គ្រងនោះ សួរថាតើធ្វើការងារយ៉ាងម៉េចទៀត? នៅពេលដែលកងការពារយកអ្នកទោសទាំងអស់ បន្ទាប់ពីថតរូបយកទៅដាក់តាមបន្ទប់ឃុំឃាំងរួម ឬក៏ឃុំឃាំងដោយឡែកៗទៅហើយ តើលោកធ្វើកិច្ចការអ្វីទៀត?

ឆៃ៖ ដែលខ្ញុំទៅយកបញ្ជើអ្នកទោសទៅតាមបន្ទប់ហើយ បន្ទាប់ពីការខ្ញុំធ្វើមានលេខបន្ទប់អីហើយ គឺខ្ញុំមកកន្លែងវិញ គឺខ្ញុំវ៉ៃបញ្ជើសាថ្មី ដើម្បីរាយការណ៍ទៅខាងមន្ទីរសួរចម្លើយប្រចាំថ្ងៃ និងថ្ងៃស្អែក ។

សៈ សូមអញ្ជើញ អញ្ជើញបន្តទៀតចុះ ។

ឆៃ៖ សូមបញ្ជាក់អំពីបញ្ហានេះ គឺថាការរាយការណ៍ទៅខាងលើ គឺអត់មាន ក្នុងបញ្ជើដាក់លេខបន្ទប់តូច បន្ទប់ធំទេ គឺដាក់តែឈ្មោះ តួនាទី និងភូមិឃុំទេ តែប៉ុណ្ណឹងទេ គឺអត់មានរាយការណ៍-- ឈ្មោះ តួនាទី និងក្រសួងទេ ចំពោះរឿងលេខបន្ទប់តូចៗធំ គឺអត់មានរាយការណ៍ទៅលើទេ ។ អានេះ គេបន្ទប់តូច បន្ទប់ធំហ្នឹង គឺខ្ញុំសម្រាប់តែចំណាំខ្លួនឯង នៅក្នុង-- ឲ្យដឹងអ្នកទោសថា នៅអគារណា? បន្ទប់ណា? នៅបន្ទប់តូច បន្ទប់ធំ ទីប៉ុន្មានៗ? ប៉ុណ្ណឹងទេ ។

[១៤:៣៧:២៦]

សៈ ក្នុងការបំពេញភារកិច្ចរបស់លោក នៅពេលដែលគេនាំចាប់មនុស្សបញ្ជូនមក គឺឆ្លងកាត់លោក ។ សំណួរសួរថា តើគ្រប់មនុស្សដែលបញ្ជូនចូលមកសុទ្ធតែត្រូវបានដកស្រង់ប្រវត្តិរូប ថតរូបទាំងអស់ ឬក៏មានករណីលើកលែងខ្លះដែលមិនបានធ្វើប្រវត្តិរូបសង្ខេប ហើយក៏មិនបានថតរូបដែរឬទេ? តើមានករណីនេះដែរឬទេ? ឬក៏ត្រូវតែសុទ្ធតែដកស្រង់យកប្រវត្តិរូបទាំងអស់ ហើយត្រូវតែថតរូបទាំងអស់?

ឆេ៖ ចំពោះអ្នកទោសដែលចូលមក គឺមិនអាចចូលមកដល់ខ្ញុំទាំងអស់ទេ ពីព្រោះអ្នកទោសសំខាន់ៗ គឺគេដាក់ដោយឡែក ។ ដូច្នេះ គេមិនយកមកចូលនៅកន្លែងខ្ញុំទេ គឺគេយកទៅគុកកន្លែង គុកពិសេសគេតែម្តង ហើយក្រោយមកបាន ហ៊ ហ្នឹង គេយកឈ្មោះហ្នឹង ឱ្យខ្ញុំវែបញ្ជូលក្នុងបញ្ជី ។

សៈ ចុះអ្នកទោសសំខាន់ៗហ្នឹង តើមានការថតរូបដែរឬទេ? ហើយបើថតរូប ថតយ៉ាងម៉េចទៅ? បើបញ្ជីលោកគឺ ហ៊ ជាអ្នកបញ្ជូនមកទេ ។ ចុះថតរូបវិញ តើមានការថតរូបដែរឬទេ? ហើយបើថតៗ យ៉ាងម៉េច?

ឆេ៖ ចំពោះអ្នកទោសសំខាន់ៗ ការថតរូបគឺខ្ញុំក្តាប់អត់បានទេ ពីព្រោះមិនដឹងជា ហ៊ បញ្ជូនទៅជាងថតរូបយ៉ាងម៉េច? ពីព្រោះមនុស្សសំខាន់ៗ ថ្នាក់លើគេច្រើនដឹងទាំងអស់ ។

សៈ លោកដែលបានឃើញនូវកុមារ ឬក៏កូនក្មេង ដែលត្រូវបញ្ជូនមកជាមួយនឹងឪពុក ឬក៏ជាមួយម្តាយរបស់វា ចូលមកមន្ទីរស-២១ ដែរឬទេ? ហើយថាតើកុមារទាំងនោះ បើមានវិញ តើបានធ្វើបញ្ជីប្រវត្តិរូបដែរឬទេ? ឬក៏អត់ទេ?

ឆេ៖ ចំពោះកុមារដែលមកចូលមន្ទីរគុកទួលស្លែងហ្នឹង គឺមាន គឺមកតាមឪពុកម្តាយ ហើយចំពោះកុមារហ្នឹង គឺអត់ធ្វើប្រវត្តិរូបទេ ។

សៈ ហើយមានបានថតរូបដែរឬទេ? ឬក៏អត់ថតរូបទេ? អត់ទាំងប្រវត្តិរូប អត់ទាំងថតរូប ឬក៏យ៉ាងម៉េច?

ឆេ៖ ចំពោះការធ្វើបញ្ជី គឺខ្ញុំអត់បានធ្វើទេ តែចំពោះការថតរូប គឺនៅកន្លែងហ្នឹងគឺអត់មានទេ ។

សៈ អ៊ីចឹងអត់ទាំងដកស្រង់នូវប្រវត្តិរូបសង្ខេបរបស់កុមារ ហើយក៏គ្មានរូបថត-- មិនបានថតរូបដែរ មិនៗត្រឹមឱ្យមានការថតរូបទេ អ៊ីចឹងមែនទេ?

ឆេ៖ បាទ, អ៊ីចឹងមែន ។

[១៤:៤០:៥៣]

សៈ តាមការកត់សម្គាល់របស់លោក ព្រោះលោកនៅច្រកចេញចូល យើងនិយាយអីក៏បានដែរ ច្រកចេញចូល បានន័យថា គ្រប់មនុស្សដែលចូលភាគច្រើន លោកក្តាប់បាននូវបញ្ហានេះ ។ សំណួរថា តើកុមារដែលបញ្ជូនមកនែ៎ សរុបពេញតាំងពីដើមទី ដែលលោកធ្វើការរហូតដល់ពេលថ្ងៃ៧ មករា ឆ្នាំ ៧៩ នោះ ។ តើមានសរុបប៉ាន់ស្មាន មិនប្រហែលមិនជាក់លាក់ទេ ប្រហែលជាប៉ុន្មាននាក់ដែរ? កុមារដែលត្រូវបញ្ជូនមកជាមួយឪពុកម្តាយរបស់គេនោះ មកទីនោះ ។

ឆេ៖ ការបញ្ជូនកុមារមកទីនោះ ដោយខ្ញុំនិយាយការពិតទៅ គឺខ្ញុំវាមិនចាំអារម្មណ៍ ពីព្រោះភារកិច្ច គិតតែពីរឿងកត់អ្នកដែលត្រូវការកត់ ។ ដូច្នេះ ការសរុប ចំនួនគឺខ្ញុំអត់បានគិតគូរ ហើយក៏-- បើខ្ញុំស្មានចេះតែនិយាយ ក៏ចេះតែបាន ប៉ុន្តែវាយកជាការពិត វាមិនសូវបាន ។ ដូច្នេះការណ៍នេះខ្ញុំពិបាកឆ្លើយ ។

សៈ ច្រើនទេ? មើលទៅច្រើនទេ? យើងយល់ ព្រោះយើងយល់បញ្ហា បញ្ហាយើងប្រហែលជាមិនបានជាក់លាក់ទេ ព្រោះលោកបាននិយាយហើយ ថាលោកមិនបានធ្វើបញ្ជី មិនបានធ្វើប្រវត្តិរូប មិនបានថតរូបទេ ប៉ុន្តែច្រើនតិច យើងចង់ដឹងថាវាអាចចូលរយនាក់ ។ ឧបមាថា ប្រហែលជារាប់រយនាក់ មួយរយឬក៏ពីររយនាក់ ឬក៏បួន-ប្រាំនាក់ទេ វាអាចមានលក្ខណៈអ៊ីចឹងទេ ។ ប្រហែលជាចូលរយនាក់អីអ៊ីចឹងទេ ឬក៏តិចតួចទេ?

ឆេ៖ ខ្ញុំរកស្មាន ប្រហែលចូលរយនាក់ហើយ ។

សៈ អរគុណ ។ ចុះអំពីអ្នកទោសបរទេសវិញលោកដែលជួបទេ? ដែលឃើញគេបញ្ជូនមកទេ? អ្នកទោសបរទេស ដូចជា ជនជាតិនាយពួកលោកបស្ចិមប្រទេស ពួកស្បែកស នៅអ៊ឺរ៉ុប អ៊ីចឹង តើលោកដែលបានជួបទេ? ហើយគេប្រព្រឹត្តទៅយ៉ាងម៉េច ទូវក្នុងការចុះបញ្ជីអ្នកទោសចូល ឬក៏ចេញនោះ?

ឆេ៖ ចំពោះអ្នកទោសបស្ចិមប្រទេស គឺបើតាមខ្ញុំដឹងគឺមិនបានចូល ចេញចូលទៅតាមកន្លែងខ្ញុំទេគឺគេយកទៅដាក់គុកពិសេសហ្នឹងតែម្តង ។

សៈ សូមអញ្ជើញៗ បន្តទៀតចុះ ។ សូមអញ្ជើញនិយាយតទៅទៀត ។

ឆេ៖ ហើយចំពោះចំនួននិងឈ្មោះ គឺហ៊ិ គេប្រគល់ឲ្យក្រោយមកវិញ ដើម្បីចុះបញ្ជីចូលជាប្រចាំថ្ងៃ ។

[១៤:៤៣:៥៩]

សៈ សរុបទៅមានប្រហែលប៉ុន្មាននាក់ដែរ ពួកបស្ចិមប្រទេសជាប់នៅទីនោះ?

ឆេ៖ ខ្ញុំស្មានមិនច្បាស់ ប្រហែលជាបី ឬបួននាក់ទេ ។

សៈ លោកដែលបានទទួលចុះបញ្ជីចូលអ្នកទោសស្ត្រី ដែលមានផ្ទៃពោះដែរឬទេ?

ឆេ៖ ចំពោះស្ត្រីដែលមានផ្ទៃពោះ គឺខ្ញុំមិនសូវជាចាប់អារម្មណ៍ ពីព្រោះវាភ្លេចហើយ គឺមិនដឹងជាមាន ឬក៏មិនមាន ខ្ញុំមិនច្បាស់ ។

សៈ ចុះលោកដែលជួបការទទួលមកដល់នៃឈ្លើយសឹកវៀតណាម ឬក៏ជនស៊ីវិលវៀតណាមដែរឬទេ នៅក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធរវាងកម្ពុជា-វៀតណាម?

ឆេ៖ កាលដែលមានជម្លោះប្រដាប់អាវុធជាមួយវៀតណាម គឺខ្ញុំបានទទួលអ្នកទោសទាំងផ្នែកទាហាន ទាំងផ្នែកស៊ីវិល ។

សេ៖ ផ្នែកឈ្លើយសឹកវៀតណាម ទាហានវៀតណាមហ្នឹង មកដល់ទីនោះ ប្រហែលជាប៉ុន្មាននាក់ដែរ? ហើយជនស៊ីវិលប្រហែលប៉ុន្មានដែរ តាមលោកនៅចងចាំ?

ឆេ៖ កាលដែលធ្វើបញ្ជីអ្នកទោស ចំពោះវៀតណាមនេះ គឺខ្ញុំ ដូចជាមិនបានជាចងចាំច្បាស់ មិនដឹងចំនួនប៉ុន្មាន? អីប៉ុន្មាន? មិនដឹងជាទាហានប៉ុន្មាន? មិនដឹងជាស៊ីវិលមានប៉ុន្មាន?

ទុកខ្ញុំសូមបញ្ជាក់បន្តិចកន្លែងៗនេះ ពីព្រោះការងារនោះ ខ្ញុំធ្វើយ៉ាងម៉េចឲ្យតែទាន់សភាពការណ៍ វាអត់គិតពីរឿងបញ្ជាអ្នកទោសណាៗទេ ពីព្រោះខ្ញុំធ្វើតែម្នាក់ឯង ។

ប្រធានអង្គជំនុំ៖

អរគុណ ។ ឥឡូវនេះ ដល់ម៉ោងសម្រាក អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំនាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញដើម្បីបន្តនីតិវិធីសវនាការតទៅទៀត ។

មន្ត្រីតុលាការសម្របសម្រួលផ្តល់នូវកន្លែងសមរម្យដល់សាក្សីផង ហើយឲ្យនាំគាត់មកកាន់សាលសវនាការវិញ ឲ្យបានមុនម៉ោងបី ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា មានការងារអីទៅ ។

[១៤:៤៧:១៤]

លោក អានីស អះមេដ៖

ខ្ញុំសូមអភ័យទោស ខ្ញុំសូមបំភ្លឺមួយ ដោយសារ--ប្រហែលជាការបកប្រែទេ ។ ដូច្នេះហើយ ខ្ញុំសូមឲ្យលោកចៅក្រមសួរសំណួរ ដើម្បីបញ្ជាក់ នៅពេលដែលប្រធានសួរ ថាតើមានក្មេងប៉ុន្មាននាក់ត្រូវបានគេឃុំខ្លួន? លោកប្រធានថា សួរថាមួយរយ ឬក៏យ៉ាងណា? ខ្ញុំមិនអាចទទួលចម្លើយពីសាក្សី ថាតើមួយរយ ឬក៏រាបរយ? ដូច្នេះហើយ គឺខ្ញុំស្នើសុំលោកប្រធានឲ្យសួរទៅសាក្សីបញ្ជាក់ទៅលើចំនួនកូនក្មេងដែលគេឃុំនៅទីនោះ ។

លោកស្រី សែ កុលវុឌ្ឍី៖

សូមអញ្ជើញក្រោកឈរ ។

[សវនាការសម្រាកពីម៉ោង ១៤:៤៨ នាទី ដល់ម៉ោង ១៥:០៣ នាទី]

ប្រធានអង្គជំនុំ៖

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការស្តាប់សក្ខីកម្ម សាក្សី សួស ធី បន្ត ។

អម្បាញ់មិញនេះគឺមុននឹងសម្រាក តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានស្នើនូវសំណួរមួយមកយើង ដើម្បីសួរបញ្ជាក់ដល់លោកសាក្សី ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់អំពីចំនួនកុមារសរុប ដែលលោកបានធ្វើការសង្កេតនៅក្នុងអំឡុងពេលដែលលោកធ្វើជាអ្នកកាន់បញ្ជីចេញចូលនៃអ្នកទោសនៃមន្ទីរសន្តិសុខស-២១មជ្ឈមណ្ឌលភ្នំពេញ អត់ច្បាស់ ឥឡូវហ្នឹងគាត់ចង់ច្បាស់ ។ ហើយយើងក៏ដឹងដែរថាលោកនៅតែនិយាយភាពមិនច្បាស់លាស់របស់លោកដោយសារលោកមិនបានគ្រប់គ្រងផ្នែលនៃបញ្ជីរបស់កុមារ ដែលត្រូវបានបញ្ជូនខ្លួនទៅកាន់ទីនោះ ទៅជាមួយឪពុកម្តាយរបស់គេនោះទេ ។ ប៉ុន្តែ យើងធ្វើការសង្កេត លោកនិយាយអំមិញគឺរយនាក់ អ៊ីចឹងវាអត់ច្បាស់ អ៊ីចឹងលោកអាចកំណត់ទេ ។ ថាតើប្រហែលជាមួយរយនាក់ ឬក៏ជាងមួយរយនាក់ ឬក៏ច្រើនរយនាក់? នេះក៏មានន័យថាមិនច្បាស់ដែរ ប៉ុន្តែវាអាចយល់បានថាប្រហែលជាមួយរយនាក់ វាអាចតិចជាង ឬក៏ច្រើនជាងមួយរយនាក់ បានន័យថាចន្លោះពីជាងមួយរយទៅក្រោមពីររយ ។ ច្រើនរយនាក់គឺអាច ២០០,៣០០,៤០០,៥០០ អ៊ីចឹងទៅ វាអាចមាន លក្ខណៈអ៊ីចឹង ។ មិនច្បាស់ដែរតែស្តាប់ទៅយល់ ។ ឥឡូវហ្នឹង លោកអាចឆ្លើយសំណួរហ្នឹងឲ្យច្បាស់ជាងមុនបានទេ? ប្រហែលជាប៉ុន្មាន?

ឆេ៖ ចំពោះកុមារបើតាមខ្ញុំមិនច្បាស់ពិតប្រាកដ ប៉ុន្តែបើតាមខ្ញុំស្មាន ពីព្រោះប្រហែលជាមួយរយជាងនាក់ទេ ទៅពីររយយ៉ាងច្រើនប៉ុណ្ណឹងទេ បើតាមខ្ញុំស្មាន ការពិតខ្ញុំមិនបានដឹងច្បាស់ទេ ។

សៈ អ៊ីចឹងច្បាស់ហើយលោកព្រះរាជអាជ្ញាគឺប្រហែលជាជាងមួយរយនាក់ទៅពីររយ ។

ឈ្មោយសឹកវៀតណាមដែលយើងបានសួរអំមិញគឺថាមានការមកដល់ ប៉ុន្តែអត់ដឹងច្បាស់ទេ ដូចគ្នាដែរប្រហែលជាដូចកុមារប្រហែលជារយនាក់ ឬក៏តិចជាងរយនាក់ ឬក៏ច្រើនជាងរយ? បានន័យថា ពីររយ ឬក៏បីររយអ៊ីចឹងទៅ យើងមិនចង់បានលេខជាក់លាក់ទេ ពីព្រោះថា ភាពជាក់លាក់ដែលរឿងហេតុដែលកើតឡើង ជាងសាមសិបឆ្នាំហើយនោះ ជាការលំបាកចងចាំណាស់ ។ និយាយពីរឿងឈ្មោយសឹកវៀតណាមដែលបានបញ្ជូនមកដល់មន្ទីរសន្តិសុខស-២១ហ្នឹង ប្រហែលជាប៉ុន្មានដែលលោកចងចាំ?

ឆេ៖ ការចងចាំរបស់ខ្ញុំគឺវាមិនបានច្បាស់។ ប៉ុន្តែបើខ្ញុំស្មានគឺវាមិនដល់ ១០០ទេ ចំពោះឈ្មោយសឹក វៀតណាម។

សៈ ចុះជនស៊ីវិលវៀតណាមវិញប្រហែលជាប៉ុន្មានដែរ?

ឆៈ ជនស៊ីវិលវៀតណាមក៏ខ្ញុំមិនច្បាស់ដែរ ប៉ុន្តែខ្ញុំស្មានក៏វា បើមួយរយ ក៏វាមួយរយមិនលើសខ្លាំងដែរ ប៉ុណ្ណឹង។

សៈ ទីពីរបញ្ហានៃពេលវេលាធ្វើការរបស់លោក តើលោកធ្វើការងារនៅទីនោះក្នុងការរៀបចំធ្វើបញ្ជីទទួលអ្នកទោសចូល ឬក៏បញ្ចេញ ឥឡូវបញ្ចេញយើងមិនទាន់និយាយទេ យើងកម្រិតត្រឹមតែបញ្ចូលសិន បញ្ជីបញ្ចូលអ្នកទោសដែលចាប់ខ្លួនបញ្ជូនមកពីខាងក្រៅ ដោយផ្នែកខាងកងពិសេសបញ្ជូនមកឱ្យលោកនោះ សំណួរសួរថា តើលោកធ្វើការងារនៅពេលណា? ពីម៉ោងប៉ុន្មាន ដល់ម៉ោងប៉ុន្មាន?

ឆៈ ការធ្វើបញ្ជីចូលរបស់អ្នកទោស ចំពោះការងារម៉ោងគឺគេអត់កំណត់ម៉ោងទេ គឺគេឱ្យខ្ញុំប្រចាំការម្តែបួនម៉ោង ។ ជួនកាលអ្នកទោសមកពេលព្រឹកក៏មាន ថ្ងៃត្រង់ក៏មាន ល្ងាចក៏មាន ជួនណាយប់ម៉ោង ដប់ពីរយប់ក៏មាន ម៉ោងមួយ ក៏មាន ម៉ោងបួន ភ្លឺក៏មាន អត់ទៀងទេ ។

សៈ អ៊ីចឹង គឺការងាររបស់លោកគឺធ្វើការប្រចាំការម្តែបួនម៉ោងលើម្តែបួនម៉ោង ហើយមានន័យថា ការបញ្ជូនអ្នកទោសមកដល់ពេលណា គឺលោកធ្វើការពេលនោះតែម្តង ដោយមិនពន្យារពេលទេ អ៊ីចឹងមែនទេ?

ឆៈ បាទ, ពិតជាអ៊ីចឹងមែន ។

សៈ លោកនៅករណីនៅទីនោះ តើលោកមានដែលជួបប្រទះនូវស្ថានភាពនៃការមកដល់អ្នកទោសអ្នកដែលគេត្រូវចាប់ខ្លួនបញ្ជូនមកដល់ទីនោះមានចំនួនច្រើនរយនាក់ទេក្នុងមួយពេល ឬក៏ក្នុងមួយថ្ងៃ? មានករណីនេះដែរឬទេ?

ឆៈ ចំពោះអ្នកទោសដែលចូលមក ជាធម្មតាគឺបួនទៅដប់នាក់ ឬក៏ម្តែ ច្រើនបំផុតសាមសិបនាក់ ។ ប៉ុន្តែ រហូតដល់ចុងឆ្នាំ១៩៧៨ គឺទើបមានច្រើន គឺជួនណាមានជាងមួយរយ ប៉ុន្តែពេលវេលាតិចទេ ពេលអង្កាល់ហ្នឹង គឺចូលហ្នឹងគឺតិចទេ។ ហើយមកខាងភូមិភាគពាយ័ព្យ គឺជួនកាលមានមកដល់ហុកសិប ចិតសិប ប៉ែតសិបនាក់ដឹកឡានមក ប៉ុន្តែពេលវេលាវាតិចទេ ។ ប៉ុន្តែ ចូលជាប្រចាំ បើតាមខ្ញុំស្មានប្រហែលជាក្នុងខ្នង់ចាប់ពី មួយនាក់ រហូតដល់ម្តែនាក់ ប្រឡោះហ្នឹង។ នេះចូលជាប្រចាំ។

សៈ លោកដែលជួបប្រទះករណីបញ្ជូនចូលមកក្នុងមន្ទីរស-២១ ហ្នឹង អ្នកទោសច្រើនមានចំនួនច្រើននាក់ ដែលបញ្ជូនដោយសារមូលហេតុច្រើនហ្នឹង គេបញ្ជូនដោយសារខាងកងពិសេសហ្នឹងគេបើករថយន្តដែលដឹកអ្នកទោសហ្នឹងចូលទៅដល់នៅក្នុងមន្ទីរសន្តិសុខស-២១ ហ្នឹងតែម្តង មិនបានចាប់បញ្ជូន

ពីខាងក្រៅផ្ទេរផ្ទួរគ្នាពីខាងក្រៅហើយចាប់បណ្តើរចូលទេ ពីព្រោះករណីតិចបណ្តើរចូលទៅ ប៉ុន្តែករណីច្រើនមានករណីបញ្ជូនដឹកទាំងរថយន្តចូលទៅក្នុងដល់ក្បែរអគារតែម្តង គឺនៅក្នុងបរិវេណនៃមន្ទីរគុក ស-២១នោះ ។ តើមានករណីដូចដែលយើងនិយាយនេះដែរឬទេ?

ឆេ៖ គឺពិតជាមាន។

សៃ៖ សំណួរសួរថាប្រសិនបើមាន តើករណីដូចដែលយើងបាននិយាយអំមិញតើរបៀបរបបនៃការធ្វើបញ្ជីរបស់លោកប្រព្រឹត្តទៅយ៉ាងដូចម្តេច? ហើយការថតរូបរបស់អ្នកថតរូបទៅ ប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរ?

ឆេ៖ កាលដែលចុងក្រោយ ដែលមកច្រើនហ្នឹង គឺការធ្វើបញ្ជី គឺគេអត់មានដឹកចូលមកកន្លែងថតរូបទេ គេចាប់នៅក្នុងគុកហ្នឹងតែម្តង គឺចាប់ទាំងអស់តែម្តង ហើយខ្ញុំគ្រាន់តែធ្វើបញ្ជី កត់តែឈ្មោះតួនាទីហើយ ។ ឯចំពោះការថត គឺអត់ កន្លែងហ្នឹង កាលហ្នឹងអត់ទាន់ ដូចអត់មានទេ មានតែឈ្មោះចូលក្នុងបញ្ជី។

សៃ៖ បាទ, អញ្ជើញឆ្លើយបន្តទៀត ។

ឆេ៖ ប៉ុន្តែខ្ញុំសូមបញ្ជាក់ចំពោះការថត ក្រែងណោ ហ៊ិ គេចាត់តាំងឲ្យគេទៅថតខាងក្រៅក៏មិនដឹង ដល់ពេលចូលក្នុងបន្ទប់ ពីព្រោះពេលនោះវាជិតចុង៧៨ ហើយ ។

សៃ៖ អម្បាញ់មិញនេះយើងចង់និយាយករណីមនុស្សច្រើននាក់ ។ សួរថាតើការដែលលោកដកស្រង់នូវបញ្ជីប្រវត្តិរូបសង្ខេបរបស់អ្នកទោសហ្នឹង មកដល់ភ្លាម ចំណាត់ការរបស់លោកធ្វើភ្លាម ដកស្រង់នូវប្រវត្តិរូបទាំងអស់ ឬក៏ប្រវត្តិរូបរួចហើយ ទើបលោកប្រគល់ទៅឲ្យផ្នែកខាងកងការពារដើម្បីនាំអ្នកទោសយកទៅដាក់ឃុំឃាំងនៅក្នុងតាមបន្ទប់ឃុំឃាំងរួម ឬក៏ឃុំឃាំងដោយឡែក ឬក៏ករណីដូច្នេះគឺកងការពារហ្នឹងចាត់ចែងយកទៅដាក់នៅក្នុងបន្ទប់ឃុំឃាំងដាក់ខ្មោះអីរួចស្រួលបួល ទើបលោកចាប់ផ្តើមធ្វើបញ្ជីជាក្រោយ? ពីព្រោះថា លោកបានលើកឡើងហើយថា ផ្នែករបស់លោកគឺមានតែម្នាក់ឯងទេ ធ្វើការងារទូទៅតាំងពីដើមរហូតមកគឺមានតែម្នាក់ឯងទេ ។ តើករណីនេះចាត់ការយ៉ាងម៉េច? បញ្ជូលទៅក្នុងការឃុំឃាំងរួច បានដកស្រង់ធ្វើបញ្ជីជាក្រោយ ឬក៏ចាប់ផ្តើមធ្វើបញ្ជីភ្លាមៗហ្នឹងជាបន្ទាន់ហ្នឹងរួចបានប្រគល់ទៅឲ្យខាងកងការពារនាំអ្នកទោសហ្នឹងយកទៅដាក់ឃុំឃាំងតាមបន្ទប់ឃុំឃាំងនីមួយៗ?

ឆេ៖ ខ្ញុំសូមបញ្ជាក់អំពីដំណើរការអ្នកទោសដែលចូលមកហើយ គឺមកដល់កន្លែងខ្ញុំ គឺខ្ញុំធ្វើប្រវត្តិរូបហើយ ។ ចំពោះការយកចូលទៅដល់ក្នុងគុក គឺកងការពារគេម្ចាស់ការខ្លួនគេ គេជាអ្នកដាក់ចូលក្នុង

បន្ទប់ ។ ហើយពួកខ្ញុំដែលទៅធ្វើបញ្ជើក្នុងបន្ទប់នោះ មិនមែនធ្វើបញ្ជើទេ គ្រាន់តែសួរកងការពារតើអ្នកទោសនៅបន្ទប់ណាខ្លះ ដើម្បីខ្ញុំស្រង់លេខតែបន្ទប់ទេ លេខបន្ទប់តូច បន្ទប់ធំអគារហ្នឹងដើម្បីបញ្ចូលក្នុងបញ្ជីវិញទេ។

សៈ អ៊ីចឹងបានន័យថា ការបញ្ជូនមកដល់ច្រើននាក់ក៏ដោយ ក៏យើងរបៀបរបបធ្វើការងារគឺគោរពតាមគោលការណ៍រួម គឺធ្វើការដកស្រង់នូវជីវប្រវត្តិ ឬក៏សង្ខេបរបស់អ្នកទោសទាំងអស់នោះរួចហើយ ទើបប្រគល់ឱ្យខាងកងការពារនាំយកទៅដាក់តាមបន្ទប់ឃុំឃាំង ។ ហើយរួចក៏ធ្វើតាមគោលការណ៍រួម គឺទៅកំណត់ថា កត់សម្គាល់ថា តើអ្នកទោសណានៅមន្ទីរឃុំឃាំងនៅកន្លែងបន្ទប់ឃុំឃាំងណា ដើម្បីដាក់មកចូលបញ្ជីហើយរាយការណ៍ទៅថ្នាក់លើដូចករណីទូទៅដែរ? អ៊ីចឹងមែនទេ? ព្រោះអំមិញយើងសួរករណីដោយឡែក ដែលមានមនុស្សច្រើនបញ្ជូនមកទេ? លោកយល់សំណួរទេ?

[១៥:១៥:០៧]

ឆេ បាទ, យល់ ។ ចំពោះដែលអ្នកទោស ជាគោលការណ៍ គឺត្រូវចូលមក គឺកត់ប្រវត្តិសង្ខេបហើយ បានកងការពារហ្នឹង យកទៅដាក់ដោយខ្លួនឯង យកចូលទៅបន្ទប់ខ្លួនឯង ពីព្រោះគេមានកម្លាំងរៀបចំ ហើយចំពោះខ្ញុំ ដែលទៅលើកក្រោយនេះ គឺមិនមែនទៅសួរអីទេ គ្រាន់តែសួរកងការពារ តើអ្នកដែលដាក់ថ្មីហ្នឹងនៅកន្លែងណា ដើម្បីខ្ញុំយកស្រង់យកថា លេខបន្ទប់តូច បន្ទប់ធំ និងអគារ យកមក មិនមែនមានយកទៅរាយការណ៍ទៅខាងលើទេ យកមកដើម្បីទុកមកកន្លែងខ្ញុំ ដើម្បីស្រណុកសម្រួលដល់ពេលគេយកអ្នកទោសទៅសួរ គេមកសួរខ្ញុំ ដើម្បីដឹងអ្នកទោសនេះ នៅបន្ទប់តូចប៉ុន្មាន បន្ទប់ធំប៉ុន្មានអគារណា តើប៉ុណ្ណឹងទេ ។

សៈ នៅបន្ទប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខស-២១ ទាំងបន្ទប់ឃុំឃាំងធំ ទាំងបន្ទប់ឃុំឃាំងតូច មានដាក់លេខសម្គាល់ ឬក៏មានសញ្ញាសម្គាល់អីទេ នៅក្នុងបន្ទប់ឃុំឃាំងតូចៗហ្នឹង អាចថាបន្ទប់លេខប៉ុន្មានៗអីអ៊ីចឹងទេ មានលេខកូដ ឬក៏លេខសម្គាល់បន្ទប់តូច ។ បើអត់មានលេខសម្គាល់បន្ទប់តើយើងគ្រប់គ្រងយ៉ាងម៉េច?

ឆេ នៅក្នុងបន្ទប់ឃុំឃាំងគឺសុទ្ធតែមានលេខសម្គាល់ទាំងអស់ ។ បន្ទប់តូចក៏មានលេខសម្គាល់ បន្ទប់ធំក៏មានលេខសម្គាល់ អគារក៏មានលេខសម្គាល់។ ប៉ុន្តែខ្ញុំសូមបញ្ជាក់ចំពោះលេខសម្គាល់ទាំងអស់នេះ គឺគេសម្រាប់តែ ខ្ញុំប្រើនៅក្នុងនេះ ដើម្បីងាយស្រួលដល់កងសួរចម្លើយ យកអ្នកទោសយកទៅធ្វើការទេ តែការរាយការណ៍ទៅលើ គឺអត់មានរៀលេខបន្ទប់ទេ ។

សៈ តាមលេខកត់សម្គាល់នៅពេលដែលបញ្ជូនអ្នកទោសមកដល់ក្នុងហ្នឹង គឺលោកបាននិយាយហើយ គឺជាកងពិសេស ។ ចុះកងការពារដែលលោកនិយាយហ្នឹង ការពារបានទទួលក្រោយពីថតរូប ឬក៏មិនថតរូប ក្រោយពេលពីធ្វើដើរដកស្រង់នៅប្រវត្តិរូបសង្ខេបរូប កងការពារជាអ្នកនាំអ្នកទោសយកទៅដាក់ឃុំឃាំង ឬក៏ដាក់គុក តាមបន្ទប់ធំ បន្ទប់រួម ឬក៏បន្ទប់ឃុំឃាំង ដោយឡែកៗហ្នឹង ដោយកងពិសេស ឬកងការពារខាងក្នុង?

[១៥:១៧:៤៩]

ឆៈ ចំពោះអ្នកទោសដែលកងការពារ ហៅថា កងពិសេសដែលយកចូល គឺគេយកចូលរហូតមកដល់ខាងក្នុង។ ប៉ុន្តែដល់ខាងក្នុងបាន ទើបកងការពារខាងក្នុងគេទទួលយកទៅតាមអគារ ខាងក្នុងគេទទួលយកទៅដាក់បន្ទប់នីមួយៗ ។

សៈ ចុះលោកជាអ្នកនៅទីនោះផ្ទាល់ ហើយលោកបានធ្វើការញឹកញាប់ លោកកត់សម្គាល់ឃើញថាតើអ្នកទោសដែលគេ កងការពារទទួលពីកងពិសេស ក្រោយពីថតរូប ឬក៏ក្រោយពីដកស្រង់នូវប្រវត្តិរូបសង្ខេបរួចបញ្ជូនទៅដាក់ឃុំឃាំងតាមអគារឃុំឃាំងរួម ឬក៏បន្ទប់ឃុំឃាំងដោយឡែក ដែលលោកបាននិយាយអម្បាញ់មិញនេះ តើនៅសម្លៀកបំពាក់ធម្មតា ឬក៏គេមានការដោះនៅសម្លៀកបំពាក់ចេញ?

ឆៈ ខ្ញុំសូមបញ្ជាក់សំណួរមុនបន្តិច ពីព្រោះមិនទាន់ច្បាស់លាស់ ។ សំណួរដែលថា កងការពារ កងពិសេសដែលយកចូលទៅ គឺគេយកចូលទៅដល់ខាងក្នុងបន្ទប់ដែលកងការពារខាងក្នុងគេប្រាប់បន្ទប់ណា ដែលនៅសល់ៗ គឺគេរៀបចំដល់កន្លែងហ្នឹងតែម្តង ។ ចំពោះសំណួរទីពីរ សូម ខ្ញុំភ្លេច សូមបញ្ជាក់ម្តងទៀត ។

សៈ អ៊ីចឹងភារកិច្ចរបស់កងពិសេសហ្នឹង គឺបញ្ជូនពីក្រៅចូលមកក្នុង មកធ្វើការឱ្យលោកជួយមើលការខុសត្រូវ ឱ្យលោកធ្វើការដកស្រង់នូវប្រវត្តិរូបសង្ខេបគ្រប់អ្នកទោសរួចហើយ ហើយបញ្ជូនទៅធ្វើការថតរូប ថតរូបរួចហើយកងពិសេសហ្នឹង គឺនៅមានភារកិច្ចបញ្ជូនបន្តផ្ទាល់រហូតទៅដល់អគារទៅដល់បន្ទប់ឃុំឃាំងរួម ឬក៏ឃុំឃាំងដោយឡែក ។ រួចហើយទើបប្រគល់ឱ្យទៅកងការពារនៅទីនោះសម្រាប់ចាត់ចែង នេះដែលលោកចង់និយាយអ៊ីចឹងមែនទេ?

ឆៈ បាទ, ប្រាកដមែនហើយ ។

សៈ សំណួរបន្ទាប់អំមិញ គឺថាតើលោកកត់សម្គាល់យ៉ាងម៉េចចំពោះអ្នកទោសនៅពេលដែលចាប់មកដល់ ហើយនាំយកទៅឃុំឃាំង តើសម្លៀកបំពាក់គេ ចំពោះអ្នកទោសទាំងអស់នោះ គេនៅតែ

ស្លៀកពាក់សម្លៀកបំពាក់ដូចដដែលអ៊ីចឹងពេលនាំទៅដល់ឃុំឃាំង ឬមួយក៏មានការដោះសម្លៀកបំពាក់វែងចេញ ទុកតែខោខ្លីទេ មុននឹងនាំយកទៅដាក់នៅក្នុង យកទៅខ្នោះនៅក្នុងបន្ទប់ឃុំឃាំងនីមួយៗនោះ?

អ៊ុំ៖ ចំពោះអ្នកទោសដែលមកដល់កន្លែងខ្ញុំ គឺខ្ញុំសូមបញ្ជាក់ គឺវាមិនទៀង ជួនកាលគេដោះខោវែងចេញអស់ នៅសល់តែខោខ្លីក៏មាន ជួនកាលខ្លះក៏មាននៅខោវែង ។ អានេះខ្ញុំចាំ វាមិនច្បាស់ ប៉ុន្តែបើតាមខ្ញុំគិត គឺមានពីរផ្នែកហ្នឹង ។

[១៥:២១:២៣]

សៈ អរគុណ ។ ឥឡូវនិយាយដល់ដំណាក់កាលមួយទៀត គឺដំណាក់នៃការសួរចម្លើយ។ តើកិច្ចការរបស់លោក ឬភារកិច្ចរបស់លោកហ្នឹង មានការពាក់ព័ន្ធជាមួយនឹងផ្នែកខាងសួរចម្លើយ ឬក៏ក្រុមសួរចម្លើយយ៉ាងម៉េចដែរ អំពីការបញ្ជូនបញ្ចេញអ្នកទោសទៅសួរចម្លើយ ហើយនិងការបញ្ជូនត្រឡប់មកវិញ ក្រោយពីសួរចម្លើយចប់?

អ៊ុំ៖ ចំពោះការងារខ្ញុំ ដែលពាក់ព័ន្ធជាមួយកងសួរចម្លើយ គឺខ្ញុំគ្រាន់តែបើក កងសួរចម្លើយមកយកឈ្មោះអ្វីមួយ គឺគេឲ្យតែឈ្មោះទេ ហើយនិងតួនាទីខ្ញុំដឹងពីឈ្មោះ ហើយនិងក្រសួង គេដាក់តែពីរមុខគឺខ្ញុំដឹង ហើយខ្ញុំស្រង់ទៅតាមហ្នឹងហើយ ខ្ញុំប្រគល់ឲ្យគេទៅ ចុះតែលេខបន្ទប់ លេខតូច លេខធំទាំងអស់ហើយ គេក៏ទៅយកខ្លួនគេទៅសួរចម្លើយ គឺគេម្ចាស់ការខ្លួនគេ គេទៅយកខ្លួនគេ ហើយគេមកវិញ គឺអត់មានចូលកន្លែងខ្ញុំទេ គឺគេចេញទៅតាមម្ចាស់ការខ្លួនគេ ។

សៈ អ៊ីចឹងគេយកមកបង្ហាញលោក ហើយថាបើគេត្រូវការ យកអ្នកទោសដែលនៅបន្ទប់លេខប៉ុន្មាន ឈ្មោះអីហ្នឹង ទៅសួរចម្លើយ ។ តើការបង្ហាញនេះ គឺមានជាលាយលក្ខណ៍អក្សរ ហើយអ្នកណាជាអ្នកមានសិទ្ធិនៅក្នុងការចារ ដើម្បីឲ្យអ្នកសួរចម្លើយហ្នឹងមានលទ្ធភាពក្នុងការមកទទួលយកអ្នកសួរចម្លើយទៅសួរ តើមានលាយលក្ខណ៍អក្សរ? ពីណាជាអ្នកចាត់ចែងក្នុងការដែលបង្គាប់បញ្ជាមកលោក ឲ្យបញ្ចេញអ្នកទោសទៅឲ្យអ្នកសួរចម្លើយនាំទៅសួរដូច្នេះ?

អ៊ុំ៖ គឺឈ្មោះដែលអ្នកសួរចម្លើយយកមក គឺគេសរសេរតែកូនក្រដាសតូច គឺអត់មានចារពីណាឲ្យមកសួរ ឲ្យមកយកទេ គឺគ្រាន់តែដាក់ឈ្មោះ ហើយនិងតួនាទីតែប៉ុណ្ណឹង ហើយសរសេរកូនក្រដាស់តូចឲ្យមកខ្ញុំតែប៉ុណ្ណឹង គឺទៅយកអ្នកទោសហើយ ។

សៈ សាជាថ្មីម្តងទៀត លោកបានឆ្លើយអំមិញហើយ ប៉ុន្តែវាចង់ច្បាស់លាស់ថា បញ្ជីដែលលោកបានធ្វើ ការបញ្ជូលអ្នកទោសមកដល់មន្ទីរស-២១ ហើយលោកធ្វើរាយការណ៍ តើរាយការណ៍ទៅឲ្យ

1 អ្នកណាគេ? ហើយអ្នកនោះមានមុខងារធ្វើអ្វី?

2 **ឆេ៖** ការធ្វើបញ្ជីអ្នកទោសចូលធ្វើជាប្រចាំថ្ងៃក្នុងការរាយការណ៍ គឺខ្ញុំរាយការណ៍ជាប្រចាំថ្ងៃ
3 គឺតែពេលម៉ោងប្រាំពីរព្រឹក គឺខ្ញុំត្រូវធ្វើឲ្យហើយ ។ ហើយពេលធ្វើចំនួនអ្នកទោស បញ្ជីអ្នកទោសដែល
4 ចូលបានសព្វគ្រប់ហើយ គឺខ្ញុំយកបញ្ជីនោះយកទៅឲ្យហ៊ា ជាអ្នកស៊ីញ្ញេ។ ហ៊ា ស៊ីញ្ញេរួចហើយ បានខ្ញុំយក
5 បញ្ជីនោះយកទៅប្រគល់ឲ្យខាងមន្ទីរកងការពារដែលមានឈ្មោះ ម៉ែង ជាអ្នកធ្វើបញ្ជីនៅកងសួរចម្លើយ
6 គេថាកង ២១(ក)ហ្នឹង ។

7 [១៥:២៥:១០]

8 **សៈ** នៅក្នុងអំឡុងពេលនៃដំណើរការគ្រប់គ្រងអ្នកទោសនៅក្នុងមន្ទីរស-២១ តើមានករណីផ្លាស់
9 ប្តូរបន្ទប់ឃុំខ្លួន ឃុំឃាំងដែរឬទេ? ឧទាហរណ៍ពីការឃុំឃាំងនៅបន្ទប់ធំ ក្រោយមកនៅបន្ទប់តូចឬក៏
10 ឃុំឃាំងនៅបន្ទប់តូច ហើយក្រោយពេលសួរចម្លើយរួចដាក់ទៅឃុំឃាំងនៅបន្ទប់ធំ តើមានករណីផ្លាស់
11 ប្តូរបន្ទប់ឃុំឃាំង ដូចដែលយើងបាននិយាយនេះដែរឬទេ?

12 **ឆេ៖** ការផ្លាស់ប្តូរអ្នកទោសគឺមានជាប្រចាំ ទៅតាមកងសួរចម្លើយគេរាយការណ៍ តែពេលឃប់
13 អ្នកទោសសួរចម្លើយយកទៅសួរ បើសិនអ្នកទោសនោះនៅបន្ទប់ធំ គឺពេលយកមកវិញ គឺគេត្រូវរក
14 បន្ទប់តូចដាក់វិញហើយ ដើម្បីកុំឲ្យសួរគ្នា ។ ហើយការដូរដេញនេះ គឺខ្ញុំមិនបានទៅមើលទេ គឺកង
15 ការពារហ្នឹង គេរាយការណ៍មក ហ៊ឹៗ គេប្រាប់ខ្ញុំថា ឈ្មោះនែ៎ប្តូរមកបន្ទប់នេះវិញហើយ ដូច្នេះខ្ញុំក៏ធ្វើ
16 បញ្ជីដូរទៅតាមហ្នឹងទៅ ពីបន្ទប់ធំ មកបន្ទប់តូចវិញ ។

17 **សៈ** ចុះលោកដែលបានជួបនៅហេតុការណ៍នៃអ្នកទោសនៅក្នុងអំឡុងពេលឃុំឃាំង ហើយគាត់
18 បានទទួលមរណភាព ឬក៏ស្លាប់ តើលោកដែលបានជួបករណីនេះដែរឬទេ?

19 **ឆេ៖** ចំពោះអ្នកទោសដែលស្លាប់នៅក្នុងមន្ទីរឃុំឃាំង គឺខ្ញុំមិនបានជួបផ្ទាល់ទេ គឺខ្ញុំធ្វើទៅតាម
20 សេចក្តីរាយការណ៍របស់ពេទ្យ ព្រោះក្នុងអគារនីមួយៗ ក្នុងមួយអគារមានពេទ្យប្រចាំមួយ ។ ដូច្នេះ អ្នក
21 ឈឺ ក៏ពេទ្យរាយការណ៍ឲ្យមក ហ៊ឹ គេធ្វើសេចក្តីរាយការណ៍អ្នកឈឺហ្នឹង ឈឺអំពីអ្វី ស្ទឹអីៗហ្នឹង អ្នក
22 ឈឺក៏រាយការណ៍ អ្នកស្លាប់ក៏រាយការណ៍ស្លាប់ ។ ដូច្នេះ ខ្ញុំត្រូវយកតែបញ្ជីដែលពេទ្យរាយការណ៍ឲ្យ ហ៊ឹ
23 ហ្នឹង យកមកស្រង់ចូលក្នុងបញ្ជីប្រចាំថ្ងៃ ដើម្បីរាយការណ៍ទៅខាងលើដែរ ។

24 **សៈ** អ៊ីចឹង អ្នកដែលស្លាប់ដោយជំងឺ ឬក៏ដោយខ្វះអាហារស្លាប់នោះ គឺក៏លោកធ្វើបញ្ជីដែល
25 បាននិយាយថា ដកលោកចេញពីបញ្ជីអ្នកទោស ដោយតាមរបាយការណ៍ លោកមិនបានទៅពិនិត្យផ្ទាល់ទេ

ព្រោះមុខងារហ្នឹងមុខងាររបស់ខាងមន្ទីរពេទ្យ ហើយអ្នកដែលធ្វើរបាយការណ៍ គឺកងការពាររាយការណ៍ទៅហ៊ឺៗ ប្រាប់មកលោក ពីបញ្ហាអ្នកទោសស្លាប់ ។ អ៊ីចឹងមែនទេ?

អ៊ុង៖ បាទ, ប្រាកដពិតមែនហើយ ។ លោកបានដឹង ឬក៏កើតមានទេ អំពីហេតុការណ៍នៅមន្ទីរ ស-២១ នៅព្រឹត្តិហេតុនៃការដំណើរការបូមឈាមពីអ្នកទោសយកទៅប្រើប្រាស់នៅមន្ទីរពេទ្យតាមតម្រូវការនៃមន្ទីរពេទ្យ តើលោកបានដឹង បានឮអំពីហេតុការណ៍នៃការបូមឈាមអ្នកទោសដែរឬទេ?

អ៊ុង៖ ហេតុការណ៍នៃអ្នកទោសដែលបានបូមឈាម គឺខ្ញុំមិនបានឃើញផ្ទាល់ទេ ប៉ុន្តែខ្ញុំដឹងដោយសារតែ ហ៊ឺ គឺឲ្យខ្ញុំចុះបញ្ជីអ្នកបូមឈាមហ្នឹងចូលទៅក្នុងឈ្មោះកម្ទេច ។

សៈ ហ៊ឺ បញ្ហាលោកថាម៉េច បានជាលោកបានដឹងពីបញ្ហាថា លោកបញ្ជីឲ្យធ្វើបញ្ជីអ្នកទោសដែលបានបូមឈាមហ្នឹង ហើយបញ្ចូលទៅបញ្ជីកម្ទេច ដំណើរការហ្នឹង វាវិវឌ្ឍន៍យ៉ាងម៉េចទៅ ដែលហ៊ឺនិយាយប្រាប់លោក ហើយដំណើរការពីដើមរហូតដល់ចប់ វាប្រព្រឹត្តទៅ វិវឌ្ឍន៍ទៅយ៉ាងដូចម្តេច?

[១៥:៣០:១២]

អ៊ុង៖ ការទាក់ទងនឹងការបូមឈាមនេះ គឺពេទ្យគេស្នើយោបល់ទៅ ហ៊ឺ ហើយ ហ៊ឺ គឺស្នើយោបល់ទៅ ឌុច ពីព្រោះការដកចេញមនុស្ស គឺទាល់តែសម្រេចពី ឌុច ទើបអាចប៉ានធ្វើបាន ។ ដូច្នេះ ការបូមឈាមនេះ គឺខ្ញុំមិនបានដឹងច្បាស់ប្រាកដទេ គឺពេលដែលបូមឈាមហើយ គឺអ្នកនោះច្បាស់តែស្លាប់ហើយ។ ដូច្នេះ ក្នុងការយកចេញទៅ គឺគ្រាន់តែ ហ៊ឺ ទទួលរបាយការណ៍ពីពេទ្យដែលគេដាក់យកឈ្មោះនេះ ដែលគេសំណូមពរពី ហ៊ឺ ហ្នឹង ឈ្មោះនេះ នៅអង្គភាពនេះ ហើយឲ្យខ្ញុំយកអាបញ្ជីហ្នឹងពិនិត្យមើលឈ្មោះហ្នឹងៗកត់ចូលក្នុងបញ្ជីកម្ទេចទៅ គឺមានតែប៉ុណ្ណឹង ។

សៈ ហ៊ឺ ប្រាប់លោកឲ្យលោកធ្វើបញ្ជីមុនទេ? បញ្ជីអ្នកដែលត្រូវបូមឈាមហ្នឹង ធ្វើបញ្ជីមុនថា ឧទាហរណ៍ដូចជា ឈ្មោះ “ក” “ខ” “គ” “ឃ” “ង” អ៊ីចឹងទៅត្រូវយកទៅបូមឈាម ហើយការបូមឈាមនេះគឺបូមឲ្យអស់ បាននិយាយថា ចូលទៅបញ្ជីកម្ទេច ពីព្រោះបូមឈាមហ្នឹងមិនបូមធម្មតាទេ គឺបូមរហូតដល់សោះឈាមចេញពីខ្លួនអស់ រហូតមនុស្សហ្នឹងដង្ហើមផ្ទឹកៗ ហើយដាច់ខ្យល់ស្លាប់តែម្តង ។ ប៉ុន្តែ យើងចង់សួរបៀបធ្វើបញ្ជីទេ ធ្វើបញ្ជីថាតើរបៀបដែលលោកធ្វើបញ្ជីហ្នឹង តើគេរៀបចំឲ្យលោកធ្វើបញ្ជីដូចយើងបាននិយាយអ៊ីចឹង កំណត់អំពីបញ្ជីឈ្មោះត្រូវជ្រើសរើសអ្នកទោសយកទៅធ្វើការបូមឈាម ហើយសម្រេចថា អ្នកទោសដែលថាសម្រេចបូមឈាមហ្នឹង បញ្ចូលទៅក្នុងបញ្ជីកម្ទេច ឬក៏គេបានសម្រេចថា មនុស្សទាំងអស់ហ្នឹង គេនឹងយកទៅបូមឈាមហើយ បូមឈាមហ្នឹង គឺបញ្ចូលបញ្ជី

កម្ទេច ដោយសាររបៀបនៃការបូមឈាមនឹងមុខតែអ្នកទោសហ្នឹងស្លាប់ហើយ? អ៊ីចឹងសម្រេចថា ឲ្យតែមនុស្សបញ្ជូនទៅធ្វើការបូមឈាម គឺបញ្ចូលក្នុងបញ្ជីកម្ទេច ។ អ៊ីចឹងអាចខុសគ្នាបន្តិច រវាងរបៀបធ្វើយើងចង់ដឹងអំពីរបៀបធ្វើនៃការជម្រះចេញពីបញ្ជី បើនិយាយរួមគឺធ្វើការគ្រប់គ្រងបញ្ជីចូល ហើយនិងចេញនេះទេ ពីព្រោះនេះជាមុខងាររបស់លោក ។ តើច្បាស់លាស់ តើលោកធ្វើយ៉ាងម៉េច តាមបញ្ជារបស់ ហ៊ិ ហ្នឹង តើធ្វើយ៉ាងម៉េចក្នុងការទាក់ទិនជាមួយនឹងអ្នកទោសដែលត្រូវបូមឈាមនេះ?

អៀ៖ ចំពោះអ្នកទោសដែលបូមឈាមនេះ គឺគេបូមថ្ងៃណា ដល់ពេលស្អែកឡើងគេរាយការណ៍ឲ្យទៅ ហ៊ិ គឺពេទ្យរាយការណ៍ឲ្យ តាហ៊ិ ទៅ គឺខ្ញុំចុះធ្វើក្នុងថ្ងៃហ្នឹង ។

[១៥:៣៣:០១]

សៃ៖ ចុះៗថាម៉េច? លោកចុះក្នុងបញ្ជីថាម៉េច?

លោកៗកុំអាល ចាំទៀត ចាំមានភ្លើងក្រហមនៅក្បាលមីក្រូ សឹមលោកចាប់ផ្តើមនិយាយ នេះទើបអាចធ្វើការកត់ប្រតិចារឹកបានផង ហើយមានការបកប្រែភាសាផង ។ ម្តងទៀត សូមឆ្លើយម្តងទៀត ។

អៀ៖ ចុះបញ្ជីកម្ទេចហ្នឹង គឺខ្ញុំសូមបញ្ជាក់ថានៅពេលណា គេបានបូមឈាមថ្ងៃហ្នឹងហើយ ហ្នឹងពេទ្យគេរាយការណ៍មក ថ្ងៃស្អែកព្រឹកព្រលឹមគេឲ្យមករាយការណ៍ហើយ គេរាយការណ៍ឲ្យ ហ៊ិ ហើយ។ ហ៊ិ យកអាក្រដាសដែលឈ្មោះអ្នកដែលបូមឈាមហ្នឹង គឺយកមកខ្ញុំដាក់ឈ្មោះកម្ទេច។ ប៉ុន្តែ សូមបញ្ជាក់គឺខ្ញុំវាមិនបានដឹងច្បាស់ តើក្នុងបញ្ជីនោះដាក់កម្ទេចហ្នឹង ដោយសារបូមឈាមឬយ៉ាងណា? ពីព្រោះខ្ញុំភ្លេចទៅហើយ ។

សៃ៖ តាមលោកនៅចងចាំ តើករណីយកអ្នកទោសទៅបូមឈាម ហើយបញ្ចូលទៅក្នុងបញ្ជីកម្ទេចហ្នឹង តាំងពីដើមរហូតដល់ចប់អ្នកទោសប្រភេទកម្ទេចដោយវិធីបូមឈាមៗយកឈាមចេញសោះខ្លួនហ្នឹង មានចំនួនប្រហែលជាប៉ុន្មានទៅតាមគិតមើល? គ្រាន់តែចំនួនប្រហែល ប្រហាក់ប្រហែលទៅបានហើយ យើងមិនចង់បានជាក់លាក់ទេ ។

អៀ៖ ខ្ញុំស្មាន គឺមិនបានច្បាស់ ប៉ុន្តែខ្ញុំវែសន្និដ្ឋាន គឺមានប្រហែលជាពីរដង ។ ពីរដងហ្នឹង គឺលើកទីមួយ គឺពីរ ឬបីនាក់ទេ ។ លើកក្រោយ គឺប្រហែលជាង ដប់នាក់ គឺសរុបទៅចន្លោះពីដប់ ទៅម្ភៃនាក់ ខ្ញុំឆ្លើយនេះ ការសន្និដ្ឋានរបស់ខ្ញុំទេ ។

សៈ ហើយលោកដឹងថា កាលគេនាំអ្នកទោសទៅបូមឈាម គេយកទៅបូមនៅកន្លែងណា? ឬក៏គេបូមនៅកន្លែងឃុំខ្លួន នៅក្នុងអគារ ឬក៏បន្តប់ឃុំខ្លួនអ្នកទោសម្នាក់ៗហ្នឹង ឬក៏គេនាំយកទៅបូមនៅកន្លែងណា?

ឆៈ ការបូមឈាមអ្នកទោសហ្នឹង គឺមិនធ្វើនៅកន្លែងក្នុងគុកទេ គឺពេទ្យគេម្ចាស់ការយកចេញទៅខាងក្រៅ ហើយទៅខាងក្រៅគឺខ្ញុំមិនបានជាទៅតាមដានទៅដឹងទេ ពីព្រោះនេះជាភារកិច្ចខ្ញុំវាអត់មាន។

សៈ ការដែលគេ ពួកពេទ្យនាំមកបញ្ចេញអ្នកទោសពីកន្លែងបន្តប់ឃុំឃាំងនាំយកទៅបូមឈាម អត់មានការពាក់ព័ន្ធជាមួយលោកទេ? ម៉េចគេដឹងថាអ្នកទោសមួយណានៅបន្តប់កន្លែងណា ឬក៏បន្តប់មួយណាបើលោកគ្រប់គ្រងអ្នកទោសទាំងអស់ហ្នឹង ថាអ្នកទាំងអស់ហ្នឹងនៅបន្តប់តាមលេខកូដ ឬក៏លេខរៀងដែលលោកបាននិយាយអំមិញ? តើមន្ទីរពេទ្យ ពួកបុគ្គលិកពេទ្យដែលនាំអ្នកទោសចេញ គេធ្វើយ៉ាងម៉េច? អត់ពាក់ព័ន្ធជាមួយលោកសោះ ឬក៏គេធ្វើការសួរនាំលោកដែរ ដើម្បីបានព័ត៌មានស្តីពីថាមនុស្សទាំងអស់ហ្នឹងនៅកន្លែងណាខ្លះ?

[១៥:៣៦:៤០]

ឆៈ ចំពោះអ្នកទោសដែលពេទ្យយកទៅបូមឈាមហ្នឹង គឺគេស្នើសុំទៅខាងពេទ្យនិង ហ៊ិ ហើយ ហ៊ិ ស្នើទៅខាង ឌុច ។ ប៉ុន្តែ ចំពោះពេលដែលពេទ្យយកអ្នកទោសចេញ គេត្រូវតែមកសួរខ្ញុំ ដើម្បីឲ្យដឹងអ្នកទោសនៅបន្តប់ណាៗ អានេះជាភារកិច្ចរបស់ខ្ញុំ ។

សៈ តាមលោកដឹង លោកមានការពាក់ព័ន្ធ យល់ដឹងអំពីដោយសារភារកិច្ចរបស់លោកហ្នឹង គឺទៅលើការសួរចម្លើយ ហើយនិងមនុស្សដែលបញ្ជូនចូលទៅឃុំឃាំង ។ សំណួរសួរថា តាមលោកចង ចាំតើមនុស្សទាំងអស់ អ្នកទោសទាំងអស់ដែលបញ្ជូនទៅឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ ហ្នឹង សុទ្ធតែត្រូវបានសួរចម្លើយទាំងអស់ ឬក៏មានករណីខ្លះគឺមិនបានសួរចម្លើយទេ?

ឆៈ ការណ៍នេះ គឺខ្ញុំសូមបញ្ជាក់ គឺខ្ញុំមិនសូវដឹងអស់ទេ គឺមិនដឹងជាបានសួរទាំងអស់ ឬក៏សួរគឺគ្រាន់តែមានសល់ ឬក៏សួរទាំងអស់ ។

សៈ ឥឡូវនិយាយពីបញ្ជើបញ្ចេញអ្នកទោសវិញ តើការរៀបចំបញ្ជើក្នុងការបញ្ចេញអ្នកទោសពីក្នុងគុកប្រព្រឹត្តទៅយ៉ាងដូចម្តេច?

ឆៈ ចំពោះបញ្ជើបញ្ចេញអ្នកទោស គឺក្រោយពី ហ៊ិ ទទួលបានបញ្ជើពី ឌុច ដែល ឌុច ចារមក ហើយ គឺ ហ៊ិ ប្រគល់ឲ្យខ្ញុំស្រង់បញ្ជើជាថ្មី ដើម្បីខ្ញុំស្រង់ឲ្យដឹងអ្នកទោសណាដែលនៅ អ្នកទោសណា

ដែលគេយកទៅកម្ទេច ។ ស្រង់ឲ្យដឹងចំនួន អ្នកដែលយកកម្ទេចហើយ ខ្ញុំត្រូវចុះនៅក្នុងបញ្ជីហ្នឹង គឺដាក់លេខបន្ទប់តូច ឬធំ អគារ ដើម្បីងាយស្រួលដល់កងការពារយកចេញទៅតាមហ្នឹង ។ ហើយរួចពីខ្ញុំចុះបញ្ជី គឺថាលេខផ្ទះលេខអស់ហើយ គឺបញ្ជីនោះខ្ញុំត្រូវប្រគល់ឲ្យទៅ ហ៊ិ វិញ ដើម្បី ហ៊ិ គេចាត់តាំងកម្លាំងយកចេញមកក្រៅ ។ មកក្រៅហ្នឹង គឺមកមុនដំបូងគឺអត់ទាន់យកចេញទៅក្រៅភ្លាមទេ គឺយកមកនៅត្រឹមមាត់ទ្វារ។ ដល់មាត់ទ្វារហើយ គឺខ្ញុំមានភារកិច្ច គឺយកបញ្ជីហ្នឹងពិនិត្យឈ្មោះមួយសារទៀត ។ តើទៅតាមត្រូវឈ្មោះ ពិតប្រាកដទៅតាមតួនាទីទេ? ពីព្រោះ ហ៊ិ បានបញ្ជាក់ហើយ បើ ធី ឯងច្រឡំអ្នកទោសម្នាក់ គឺ ធី ឯងទទួលខុសត្រូវហើយ ទទួលជំនួសហើយ ។ ដូច្នេះ ការដកចេញនេះ ខ្ញុំធ្វើការដោយប្រយ័ត្នបំផុត គឺខ្លាច។ណាស់ គឺខ្ញុំសួរទាល់តែពិតប្រាកដ ទាំងចំនួន ទាំងតួនាទី ទាំងឈ្មោះ ពិតប្រាកដបានទើបខ្ញុំប្រគល់បញ្ជីនេះទៅឲ្យ ហ៊ិ វិញ ។ ភារកិច្ចរបស់ខ្ញុំ គឺចប់ត្រឹមតែប៉ុណ្ណឹង ។

[១៥:៤០:៥០]

សៈ ពេលលោកនិយាយអំមិញថា ពេលដែលដកអ្នកទោសចេញទៅកម្ទេច គឺមានការធ្វើបញ្ជីសាឡើងវិញដែលមានចំណាររបស់ ឌុច បញ្ជូនមក ហ៊ិ។ បញ្ជូនមកឲ្យលោក ហើយបន្ទាប់ពីធ្វើបញ្ជីសាជាថ្មីបញ្ជូនទៅឲ្យ ហ៊ិ ដើម្បី ហ៊ិ ចាត់តាំងកម្លាំងដើម្បីនាំអ្នកទោសទៅកម្ទេច ។ ដើម្បីច្បាស់លាស់លោកមានភារកិច្ចទៅផ្ទៀងផ្ទាត់នូវអ្នកទោសសាជាថ្មីម្តងទៀតមុននឹងបញ្ចេញទៅកម្ទេច គឺទៅផ្ទៀងផ្ទាត់នៅមាត់ទ្វារ ។ លោកនិយាយពាក្យ “មាត់ទ្វារ” ហ្នឹង មាត់ទ្វារនៃបន្ទប់ឃុំឃាំង ឬក៏មាត់ទ្វារនៃគុក? បាននិយាយថា បញ្ចេញមកផ្លូវ មកអាខាង-- បច្ចុប្បន្នអាកន្លែងច្រកចេញចូលហ្នឹង ចេញចូលនៅក្នុងមន្ទីរ ស-២១ ឬក៏មាត់ទ្វារនៃបន្ទប់ឃុំឃាំងរួម ឬក៏បន្ទប់ឃុំឃាំងដោយឡែក?

ឆៃ គឺនៅច្រកមាត់ទ្វារចេញចូល មិនមែននៅច្រកមាត់ទ្វារបន្ទប់ឃុំឃាំង គឺមាត់ទ្វារចូលទៅក្នុងគុកនុ៎ង ។

សៈ ការធ្វើដូច្នេះ គ្រប់ករណីទាំងអស់? ករណីនាំទៅកម្ទេចវាយ មានលក្ខណៈវាយ បាននិយាយថាមានចំនួនតិច ឬក៏មានទាំងលក្ខណៈជាឈុត បាននិយាយថា ការនាំទៅកម្ទេចហ្នឹងមានទ្រង់ទ្រាយធំមានគ្នាច្រើននាក់ ។ បាននិយាយថា នាំម្តងមួយជើងហ្នឹង មួយរយ ឬក៏ពីររយនាក់អ៊ីចឹងទៅ ។ តើធ្វើដូចគ្នាទាំងអស់ឬក៏មានលក្ខណៈខុសគ្នាដែរក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ឡើងវិញនៅមាត់ទ្វារចេញចូលគុនោះ?

ឆៃ ទោះបីចំនួនអ្នកទោសមានចំនួនតិចក៏ត្រូវតែពិនិត្យនៅមាត់ទ្វារហ្នឹងដែរ ។ មុននឹងចេញទៅពីព្រោះខ្ញុំអត់មានពេលទៅពិនិត្យនៅក្នុងគុកទេ គឺមកដល់កន្លែងហ្នឹង កងការពារគេយកមកដល់កន្លែង

ហ្នឹង គឺខ្ញុំត្រូវពិនិត្យកន្លែងហ្នឹង ។ ទាំងចំនួនតិចក៏ដូចជាចំនួនច្រើន គឺធ្វើដូចគ្នាទាំងអស់ ។

សៈ ចុះករណីត្រូវដឹកជញ្ជូនដោយរថយន្ត តើរថយន្តគេយកចូលមកបរិវេណ មកជិតអគារឃុំឃាំង ឬក៏រថយន្តហ្នឹងទុកខាងមាត់ច្រកតាមដងផ្លូវនៅខាងកើត ស្របនឹងមន្ទីរគុកទួលស្លែងហ្នឹង? សម្រាប់ដឹកអ្នកទោសយកទៅកម្ទេចក្នុងរថយន្ត តើគេចតនៅកន្លែងណា ក្នុងការនាំអ្នកទោសឡើងរថយន្តនោះ?

ឆេ ចំពោះការឡើងអ្នកទោសយកទៅរថយន្ត គឺរថយន្តគេចតនៅខាងក្រៅ ហើយនៅពេលដែលខ្ញុំពិនិត្យបញ្ជើអ្នកទោសបញ្ជាក់សាជាថ្មីហ្នឹង គឺទ្វារហ្នឹងបិទគេអត់ឲ្យចូលមកទេ ។

សៈ អ៊ីចឹងមានន័យថា បើទ្រង់ទ្រាយធំដែលត្រូវដឹករថយន្តហ្នឹង គឺរថយន្តនៅខាងក្រៅ ហើយលោកផ្ទៀងផ្ទាត់បញ្ជើនៅត្រង់មាត់ច្រកចេញចូល ។ អ៊ីចឹង ច្រកចេញចូលហ្នឹងកាលណោះមិនមែនបើកទូលាយអ៊ីចឹងទេ បានន័យថា ទុកតូចច្រកចង្អៀត ដើម្បីឲ្យការពិនិត្យហ្នឹងងាយស្រួល បានន័យថា បើចេញអាចលទ្ធភាពអាចចេញចូលបានតែមនុស្សម្នាក់ ឬក៏មនុស្សពីរនាក់ទេក្នុងការចេញទៅមិនមែនបើកធំអ៊ីចឹងទេ ឬក៏យ៉ាងម៉េចក្នុងការរបៀបបញ្ចេញអ្នកទោសឡើងរថយន្តបញ្ជូនទៅកម្ទេចនោះ?

[១៥:៤៤:៥៣]

ឆេ ចំពោះការបញ្ជូនអ្នកទោសឡើងរថយន្ត គឺមាត់ទ្វារគេអត់បើកចំហធំទេ គឺគេបើកតែមួយចំហៀងសម្រាប់អ្នកទោសចេញចូល ដឹកអ្នកទោសចេញតែប៉ុណ្ណោះ ។

សៈ លោករកនឹកឡើងវិញក្នុងករណីដោយឡែក ដូចជានាំយកអ្នកទោសមានចំនួនតិច ហើយយកទៅកម្ទេចនៅក្បែរនៃមន្ទីរសន្តិសុខស-២១ មជ្ឈមណ្ឌលភ្នំពេញ តើការប្រព្រឹត្តិទៅប្រហាក់ប្រហែលគ្នានឹងរបៀប ឬក៏បែបបទនៅក្នុងការដឹកអ្នកទោសដែលមានចំនួនច្រើនតាមរថយន្តបញ្ជូនទៅកម្ទេចនៅជើងឯក ឬក៏មានការរបៀបរបបធ្វើទៅខុសគ្នា?

ឆេ របៀបរបបក្នុងការកម្ទេចនៅក្បែរគុកទួលស្លែង គឺរបៀបរបបគេធ្វើដូចតែគ្នាទេ ។ ប៉ុន្តែគ្រាន់តែបើទៅក្រៅច្រើន គេប្រើឡានធំ ឡានចិនបីគ្រឿងហ្នឹង ហើយបើសិនជានៅក្នុងគុកនេះ ក្បែរគុកនេះវិញ គេធ្វើតែឡានតូចទេ ។

សៈ អ៊ីចឹង បានន័យថា ការនាំអ្នកទោសទៅសម្លាប់នៅតំបន់ក្បែរៗមជ្ឈមណ្ឌលមន្ទីរសន្តិសុខស-២១ ក្រុងភ្នំពេញ ក៏ត្រូវដឹកដោយរថយន្តដែរ មិនមែនបណ្តើរចេញទៅដោយថ្មើរជើងទេ ។ អ៊ីចឹងមែនទេ?

ឆៃ៖ ការណ៍អស់ទាំងនេះ គឺខ្ញុំចាំមិនច្បាស់ទេ ពីព្រោះភារកិច្ចរបស់ខ្ញុំ វាគឺគ្រាន់តែពិនិត្យ គឺខ្ញុំមិនសូវជាចាប់អារម្មណ៍ការដែលគេយកចេញទៅកម្ទេចនោះទេ ។ ខ្ញុំវាមិនច្បាស់ពីរឿងតើគេយកឡានទាំងអស់ ឬក៏គេដឹកយកទៅ ដោយនេះគឺខ្ញុំមិនទាន់ច្បាស់ ។

សៈ យើងសួរនេះដោយសារមានហេតុផលមួយចំនួន មានហេតុផលដែលព័ត៌មាននៅក្នុងសំណុំរឿងមានករណីខ្លះគឺការនាំទៅកម្ទេចមានលក្ខណៈជាបុគ្គល ម្នាក់ ឬក៏ពីរនាក់ បីនាក់ បាននិយាយថាមានមនុស្សរាយ មានមនុស្សមានចំនួនតិច ។ ប៉ុន្តែទន្ទឹមនឹងនេះ ការដែលក្នុងសំណុំរឿងមានកំណត់ហេតុមួយចំនួននៅក្នុងការស្រាវជ្រាវឆ្នាំមួយពាន់ប្រាំបួនរយ-- ចុងឆ្នាំ១៩៧៩ និងដើមឆ្នាំ១៩៨០ បានធ្វើការគាស់នូវរណ្តៅសាកសពរួមមួយចំនួននៅក្បែរ បច្ចុប្បន្នហៅថាគុកទួលស្លែងនេះ នៅតំបន់ជុំវិញក្បែរនេះ ខាងលិច ឬក៏ខាងត្បូង កំណត់ហេតុបានបង្ហាញ គណៈកម្មការបានបង្ហាញឲ្យឃើញថា មានរណ្តៅសាកសពរួម មានរណ្តៅខ្លះម្ភៃប្រាំបីនាក់ មានរណ្តៅខ្លះរហូតដល់សាមសិបពីរនាក់ ហើយភាគច្រើនគឺជាងដប់នាក់ ដប់ប្រាំមួយ, ដប់ប្រាំពីរនាក់ ទៅម្ភៃនាក់ ក្នុងមួយរណ្តៅ នេះបានចង់សួរព័ត៌មាននេះគឺពាក់ព័ន្ធជាមួយនឹងការបញ្ចេញផង និងការបញ្ជូនទៅសម្លាប់ដែលមានទ្រង់ទ្រាយជាក្រុម ជារណ្តៅសពរួមដែលមានកម្រិតពីម្ភៃនាក់ ឬក៏ជាងដប់នាក់ ទៅសាមសិបនាក់នេះ វាអាចមានវិធីយ៉ាងម៉េចក្នុងការបញ្ជូនចេញ ក្នុងការប្រគល់ទទួល?

[១៥:៤៨:៤៣]

បាននិយាយថា តើបុគ្គលទទួលនោះម្តង ឧបមាថា បញ្ជូនចេញទៅម្ភៃនាក់ ឬក៏ដប់ប្រាំនាក់ យើងបញ្ជូនម្តងទៅឲ្យ-- បញ្ចេញទៅឲ្យអ្នកពិនិត្យ បញ្ចេញពីខាងក្នុងគុកទៅឲ្យខាងក្រៅ ទៅឲ្យអ្នកដែលទទួលបន្ទុកនាំទៅកម្ទេចហ្នឹង ខាងក្រៅអ៊ីចឹង រាប់អស់រួចហើយ យើងបិទទ្វារចប់បញ្ជី ឬក៏មានករណីនាំបញ្ចេញមួយទៅនាំទៅបាត់ទៅ ហើយបន្ទាប់មកនាំ មកយកមួយទៀត នាំមួយទៀតទៅបាត់ទៅ នាំមួយទៀត រហូតដល់ច្រើនម៉ោង អាចចំណាយពេលវេលាមួយម៉ោង ឬពីរម៉ោងអីទៅ ទម្រាំតែអស់មនុស្សដប់នាក់ ឬក៏ដប់ប្រាំនាក់ ឬក៏ម្ភៃនាក់អ៊ីចឹង បានជាយើងសួរបញ្ហាក់ពីបញ្ហាហ្នឹង ពីព្រោះអង្គហេតុវាអាចមានបញ្ហាដូចយើងបានជម្រាបលោកអ៊ីចឹងថា វាមានបញ្ហាហ្នឹងដែលយើងមានការចង់ដឹងច្បាស់អំពីហេតុការណ៍នេះ ។ តើលោកអាចនៅចងចាំបានទេ បញ្ហានេះ?

ឆៃ៖ បញ្ហានេះ គឺជាទូទៅ បើនិយាយឲ្យខ្លីគឺខ្ញុំមិនសូវបានចងចាំប៉ុន្មានទេ ។ ប៉ុន្តែ ជាទូទៅតែខ្ញុំផលិតបញ្ជីហើយ ច្បាស់គេដាក់ឡានទៅហើយ ។ គេមិនដែលទៅបណ្តើរ ។

សៈ តើតម្រូវការ ឬក៏របៀបរបបធ្វើការរបស់លោក តើតម្រូវឲ្យអ្នកដែលនាំអ្នកទោសទៅកម្ទេចហ្នឹងគាត់ធ្វើបញ្ជីនៃការកម្ទេចមនុស្សដែលប្រគល់ទទួលដោយលោកបានត្រួតពិនិត្យត្រង់ច្រកចេញចូលហ្នឹង ហើយត្រឡប់ធ្វើបញ្ជីបង្វិលមកឲ្យលោកវិញដែរឬទេ ក្រោយពេលប្រតិបត្តិការនៃការកម្ទេចរួចរាល់ហើយ?

ឆៃ រាល់ការដែលដកចេញអ្នកទោស គឺពេលដែលខ្ញុំពិនិត្យបញ្ជីហើយ គឺបញ្ជីនោះ គឺប្រគល់ទៅឲ្យហ៊ា ហើយ ហ៊ា គឺគេប្រគល់ទៅឲ្យកងការពារដែលយកទៅហ្នឹងហើយ គឺមាន ហ៊ុយ ឬក៏ ប៉ែង គឺជាអ្នកទទួលបញ្ជីនោះ ហើយបញ្ជីនោះគឺមកវិញគេឲ្យ ហ៊ា វិញហើយ ហើយហ៊ា ហ្នឹងគឺឲ្យបញ្ជីខ្ញុំដើម្បីធ្វើបញ្ជីអ្នកទោសដែលត្រូវដកកម្ទេចហ្នឹង ។

សៈ គ្រប់ករណីទាំងអស់ បានន័យថា ករណីរាយ កម្ទេចមនុស្សរាយ បានន័យមនុស្សពីរបីនាក់ ឬក៏ម្នាក់ក៏ធ្វើអ៊ីចឹងដែរ? ហើយការបញ្ចេញទ្រង់ទ្រាយធំដែលមានការបញ្ជូនទៅដូចជាទៅជើងឯកដែលមានទ្រង់ទ្រាយធំ កម្ទេចម្តងរាប់សិបនាក់ ឬក៏រាប់រយនាក់ ក៏ធ្វើបញ្ជីបង្វិលត្រឡប់មកឲ្យលោកវិញតាមរយៈ ហ៊ា អ៊ីចឹងទាំងអស់មែនទេ?

[១៥:៥១:៤២]

ឆៃ បាទ, ពិតប្រាកដមែនហើយ ។

សៈ របៀបរបបដែលលោកធ្វើការដូច្នេះហ្នឹង តើលោកបានទទួលការរៀនសូត្រ ឬក៏ការណែនាំពីអ្នកណាដែរ?

ឆៃ របៀបរបបនៃការធ្វើបញ្ជី គឺខ្ញុំទទួលផ្ទាល់ គឺទទួលបញ្ជាតែពី ហ៊ា ទេ គឺហ៊ា ឲ្យខ្ញុំធ្វើយ៉ាងម៉េច គឺខ្ញុំធ្វើអ៊ីចឹង ។

សៈ ចុះអ្នកទោសសំខាន់ៗ ឬក៏ជនបរទេស ដែលលោកនិយាយខាងដើមថា អ្នកទាំងអស់នោះគឺពេលដែលយកមកដាក់គុក ឬក៏យកមកឃុំឃាំងនោះនៅមន្ទីរស-២១ មិនឆ្លងកាត់លោកទេ គេគ្រាន់តែធ្វើរបាយការណ៍ទេ ។ សំណួរសួរថា នៅពេលដែលគេបញ្ចេញទៅ មនុស្សនោះទៅកម្ទេច តើត្រូវឆ្លងកាត់បែបបទជាមួយនឹងលោក និងការងារភារកិច្ចរបស់លោកនៃការបញ្ជីស្នាមហ្នឹងយ៉ាងម៉េចដែរ?

ឆៃ ចំពោះអ្នកទោសសំខាន់ៗ គឺគេមិនឆ្លងកាត់តាមរយៈរបស់ខ្ញុំទេ គឺគេ ឌុច គេស្គាល់អ្នកធំហើយអស់ហើយ ដូច្នេះ ហ៊ា ក៏គេដឹងដែរ ។ ដូច្នេះ គេសម្រេច ព្រោះអ្វីគឺគេធ្វើដោយខ្លួនគេទេ គឺអត់មានឆ្លងកាត់តាមខ្ញុំទេ ។

សៈ តើមានអ្នកដែលទទួលបន្ទុកកម្ទេចអ្នកទោសសំខាន់ៗ ឬក៏អ្នកទោសដែលជាជនជាតិបរទេស ឬក៏ពួកបស្ចិមប្រទេស ដែលជាចាត់ទុកថាអ្នកដែលជាប់គុកពិសេសនោះ ក្រោយពេលកម្ទេចរួច តើគេបានៗបញ្ជូនឯកសារ ឬក៏ឈ្មោះ បញ្ជីឈ្មោះមកត្រឡប់មកវិញ ដើម្បីឲ្យលោកធ្វើការ ធ្វើជាបញ្ជីកម្ទេចដែរឬទេ?

ឆៈ កន្លងមកគឺថា កាលអ្នកទោសដែលនៅគុកពិសេសខាងក្រៅ គឺខាងក្រៅក៏ដូចជាខាងក្នុង បើសិនជាគេយកទៅកម្ទេច គឺខ្ញុំអត់បានដឹងច្បាស់លាស់ទេ ប៉ុន្តែនៅពេលដែលឈ្មោះហ្នឹងកម្ទេច គឺហ៊ានគេយកបញ្ជីហ្នឹងឲ្យខ្ញុំរៃអង្គាសការណ៍ជាប្រចាំ ដើម្បីឡើងទៅលើដែរ ។

សៈ តាមធម្មតា នៅក្នុងបញ្ជីដែលបញ្ជីអ្នកទោស ដែលលោកអាចលើកឡើងថាមានចំណារបស់ជនជាប់ចោទ ហើយដែលបញ្ជូនមកលោកតាមរយៈឈ្មោះ ហ៊ា ហ្នឹង ។ ចំណារហ្នឹងជាទូទៅដែលមានន័យថាកម្ទេចហ្នឹង គឺគេចារលើខ្លឹមសារថាម៉េចទៅបានជាលោកដឹងថា ឯកសារណាដែលឈ្មោះនេះ ឬក៏អ្នកទោសនេះត្រូវកម្ទេច? គេដាក់ខ្លឹមសារនៃចំណារហ្នឹងថាដូចម្តេចទៅ?

[១៥:៥៥:៣៥]

ឆៈ ខ្លឹមសារនៃចំណារដែលដាក់កម្ទេចនោះ គឺមានតែ ឌុច ទេ ដែលហ៊ានចារពីលើត្រង់ឈ្មោះអ្នកទោសដែលត្រូវកម្ទេច ហើយចំណារនោះគឺគេសរសេរអក្សរ “កំៗ” ចំពោះឈ្មោះដែលត្រូវកម្ទេចនោះ គឺគេដាក់សរសេរថា “កំៗ” តែម្តង ។

សៈ ចុះនិយាយអំពីបញ្ជីវិញ បញ្ជីដែលលោកថា ក្រោយពេលគេនាំយកទៅកម្ទេចរួចបញ្ជូនឡប់មកវិញដើម្បីធ្វើបញ្ជីអ្នកទោសដែលបានកម្ទេច ។ សំណួរសួរថា បញ្ជីអ្នកទោសដែលបានកម្ទេចហ្នឹងការកំណត់នៅក្នុងបញ្ជីនោះ តើត្រូវសរសេរអំពីព័ត៌មានអ្វីខ្លះទៅតាមដែលលោកចងចាំ? លោកអាចនិយាយប្រាប់ដល់អង្គសវនាការយល់អំពីបញ្ហានេះដែរឬទេ?

ឆៈ ចំពោះបញ្ជីកម្ទេចដែលខ្ញុំបានចងចាំ-- សូមអត់ទោសសូមសួរម្តងទៀត ។

សៈ តាមលោកចងចាំ លោកអំមិញនិយាយថា គ្រប់មនុស្សនាំទៅកម្ទេចហ្នឹងគេមានវិធីបញ្ចេញមុនដំបូងបញ្ចូល បញ្ចូលរួចហើយបញ្ចេញទៅកម្ទេច ។ បញ្ចេញទៅកម្ទេចហ្នឹងផ្អែកលើឯកសារដែលផ្តល់ដោយឈ្មោះ ហ៊ា ដែលជាអនុប្រធាន មកឲ្យលោក ហើយចំណារនេះលោកឃើញថា មានចំណារបស់ ឌុច លោកបាននិយាយហើយ អំមិញចំណារទាំងអស់នេះគឺភាគច្រើនគឺប្រើពាក្យថា “កំ” ។ “កំ” ហ្នឹងមានន័យថា “កម្ទេច” ។ ឥឡូវហ្នឹងបានចំណារហ្នឹងលោកបានរៀបចំបញ្ជីជាថ្មី ដើម្បីបញ្ជូនទៅ--

រាយការណ៍ទៅប្រាប់ ហ៊ិ វិញ អំពីទីកន្លែង អំពីចំណុចណាៗទាំងអស់ ដើម្បី ហ៊ិ ហ្នឹងគេចាត់តាំងកម្លាំង ដើម្បីនាំអ្នកទោសចេញទៅកម្ទេច ។ ក្រោយពីបានធ្វើដូច្នេះរួចហើយ ដល់មានផែនការកម្ទេច គឺធ្វើការផ្ទៀងផ្ទាត់ដោយសារលោកហ្នឹងមានកំហិតមួយថា បើសិនជាមានការភាន់ច្រឡំ បានន័យថា កម្ទេចអ្នកទោសមានការភាន់ច្រឡំ ទៅលើអ្នកទោសដែលមិនទាន់ត្រូវបានដល់ពេលត្រូវកម្ទេចទេនោះ គឺលោកត្រូវទទួលកំហុស ទទួលខុសត្រូវខ្លួនឯង បានន័យថា ដល់វេនត្រូវចាប់ខ្លួនឯងម្តង ។ ដោយមានការប្រយ័ត្នប្រយែងដូច្នេះ លោកបានរៀបចំរបៀបធ្វើការងារមួយពេលដែលបញ្ចេញអ្នកទោសទៅកម្ទេច គឺធ្វើការផ្ទៀតផ្ទាត់បញ្ជីរវាងលោកជាមួយនឹងក្រុមដែលនាំអ្នកទោសទៅកម្ទេចនៅមាត់ទ្វារចេញចូល ដើម្បីផ្ទៀងផ្ទាត់ឲ្យច្បាស់ ចៀសវាងមានការភាន់ច្រឡំ ។ ហើយបន្ទាប់ពីនោះទៅ គឺអ្នកដែលនាំទៅកម្ទេចនោះ គឺត្រូវកាន់បញ្ជីមួយ ដែលលោកបាននិយាយអំមិញ គឺកាន់បញ្ជីមួយដែលរៀបចំរួចហើយនេះ ដើម្បីទៅផ្ទៀងផ្ទាត់នៅក្នុងពេលប្រតិបត្តិការសម្លាប់អ្នកទោស ហើយសម្លាប់រួចហើយ គឺអ្នកដែលប្រតិបត្តិការនោះគឺនាំយកបញ្ជីដែលខ្លួនគេផ្ទៀងផ្ទាត់ពេលដែលអនុវត្តកម្ទេចនោះ មកត្រឡប់មកវិញ ។ ត្រឡប់មកវិញ ប្រគល់ឲ្យ ហ៊ិ ហើយ ហ៊ិយកមកឲ្យលោក ដើម្បីធ្វើបញ្ជីរួម បញ្ជីកម្ទេចអ្នកទោសដែលបាន-- អ្នកទោសដែលត្រូវបានកម្ទេចរួចហើយ ដើម្បីធ្វើបញ្ជីនោះរាយការណ៍ទៅថ្នាក់លើទៀត ។ សំណួរសួរថា បញ្ជីរួមនៃអ្នកទោសដែលត្រូវបានកម្ទេចរួច ដើម្បីរាយការណ៍ជូនទៅថ្នាក់លើនោះ សួរថាបញ្ជីនោះតម្រូវឲ្យមានព័ត៌មានអំពីអ្វីខ្លះ?

[១៦:៥៩:៥៦]

ឆេ៖ បញ្ជីចំពោះអ្នកទោសដែលកម្ទេចរួចហើយ គឺខ្ញុំទៅ ស្អែកឡើង គឺទៅរាយការណ៍ចាប់ពីម៉ោង៧ ទៅ គឺរាយការណ៍ហើយ គឺបញ្ជីអ្នកនោះគឺដាក់ឈ្មោះថា បញ្ជីកម្ទេចថ្ងៃប៉ុន្មានថាត្រូវកម្ទេច ។ ឧទាហរណ៍ ថ្ងៃប៉ុន្មានគឺដាក់ទៅតាមហ្នឹង គឺអត់មាននេះអី គឺគ្រាន់តែសរសេរឈ្មោះតួនាទី តែឈ្មោះកម្ទេចៗទេតាមហ្នឹង តែប៉ុណ្ណឹងទេ ។ ហើយបញ្ជីដាក់ខាងលើថាឈ្មោះកម្ទេចថ្ងៃប៉ុន្មានអ៊ីចឹង ។

សេ៖ ប៉ុន្តែ អម្បាញ់មិញនេះ លោកបានមានការពាក់ព័ន្ធជាមួយនឹង-- ឆ្លើយទៅគឺមានការឆ្លើយការមួយថាមានកុមារដែលអត់មានការចុះបញ្ជីទេ ហើយសំណួរសួរថា តាមដែលលោកធ្វើការកត់សម្គាល់តើកុមារដែលយកទៅជាមួយឪពុកម្តាយហ្នឹង កុមារនោះទៅអស់ហើយ? ត្រូវគេបញ្ជូនពួកកុមារទៅទុកនៅកន្លែងណា?

ឆ៖ កុមារដែលត្រូវទៅជាមួយឪពុកម្តាយ គឺទៅដល់កន្លែងខ្ញុំគេអត់ទាន់បំបែកទេ រហូតទៅដល់ចូលក្នុងគុក បាន ហ៊ិ គេចាត់ទាំងកម្លាំងឲ្យទៅបំបែកពីឪពុកម្តាយ ។ ហើយកុមារដែលចូលក្នុងគុកហើយគឺគ្មានរស់ទេ គឺត្រូវស្លាប់ទាំងអស់ហើយ ។

ស៖ តាមលោកចងចាំនៅក្នុងអំឡុងពេលដែលលោកធ្វើការងារនៅទីនោះ តើមានអ្នកទោសត្រូវបានដោះលែងវិញដែរឬទេ?

ឆ៖ តាមតែការដែលខ្ញុំចងចាំ ចំពោះអ្នកទោសដែលជាប់គុកនៅកន្លែងឋលស្នែង ដែលខ្ញុំធ្វើការនៅកន្លែងនោះ គឺអ្នកទោសគឺអត់មានដោះលែងទាំងអស់ បើនិយាយរួម ។ អានេះ ប៉ុន្តែខ្ញុំមិនបានដឹងច្បាស់ប្រាកដឲ្យនេះ ប៉ុន្តែបើតាមខ្ញុំដឹង គឺអត់មានបានដោះលែង ។

ស៖ លោកមានដឹង មានដែលដឹងព័ត៌មាន ឬមានព្រឹត្តិហេតុនៃអ្នកទោសរត់រួច រត់ចាកចេញពីមន្ទីរសន្តិសុខស-២១ ដែរឬទេ?

ឆ៖ ខ្ញុំបានដឹងព្រឹត្តិហេតុនៃអ្នកទោសរត់រួចម្នាក់នៅក្នុងគុកមន្ទីរស-២១ ហើយអ្នកទោសនោះគឺជាអ្នកធ្វើការនៅមន្ទីរស-២១ ។ ប៉ុន្តែក្រោយមកទាំងកងរយ ទាំងកងការពារនៅហ្នឹង ត្រូវគេចាប់ទាំងអស់ ។

ស៖ គាត់-- អ្នកទោសនៅរត់រួចទេ ឬក៏ក្រោយមកមានការចាប់ខ្លួនបានវិញ?

ឆ៖ អ្នកទោសនោះ គឺរត់រួចបាត់ ។

ស៖ អ្នកទោសដែលរត់រួចបាត់ លោកបាននិយាយអ៊ីចឹង ពាក់ព័ន្ធជាមួយនឹងភារកិច្ចរបស់លោក តើលោកធ្វើបញ្ជីអ្វីដែរ? លោកមានធ្វើបញ្ជីទេ? បញ្ជីអ្នកទោសរត់រួចអ៊ីចឹងទេ?

ឆ៖ ចំពោះអ្នកទោសរត់រួច សភាពការណ៍អីក៏ដោយ ឲ្យតែមានសភាពការណ៍ក្នុងហ្នឹង គឺខ្ញុំត្រូវតែ-- ហ៊ិ ឲ្យរាយការណ៍ទាំងអស់ ដើម្បីជូនទៅខាងមន្ទីរសួរចម្លើយ ។ ឧបមាថា បើរត់រួច យើងដាក់រត់រួច បើអ្នកទោសឈឺ យើងដាក់ថាឈឺ បើអ្នកទោសស្លាប់ក្នុងអគារ យើងដាក់អ្នកទោសស្លាប់ក្នុងអគារ ។ អាហ្នឹង ជារបាយការណ៍ចំពោះអ្នកទោសដែល-- ជាមួយរបាយការណ៍អ្នកទោសដែលចូលជាប្រចាំថ្ងៃ ។

[១៦:០៤:៣៩]

ស៖ លោកនិយាយអំមិញ ដល់ចំណុចមួយថា ដោយសារមានការអ្នកទោសរត់រួចម្នាក់ អ៊ីចឹង គឺព្រឹត្តិហេតុ ព្រឹត្តិការណ៍នោះនាំឲ្យមានការចាប់ខ្លួនទូរបុគ្គលិកមន្ទីរស-២១ ជាច្រើននាក់ ។ អ៊ីចឹង មែន

ទេ? តាមដែលលោកនិយាយអំមិញ ឬក៏យើងមានការស្តាប់ មានការភាន់ច្រឡំ?

អ៊ុង៖ កាលដែលខ្ញុំដឹង គឺមានការចាប់អ្នកទោសជាច្រើននាក់ ក្រោយពីអ្នកទោសរត់រួចម្នាក់ ។

សៃ៖ បាននិយាយថា ក្រោយពីមានអ្នកទោសរត់រួចម្នាក់ គឺបុគ្គលិកកម្មាភិបាលនៅមន្ទីរស-២១ ត្រូវបានចាប់ខ្លួនឃុំឃាំង ហើយនិងកម្ទេចអស់ជាច្រើននាក់ ។ អ៊ីចឹងមែនទេ?

អ៊ុង៖ ពិតប្រាកដមែន ជាពិសេសកងរយក៏ត្រូវជាប់ កងហាក៏ត្រូវជាប់ ហើយនិងកងការពារដែលយាមនៅអគារហ្នឹង គឺត្រូវជាប់ទាំងអស់ ។

សៃ៖ កងរយហ្នឹង ថ្នាក់យ៉ាងម៉េចទៅកងរយហ្នឹង? ក្តាប់ៗ ក្តោបក្តាប់មនុស្សប៉ុន្មាននាក់? ហើយកងហាក្តោបក្តាប់មនុស្សប៉ុន្មាននាក់?

អ៊ុង៖ ខ្ញុំសូមបញ្ជាក់ គឺកងរយហ្នឹង គឺកងអនុសេនាធំ ។ កងហាហ្នឹង គឺកងអនុសេនាតូច ។ កងរយហ្នឹងគឺ ក្តាប់មនុស្សមួយរយនាក់ ។ កងហាគឺ ក្តាប់មនុស្សហាសិបនាក់ ។

សៃ៖ នៅក្នុងព្រឹត្តិហេតុនៃការចាប់ខ្លួនបុគ្គលិកកម្មាភិបាលនៃមន្ទីរសន្តិសុខស-២១ តើកិច្ចការរបស់លោក ជាអ្នករៀបចំឯកសារប្រព្រឹត្តទៅ ឬក៏ប្រតិបត្តិការយ៉ាងដូចម្តេចដែរ? ដូចករណីទូទៅដែរ? ឬក៏មានលក្ខណៈពិសេសជាងករណីធម្មតាករណីទូទៅ?

អ៊ុង៖ សូមបញ្ជាក់ម្តងទៀតសំណួរនេះ ខ្ញុំស្តាប់អត់ទាន់ ។

សៃ៖ លោកនិយាយអំមិញដល់ការចាប់ខ្លួនកម្មាភិបាលបុគ្គលិកនៃមន្ទីរស-២១ នៅក្នុងនោះមានកងរយកងហា និងកងការពារមួយចំនួន ហើយដែលលោកនិយាយផ្អែកទៅលើព្រឹត្តិហេតុនៃអ្នកទោសម្នាក់បានរត់រួចខ្លួនចាកចេញពីមន្ទីរសន្តិសុខស-២១ ។ សំណួររបស់យើងសួរថា ភារកិច្ចរបស់លោកនៅក្នុងការរៀបចំធ្វើបញ្ជីស្នាមផ្សេងៗ ពាក់ព័ន្ធជាមួយនឹងអ្នកទោស ដែលពីមុនគាត់ជាកម្មាភិបាលបុគ្គលិកនៃមន្ទីរសន្តិសុខស-២១ តើប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរ?

[១៦:០៨:២៦]

អ៊ុង៖ ចំពោះការចាប់ខ្លួនរបស់កម្មាភិបាលសន្តិសុខមន្ទីរ និងបុគ្គលិកសន្តិសុខមន្ទីរស-២១ គឺគេអត់ឲ្យខ្ញុំដឹងទេ គឺគេ ហ៊ិ គឺក្រោយបញ្ជា ឌុច ហ្នឹង គឺគេឲ្យចាប់ ។ ចាប់ហ្នឹង ដល់ពេលហ្នឹង គឺខ្ញុំអត់មានសិទ្ធិទៅសួរអីទេ គឺហ៊ិ គេឲ្យជាឈ្មោះ-- ចាប់ឈ្មោះនេះ ឈ្មោះនេះ ដើម្បីស្រង់បញ្ជីយកទៅរាយការណ៍ខាងលើ ។

សៈ អ៊ីចឹង បាននិយាយថា លោកគឺមិនដែលបានទទួល គឺសម្ភាសន៍ ឬក៏សួរនាំអំពីប្រវត្តិរូបនៃបុគ្គលិក ឬក៏កម្មាភិបាលនៃមន្ទីរសន្តិសុខស-២១ ដែលត្រូវចាប់ខ្លួននោះទេ ។ ការចាប់ខ្លួនគឺប្រព្រឹត្តឡើងដោយស្ងាត់ៗ ហើយការរៀបចំឯកសារ គឺមិនឆ្លងកាត់លោកទេ គឺក្រោយពេលគេចាប់រួចហើយ គេគ្រាន់តែបញ្ជូនឈ្មោះមកឲ្យលោកដើម្បីបញ្ជូនឈ្មោះនោះ ទៅក្នុងបញ្ជីអ្នកទោស ដើម្បីរាយការណ៍ជូនទៅថ្នាក់លើតែប៉ុណ្ណោះ ។ អ៊ីចឹងមែនទេ?

ឆៃ បាទ, ពិតមែន ។

សៈ ចុះក្នុងករណីត្រូវសួរចម្លើយ អ្នកដែលត្រូវបានចាប់អតីតបុគ្គលិកកម្មាភិបាលមន្ទីរស-២១ ត្រូវបានចាប់ខ្លួន ដល់ពេលត្រូវការសួរចម្លើយ តើឆ្លងកាត់បែបបទជាមួយនឹងលោកយ៉ាងម៉េចដែរ?

ឆៃ ចំពោះការសួរចម្លើយ នៅក្នុងរបស់បុគ្គលិកមន្ទីរស-២១ គេខាងអ្នកសួរ គេដឹងហើយ គឺថាបុគ្គលិកមន្ទីរស-២១ គេគ្រាន់តែចូលគេដឹង មិនបាច់ឆ្លងកាត់តាមខ្ញុំទេ ។

សៈ លោកមានដឹងថា ពាក់ព័ន្ធជាមួយនឹងបុគ្គលិកនិងកម្មាភិបាលនៃមន្ទីរសន្តិសុខស-២១ ខ្លួនឯងដែលត្រូវបានចាប់ខ្លួន ហើយសួរចម្លើយមានបែបបទរបៀបរបបធ្វើការងារ សម្រាប់មុខសញ្ញាដែលជាបុគ្គលិកជាកម្មាភិបាលនៃមន្ទីរសន្តិសុខស-២១ ពីមុនមកហ្នឹង ត្រូវក្លាយខ្លួនជាអ្នកទោសនោះតើគេប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរ? ដូចជាការសួរចម្លើយ នាំទៅសួរចម្លើយអីជាដើម តើគេប្រព្រឹត្តទៅយ៉ាងម៉េចលោកដឹងទេ? ឬក៏លោកដែលបានកត់សម្គាល់រឿងនេះទេ?

ឆៃ ការណ៍អស់ទាំងនេះ គឺខ្ញុំអត់បានដឹងទេ ពីព្រោះក្នុងបុគ្គលិកមន្ទីរស-២១ គេលាក់ការណ៍។ គ្រាន់តែយកអ្នកទោសចេញ ក៏គេឃ្លុំទាំងអស់ដែរ កងសួរចម្លើយ ។ ដូច្នេះ គឺខ្ញុំអត់បានដឹងទេ ។

[១៦:១១:២៩]

សៈ កងសួរចម្លើយ គេឃ្លុំនោះ ឃ្លុំយ៉ាងម៉េចទៅ? ឃ្លុំអ្នកទោស ដែលជាអតីតបុគ្គលិកកម្មាភិបាល ស-២១ ពេលដែលនាំទៅ ឬពេលដែលនាំត្រឡប់មកវិញ ពីសួរចម្លើយ គេឃ្លុំនោះ ឃ្លុំយ៉ាងម៉េចទៅ?

ឆៃ គេយកំណាត់គ្រប ពេលបណ្តើរទៅ ដើម្បីកុំឲ្យកងការពារឃើញ កុំឲ្យអ្នកដទៃទៀតផ្សេងឃើញ ។

សៈ ចុះពេលដែលសួររួចហើយ នាំត្រឡប់មកវិញ?

ឆៃ ពេលដែលសួររួចហើយ ត្រឡប់មកវិញ ក៏គេធ្វើដូច្នេះដែរ ។

ស៖ តាមលោកដឹង ព្រោះលោកធ្វើការងារទាំងនោះ ហើយគ្រប់គ្រងបញ្ជី តាមការប៉ាន់ស្មានរបស់លោក តើបុគ្គលិកមន្ទីរស-២១ ដែលចាប់ខ្ពួនហ្នឹង មានទាំងខាងមន្ទីរ២១ "ឃ" ឬក៏ព្រៃស នោះ ។ តើមានការចាប់ខ្ពួនដាក់ឃុំឃាំងបញ្ជូនមកមន្ទីរស-២១ មជ្ឈមណ្ឌលភ្នំពេញដើម្បីឃុំឃាំង ដូចកម្មាភិបាលបុគ្គលិកដែលធ្វើការនៅក្នុងមន្ទីរស-២១ មជ្ឈមណ្ឌលភ្នំពេញដែរឬទេ? ឬក៏មានតែបុគ្គលិកកម្មាភិបាលធ្វើនៅមន្ទីរសន្តិសុខ ស-២១ មជ្ឈមណ្ឌលភ្នំពេញទេ ទើបមានការចាប់ខ្ពួនឃុំឃាំងនោះ?

អ៖ ការចាប់ខ្ពួនឃុំឃាំងគឺមានទាំងអស់ គឺមានទាំងខាង២៤ ខាងការពារនិងកងសួរចម្លើយ ។ ហើយការណ៍នេះគឺខ្ញុំមិនដឹងច្បាស់ ពីព្រោះខ្ញុំយូរកាន់តែភ្លេច វាយូរឆ្នាំហើយ ។ បើចង់ច្បាស់ គឺកូឡោនអ្នកចាប់នៃស-២១ បុគ្គលិក គឺក្នុងកូឡោនសេនាធិការ ពីព្រោះមន្ទីរស-២១ នៅក្រោមការក្តោបក្តាប់របស់សេនាធិការ ។ ដូច្នេះ ក្នុងបុគ្គលិកក្នុងមន្ទីរស-២១ គឺដាក់នៅក្នុងអង្គភាពសេនាធិការ ។

ស៖ តាមលោកដឹង មានចំនួនច្រើនទេ ប្រហែលជាប៉ុន្មានដែរ? ចំណែកឯបញ្ជីមានរួចហើយនៅក្នុងសំណុំរឿង នោះជាប្រភេទឯកសារ តុលាការនឹងពិនិត្យជាក់ស្តែង ពីព្រោះឯកសារនៅក្នុងសំណុំរឿង ។ ប៉ុន្តែការសួរដេញដោលនៅពេលនេះ គឺនិយាយផ្ទាល់មាត់នូវការចងចាំរបស់សាក្សី ដើម្បីផ្ទៀងផ្ទាត់ថាតើវាសមស្របគ្នាដែរឬទេ? រវាងបញ្ជីដែលបានធ្វើរួចហើយ ជាមួយនឹងសាក្សីដែលបានដឹងរឿងនោះ? អ៊ីចឹងហើយអាចមានលក្ខខណ្ឌខុសគ្នា តាមលោកដឹង តើមានចំនួនប្រហែលប៉ុន្មានដែរ?

អ៖ កាលដែលខ្ញុំដឹង វាមិនច្បាស់ប្រាកដ ប៉ុន្តែខ្ញុំសន្និដ្ឋានស្មាន គឺមិនតិចដែរទេ គឺមិនក្រោមពីមួយរយ គឺមានតែមួយរយ ទៅជិតពីរនាក់ ឬក៏ចន្លោះហ្នឹង គឺខ្ញុំមិនច្បាស់ ។

[១៦:១៥:00]

ស៖ ហើយកម្មាភិបាលបុគ្គលិកនៃមន្ទីរស-២១ រួមទាំងនៅព្រៃសផងនោះ ការចាប់ខ្ពួនឃុំឃាំងមានដែលអ្នកណាត្រូវបានដោះលែងវិញទេ ឬក៏ការប្រព្រឹត្តិចំពោះអតីតបុគ្គលិកកម្មាភិបាលមន្ទីរស-២១ ទាំងអស់នោះគឺដូចអ្នកទោសដទៃទៀតដែរ គឺចុងក្រោយត្រូវកម្ទេចទាំងអស់?

អ៖ ការប្រព្រឹត្តិនៅក្នុងគុកទួលស្លែង ការដែលចាប់បុគ្គលិកនៅមន្ទីរស-២១ គឺតែចាប់ហើយគឺគេយកទៅសម្លាប់ហើយ គឺអត់មានដោះលែងទេ គឺគេធ្វើដូចជាអ្នកទោសជាទូទៅទាំងអស់ ។

ស៖ លោកបានចាកចេញពីមន្ទីរសន្តិសុខស-២១ មជ្ឈមណ្ឌលក្រុងភ្នំពេញហ្នឹងនៅថ្ងៃខែឆ្នាំណាដែរ?

ឆៃ៖ ខ្ញុំបានចាកចេញពីមន្ទីរស-២១ គឺនៅពេលដែលឮស្នូរកាំភ្លើង គឺនាំគ្នាផ្អើលចេញមកក្រៅ គឺខ្ញុំចាកចេញពីថ្ងៃហ្នឹង ។

សៈ ពេលឮស្នូរកាំភ្លើងចូលដល់ភ្នំពេញមានទាំងសំឡេងរថក្រោះផងដែរហ្នឹងមែនទេ?

ឆៃ៖ ពិតប្រាកដមែនហើយ ។

សៈ អ៊ីចឹងបានន័យថា លោកចាកចេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រហែលជាម៉ោងប៉ុន្មានដែរ?

ឆៃ៖ ប្រហែលជាម៉ោងដប់ ទៅដប់មួយ តែមិនច្បាស់ទេ ចង់ភ្លេចហើយ ។

សៈ នៅពេលដែលលោកចាកចេញ លោកគិតឡើងវិញទៅមានការចងចាំទេ ថាតើមនុស្សដែលនៅក្នុងមន្ទីរស-២១ ចាកចេញពីមន្ទីរស-២១ កាលណោះមានមនុស្សប៉ុន្មានប្រភេទ? តើមានអ្នកទោសដែលនៅរស់រានមានជីវិតហើយបានចាកចេញនៅក្នុងដំណាលពេលជាមួយនឹងលោក និងក្រុមបុគ្គលិកកម្មាភិបាលស-២១ ចាកចេញដែរឬទេ?

ឆៃ៖ ចំពោះការចាកចេញពីមន្ទីរស-២១ នៅថ្ងៃ៧ មករា ហ្នឹងគឺមានទាំងអ្នកទោសចេញទៅដែរ ប៉ុន្តែអ្នកទោសហ្នឹង គឺអ្នកទោសដែលធ្វើការបម្រើខាងក្រៅ គឺចេញទៅជាមួយ ។

សៈ អ៊ីចឹងនៅក្នុងអំឡុងពេលនៃការគ្រប់គ្រងអ្នកទោសនៅក្នុងមន្ទីរសន្តិសុខស-២១ កាលណោះ គឺមានអ្នកទោសមួយចំនួនត្រូវបានឲ្យរស់នៅខាងក្រៅ មិនដាក់ខ្នោះ មិនដាក់ច្រវាក់នៅក្នុងបន្ទប់ឃុំឃាំងរួម ឬក៏បន្ទប់ឃុំឃាំងតូចៗទេ ដោយឲ្យនៅជួយធ្វើការ ។ សំណួរសួរថា អ្នកទោសដែលទុកឲ្យរស់រានមានជីវិត ហើយនៅខាងក្រៅឲ្យជួយធ្វើការហ្នឹង បញ្ហែដែលលោកគ្រប់គ្រងហ្នឹងដាក់ចារនៅក្នុងបញ្ជីគ្រប់គ្រងចំពោះអ្នកទាំងអស់ន៎ុងថាយ៉ាងម៉េច?

[១៦:១៨:៤៧]

ឆៃ៖ បញ្ជីគ្រប់គ្រងហ្នឹងគឺដាក់ថា អ្នកទោសធ្វើការនៅខាងក្រៅតែម្តង ។

សៈ ចុះរបាយការណ៍? របាយការណ៍ទៅលើចំពោះអ្នកទោសដែលមន្ទីរសម្រេចថា ទុកគាត់ដើម្បីជួយធ្វើការខាងក្រៅដោយមិនដាក់នៅក្នុងបន្ទប់ឃុំឃាំងរួម ឬឃុំឃាំងដោយឡែក ដាក់ច្រវាក់ ដាក់ខ្នោះហ្នឹងរបាយការណ៍ប្រចាំខែ ឬក៏របាយការណ៍រួមបញ្ជូនទៅថ្នាក់លើ តើចុះព័ត៌មានថាយ៉ាងដូចម្តេចនៅក្នុងបញ្ជី?

ឆេ៖ ចំពោះអ្នកទោសដែលធ្វើការនៅខាងក្រៅ គឺក្នុងបញ្ជីប្រចាំថ្ងៃ គឺគេដាក់តែបញ្ជីឈ្មោះអ្នកទោសចូល ។ ឯចំពោះ បញ្ជីរួមគឺអត់ដែលបានសរសេរទេ គឺចំពោះអ្នកទោសដែលនៅប៉ុន្មានអីប៉ុន្មានគឺអត់ដែលបានសរុប ។

សេ៖ អរគុណលោក សួស ធី ដែលបានប្រឹងប្រែងអស់ក្នុងការឆ្លើយនូវសំណួររបស់យើង ។ ប៉ុន្តែ ដោយសារពេលវេលាដំណើរការសវនាការ គឺដល់ម៉ោងត្រូវឈប់សម្រាកហើយ ហើយលោកត្រូវបន្តផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះបន្តនៅថ្ងៃស្អែកទៀត ។ ដូច្នេះ ថ្ងៃនេះគឺសម្រាកត្រឹមនេះ ហើយថ្ងៃស្អែកអង្គជំនុំជម្រះអញ្ជើញលោកមកផ្តល់សក្ខីកម្មជាបន្តនៅម៉ោងប្រាំបួនព្រឹក ។ ដូច្នេះ សូមលោក អញ្ជើញមកតាមការកំណត់នេះ ។ អ៊ីចឹង អង្គជំនុំជម្រះផ្អាកសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកបន្តទៅថ្ងៃស្អែក ។ ហើយមន្ត្រីតុលាការសម្របសម្រួលជូនសាក្សីរូបនេះទៅទំនាក់ទំនងជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញដើម្បីបានជូនគាត់ទៅរកកន្លែងសម្រាក និងឲ្យអង្គភាពនោះនាំគាត់មកកាន់អង្គជំនុំជម្រះនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក ដើម្បីបន្តនីតិវិធី ។

អនុរក្សមន្ទីរ ឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំជនជាប់ចោទមកកាន់សាលសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក ៕

[សវនាការផ្អាកនៅម៉ោង ១៦: ២១នាទី]